ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Apr-2017, 13:14
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥**

**ម៉ោង ០៩:១០នាទី**

**សវនាការលើកទី៣០៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ត្រាវីស ហ្វារ
*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms. Marie GUIRAUD)*

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក សេង លាង | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី ឃិន វ៉ាត (2-TCW-866) | ខ្មែរ |
| លោក អ៊ុំ ជី (2-TCW-926) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី យិន ឌ៉ាត** (2-TCW-866)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................................................ទំព័រ ៣
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី.................................................................ទំព័រ ១៨
សួរដោយលោក គង់ សំអុន ផ្ដើមពី .......................................................................ទំព័រ ២៣

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុំ ជី** (2-TCW-926)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ...........................................................................ទំព័រ ២៥
សួរដោយលោក សេង លាង ផ្ដើមពី .......................................................................ទំព័រ ២៨
សួរដោយ លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ......................................................ទំព័រ ៤២
សួរដោយលោក ឡៅ ជុនធី ផ្ដើមពី........................................................................ទំព័រ ៦០
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................................................ទំព័រ ៦៥
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី.................................................................ទំព័រ ៧៥
សួរដោយលោក គង់ សំអុន ផ្ដើមពី .......................................................................ទំព័រ ៨៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១០:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មសាក្សី ឃិន វ៉ាត ពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយនិងផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-926 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការដ្ឋានទំនប់១មករា។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ឃិន វ៉ាត។ លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

នៅថ្ងៃនេះ មានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-926។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅព្រឹកនេះ មុនពេលផ្តល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិមានវត្តមាន និងចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥។

[០៩:១៣:២៩]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ បានកត់សម្គាល់ថា សុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះ ឈឺខ្នង មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមសាលសវនាការនេះ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ដែលដំបូងនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរភាគី សូមជម្រាបសួរលោកស្រីសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក រ៉ុចទ័រ កូប៉េ៖**

**ស៖** នៅថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរអ្នកស្រី។ ហើយជាដំបូង ខ្ញុំសូមចាប់ផ្ដើមសួរអំពីអ្វីដែលអ្នកស្រីបាននិយាយកាលពីព្រឹកម្សិលមិញ នៅពេលដែល<>លោកប្រធានបានសួរអ្នកស្រី។ ខ្ញុំសូមអានសម្រង់<ខ្លីមួយ>ដែលមាននៅក្នុងប្រតិចារឹកនៃការសួរសំណួររបស់អ្នកស្រី។ លោកប្រធាននៅម៉ោងដប់មួយ ម្ភៃប្រាំបួន បានសួរអ្នកស្រី៖ “ថាតើមុនពេលដែលអ្នកស្រីមកបង្ហាញខ្លួននៅចំពោះមុខតុលាការ តើអ្នកស្រីមានបានអានកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រី ដើម្បីជួយរំឭកដល់ការចងចាំរបស់អ្នកស្រីដែរឬទេ?” ហើយអ្នកស្រីបានឆ្លើយថា៖ “ក្មួយរបស់ខ្ញុំបានអានឲ្យខ្ញុំស្ដាប់”។ ហើយបន្ទាប់មកទៀតលោកប្រធានបានសួរអ្នកស្រី៖ “តាមដែលអ្នកស្រីចាំ ថាតើកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រីហ្នឹង វាបានឆ្លុះបញ្ចាំងទៅលើ<ពាក្យពេចន៍>ដែលអ្នកស្រីបានផ្ដល់ចម្លើយជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៅផ្ទះរបស់អ្នកស្រី ឬក៏អត់?” ហើយអ្នកស្រីបានឆ្លើយថា៖ “ចាស គឺខ្ញុំចាំទៅលើអ្វីដែលខ្ញុំបានឆ្លើយនោះ”។ ហើយសំណួរបញ្ចប់របស់លោកប្រធានសួរថា៖ “តើកំណត់ហេតុស្ដាប់ចម្លើយហ្នឹង ស្របជាមួយនឹងអ្វីដែលអ្នកស្រីបានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៅពេលសួរដែរឬអត់?” អ្នកស្រីឆ្លើយថា៖ “ចាស គឺវាស្របទៅនឹងអ្វីដែលខ្ញុំបានឆ្លើយ”។ លោកស្រីសាក្សីខ្ញុំចង់សួរថា តើពេលណាដែលក្មួយរបស់អ្នកស្រីអានឲ្យអ្នកស្រីស្ដាប់នូវកំណត់ហេតុស្ដាប់ចម្លើយមួយនេះ?

[០៩:១៦:៥១]

**លោកស្រី ឃិន វ៉ាត៖**

**ឆ៖** ចាស ក្មួយខ្ញុំអានមុននឹងចូលហ្នឹង ព្រឹកហ្នឹង ព្រឹកម្សិលមិញហ្នឹង។

**ស៖** ហើយនៅពេលដែលគាត់អានឲ្យអ្នកស្រីស្ដាប់នោះ តើអ្នកស្រីមានគិតថាផ្នែកណាខ្លះនៅក្នុងកំណត់ហេតុហ្នឹងវាមិនត្រឹមត្រូវ ឬក៏អ្នកស្រីគិតថាអ្វីដែលអ្នកស្រីឆ្លើយនៅពេលហ្នឹងខុសពីអ្វីដែលអ្នកស្រីចាំដែរឬទេ?

**ឆ៖** ចាស ខ្ញុំអាចភ្លេចខ្លះដែរ ចម្លើយមិនអាចឆ្លើយគ្រប់គ្រាន់ ព្រោះខ្ញុំមានការចងចាំតិច។

**ស៖** តើអ្នកស្រីចាំទេ ថាការសម្ភាសនៅឆ្នាំ២០០៩ គឺ<>អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង<>ធ្វើការសម្ភាស<លោកស្រីដែរទេ>?

**ឆ៖** ចាស កាលណោះ ខ្ញុំចង់ភ្លេចដែរទាល់តែបានអាន ក្មួយអានឲ្យស្ដាប់បានខ្ញុំចាំ ព្រោះខ្ញុំវា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យូរហើយ ខ្ញុំមានជំងឺក្នុងខ្លួនខ្ញុំច្រើនទៅ ខ្ញុំអាចភ្លេច។ ប៉ុន្តែដឹងថាគាត់មកសុំខ្ញុំមកបំភ្លឺពេលនោះ ខ្ញុំក៏សន្យាថា បើសុខភាពបាន ខ្ញុំអាចមក។ ខ្ញុំចាំបានប៉ុណ្ណឹង តែការឆ្លើយលម្អិតខ្ញុំចាំបានត្រួសៗទេ ខ្ញុំមិនបានលម្អិត ទាល់តែខ្ញុំបានក្លាយបានអាននេះ ខ្ញុំក៏ចាំចំណុចខ្លះដែលខ្ញុំបានឆ្លើយកាលនោះ។

**ស៖** ខ្ញុំយល់អំពីចំណុចទាំងអស់នេះ ប៉ុន្តែអ្នកស្រីចាំទេថា ចម្លើយដែលអ្នកស្រីបានផ្តល់កាលពី ៦ឆ្នាំមុននេះ ថាតើអ្នកស៊ើបអង្កេតមានអានចម្លើយឱ្យអ្នកស្រីស្តាប់ដែរឬទេ? ហើយបន្ទាប់<ពីស្តាប់រួចហើយ> តើអ្នកស្រីមានចាំថា អ្នកស្រីបានចុះហត្ថលេខាទៅលើកំណត់ហេតុស្តាប់ចម្លើយហ្នឹងដែរឬទេ?

**ឆ៖** ចាស កាលនោះខ្ញុំអត់បានមើលទេ តែគ្រាន់ថាការចុះកំណត់ហេតុហ្នឹង ខ្ញុំបានសន្យាជាមួយគាត់ថា ខ្ញុំអាចមកនៅធ្វើសាក្សីឱ្យខាងគាត់។

[០៩:២០:២៩]

**ស៖** ខ្ញុំយល់អ្នកស្រី។ ប៉ុន្តែ<បើ>ខ្ញុំ<យល់មិនខុសទេ> ថាអ្នកស្រីមិនអាចអាន មិនអាចសរសេរបាន ប៉ុន្តែខ្ញុំចង់សួរថា កាលពី៦ឆ្នាំមុននៅពេលដែលគេសម្ភាសអ្នកស្រីហ្នឹង ថាតើអ្នកស៊ើបអង្កេតហ្នឹងគាត់មានបានអានឱ្យអ្នកស្រីស្តាប់ទៅលើអ្វីដែលអ្នកស្រីបានឆ្លើយប្រាប់ពួកគាត់ដែរឬទេ?

**ឆ៖** ខ្ញុំភ្លេចបាត់ទៅហើយ ដឹងថាបាន ដឹងអត់ អត់ចាំដែរ ខ្ញុំភ្លេចអស់។

**ស៖** អ្នកស្រីសាក្សី ហេតុផលដែលខ្ញុំសួរសំណួរបែបនេះ ព្រោះថា វាមានភាពលម្អៀងមួយចំនួនអំពីអ្វីដែលអ្នកស្រីបានផ្តល់កាលពីម្សិលមិញ និងអ្វីដែលអ្នកស្រីបាននិយាយកាលពី៦ឆ្នាំកន្លងមក គឺទៅពេលដែលអ្នកស្រីផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេត។ យើងរកឃើញ<ឧទាហរណ៍នៃ> <> ភាពខុសគ្នា<ប្រហែលជា>ប្រាំបីចំណុច <>។ ដូច្នេះ តើអ្នកស្រីអាច<បំភ្លឺ>បានទេថា តើហេតុអ្វីក៏ដូច្នេះ? ឬមួយក៏អ្នកស្រីចង់ឱ្យខ្ញុំលើកយក<ឧទាហរណ៍មួយចំណុច ឬពីរ>ចំណុចដែល<លម្អៀង>ហ្នឹងយកមក<បង្ហាញ>អ្នកស្រី ហើយ<និងសួរអ្នកស្រីឱ្យឆ្លើយតបមកវិញ?>

**ឆ៖** ចាស ខ្ញុំអត់ចាំអស់។ ស្រេចតែខាងអស់លោកហ្នឹងសួរ ខ្ញុំអាចឆ្លើយបាន ខ្ញុំឆ្លើយ។ ខ្ញុំអាចចាំខ្ញុំឆ្លើយ បើខ្ញុំបាត់ អត់ភ្លេច ខ្ញុំភ្លេច អត់ចាំ ខ្ញុំក៏ឆ្លើយមិនអាចបានដែរ។ បើកន្លែងណាខ្ញុំចាំ ខ្ញុំឆ្លើយបានសួរចុះ។

[០៩:២២:៣៧]

**ស៖** ខ្ញុំសូមចាប់ផ្តើមនូវឧទាហរណ៍មួយ។ អ្នកស្រីកាលពីម្សិលមិញ ឥឡូវនេះខ្ញុំចាប់ផ្តើមដំបូងដោយអាននូវកំណត់ហេតុស្តាប់ចម្លើយអ្នកស្រីគឺ E3/5284 ខ្មែរមានលេខ 00 -- គឺខ្មែរមានលេខ

<00315914>, <បារាំង 00375492 និងខ្មែរ 00304364។> អ្នកស្រីបានឆ្លើយជាមួយអ្នកស៊ើបអង្កេតថា នៅពេលដែលអ្នកស្រីធ្វើការនៅ<ព្រលានយន្តហោះ>ពោធិ៍ចិនតុង អ្នកស្រីបានអមដំណើរជាមួយនឹងជនជាតិចិនទៅកំពង់ឆ្នាំង <ទៅសិក្សាពី>ព្រលានយន្តហោះកំពង់ឆ្នាំងប្រហែលជាបីដងក្នុងមួយ<ខែ>។ កាលពីម្សិលមិញ អ្នកស្រីបាននិយាយថា អ្នកស្រីមិនដែលទៅកំពង់ឆ្នាំងជាមួយ<ក្រុមជនជាតិ>ចិនទេ គឺអ្នកស្រីទៅកំពង់ឆ្នាំង<លើកទី១ហើយតែម្តងគត់ក្នុងឆ្នាំ១៩៧៧ គឺ>តែមួយសប្តាហ៍ប៉ុណ្ណោះ ដើម្បីរៀបការជាមួយប្តីរបស់អ្នកស្រីនោះ--

**លោក ត្រាវីស ហ្សារ៖**

លោកប្រធាន<> ខ្ញុំសូមទាញចំណាប់អារម្មណ៍<អង្គជំនុំជម្រះ>ថា កាលពីម្សិលមិញ គាត់និយាយថា គាត់ជាអ្នកដាំស្លឲ្យភ្ញៀវចិននៅ<ឯព្រលានយន្តហោះ>កំពង់ឆ្នាំង ប្រហែលជាមួយសប្តាហ៍<ក្នុងពេលមួយ>។ មិនមែនជាការជំទាស់ទេ ប៉ុន្តែគ្រាន់ជាការរំឭក<ភាគីទាំងអស់អំពីសក្ខីកម្មជាក់ស្តែងរបស់គាត់គឺ> គាត់បានទៅ<ព្រលានយន្តហោះ>កំពង់ឆ្នាំងប្រហែលជាមួយសប្តាហ៍ដើម្បីជួយដាំស្លឲ្យភ្ញៀវចិន នៅកំពង់ឆ្នាំងនោះ<ក្នុងពេលមួយ>។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកព្រះរាជអាជ្ញា ដែលបានផ្តល់នូវការកត់សម្គាល់នេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះខ្ញុំចង់សួរអ្នកស្រីថា តើវាមានអ្វីខុសគ្នា<រវាងរឿងទាំងពីរនេះ> ឬមួយក៏ខ្ញុំយល់ខុសទៅលើចម្លើយរបស់អ្នកស្រីទៅវិញទេ?

[០៩:២៥:៣៨]

**លោកស្រី ឃិន វ៉ាត៖**

**ឆ៖** ចាស ការឆ្លើយរបស់ខ្ញុំនេះ ខាងលោក គឺស្តាប់ច្បាស់លាស់ តែខ្ញុំគឺមានភ្លេចភ្លាំង ខ្ញុំមិនអាចចាំបាន តែពេលវេលាដែលខ្ញុំនិយាយជាមួយគាត់នៅឯផ្ទះនោះ ខ្ញុំភ្លេចអស់ហើយ ខ្ញុំអត់ចាំ។ ខ្ញុំចាំបានតែថា ខ្ញុំអត់បានទៅយូរឆ្នាំទេនៅកំពង់ឆ្នាំងហ្នឹង ខ្ញុំបានតែទៅត្រឹមខ្ញុំរៀបការហើយ។ ទៅដាំបាយចំនួនមួយអាទិត្យហ្នឹង គេខ្ញុំមកវិញ។ ខ្ញុំទៅមួយលើកទៀត ខ្ញុំទៅនៅព្រលានធ្វើស្រែមួយរដូវស្រែហ្នឹង។

**ប្រធានអង្គជំនុំ៖**

សូមភាគីចាប់អារម្មណ៍ឡើងវិញ លើចំណុចសំណួរនិងចម្លើយ។ បើតាមខ្ញុំពិនិត្យជាភាសាខ្មែរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សាក្សីឆ្លើយសមស្របហើយ មកពីការយល់។ ម្សិលមិញសំណួរនេះសួរឡើងដោយក្រុមសហមេ -- តំណាងមេធាវី -- តំណាងដើមបណ្ដឹងរដ្ឋប្បវេណី វ៉ែន ពៅ។ គាត់ក៏ទំនងជាយល់ច្រឡំនូវសំណួរដែរ នូវចម្លើយរបស់សាក្សីដែរ។ សាក្សីឆ្លើយថា៖ "ខ្ញុំបានមកជាមួយចិន ដែលពួកទាំងនោះមកមើលព្រលានយន្តហោះនៅកំពង់ឆ្នាំងជាញឹកញាប់ប្រហែលបីដងក្នុងមួយខែ។" ពួកចិនទេ ដែលមកទៅមើលព្រលានយន្តហោះម្ដងបីខែ -- ប្រហែលជាបីៗដងក្នុងមួយខែ។ មិនមែនគាត់ទៅមើលព្រលានយន្តហោះក្នុងបីដងមួយខែទេ។ គាត់គ្រាន់តែបញ្ជាក់ថា គាត់ជាមួយចិន ប៉ុន្តែអាពួកចិនហ្នឹង ពួកជំនាញការចិនហ្នឹង គឺទៅធ្វើ ទៅមើលព្រលានយន្តហោះបីដងក្នុងមួយខែ។ នេះជាភាសាខ្មែរ។ យើងឃើញម្សិលមិញក៏មានការភ័ន្តច្រឡំដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរបញ្ហានេះដែរ។

[០៩:២៦:៥៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមលើកឧទាហរណ៍មួយទៀត លោកប្រធាន។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រី អ្នកស្រីបាននិយាយថា អ្នកស្រីបានស្ដាប់ឮការនិយាយគ្នារបស់មេដឹកនាំជាន់ខ្ពស់នៅព្រលានយន្តហោះដូចជា ល្វៃ ហើយនិង ធួក១។ កាលពីម្សិលមិញអ្នកស្រីនិយាយថា <អ្នកស្រីគិតតែពីរឿងការងារខ្លួនឯង>អ្នកស្រីមិនខ្វល់ពីអ្នកដទៃទេ អ្នកស្រីអត់ព្យាយាមស្ដាប់<>អ្នកនិយាយនោះឡើយ។ ដូច្នេះខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីស្ដាប់ឮការជជែកគ្នានៅព្រលានយន្តហោះកំពង់ឆ្នាំង ឬមួយក៏អ្នកស្រីអត់ស្ដាប់ឮទេ គឺអ្នកស្រីមិនខ្វល់ពីការនិយាយរបស់អ្នកដទៃនោះទេ? តើមួយណាជាចម្លើយដែលត្រឹមត្រូវ?

**លោកស្រី ឃិន វ៉ាត៖**

**ឆ៖** ចាស ពេលខ្ញុំនៅដាំស្លហ្នឹង គាត់ក៏និយាយគ្នាគាត់ ពីរឿងផែនការធ្វើហ្នឹង។ ខ្ញុំអត់បានចាប់អារម្មណ៍មែន ប៉ុន្តែថាការនិយាយៗពីរឿងធ្វើការហ្នឹងហើយ ធ្វើផែនការព្រលានហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ឧទាហរណ៍<ចុងក្រោយ បន្ទាប់មកខ្ញុំនឹង>សួរ<>បន្តទៅចំណុចផ្សេង។ កាលពីម្សិលមិញគេសួរអ្នកស្រី អំពីការចោទប្រកាន់ពីការសម្លាប់ខ្លួននៅព្រលានយន្តហោះកំពង់ឆ្នាំង។ កាលពីម្សិលមិញ អ្នកស្រីផ្ដល់នូវឧទាហរណ៍ពីរ។ ប៉ុន្តែនៅក្នុងចម្លើយរបស់អ្នកស្រី ជាមួយអ្នកស៊ើបអង្កេត អ្នកស្រីនិយាយថា<ធ្វើអត្តឃាតដោយ>រត់ចូលទៅ<ក្រោម>កង់ឡាន គឺថាកើតឡើងជាញឹកញាប់។ ថាតើអ្វីដែលអ្នកស្រីផ្ដល់ចម្លើយកាលពីម្សិលមិញត្រឹមត្រូវ ឬមួយក៏អ្វីដែលអ្នកស្រីប្រាប់អ្នកស៊ើបអង្កេតនុ៎ងត្រឹម

ត្រូវ? តើមួយណាជាចម្លើយត្រឹមត្រូវ?

**ឆ៖** ចាស ខ្ញុំអត់ដឹងញឹកញាប់ទេ។ ខ្ញុំដឹងតែម្តង ឮអ្នកបើកឡានហ្នឹងគាត់និយាយគ្នាទេ។ ដឹងថា វត់ចូលតែម្តងហ្នឹងទេ ខ្ញុំអត់ដឹងថាញឹកញាប់។ ញឹកញាប់ហ្នឹង ខ្ញុំអត់បានដឹង អត់បាននិយាយទេ។ ដឹងថាតែម្តង។

[០៩:២៩:៥៤]

**ស៖** សូមអរគុណអ្នកស្រី។ ឥឡូវនេះ ខ្ញុំសូមបន្តទៅសំណួរផ្សេងទៀត។ កាលពីម្សិលមិញ អ្នកស្រីបានផ្តល់សក្ខីកម្មអំពីប្តីរបស់អ្នកស្រីដែលបាត់ខ្លួន គឺឈ្មោះ ឡោត ប្រសិនបើខ្ញុំចាំមិនខុសទេ។ ថាតើវាជាការពិតទេ ដែលថាប្តីរបស់អ្នកស្រីជាមេបញ្ជាការនៅក្នុងកងពិការនៃកងពល៥០២<>?

**ឆ៖** ចាស គាត់ ខ្ញុំអត់ដឹងថា គាត់មុខនាទីអីដែរទេ ប៉ុន្តែថា ឮគេឯងថាគាត់ហ្នឹងមកពីកងពិការកុមារពិការ។

**ស៖** ប៉ុន្តែអ្នកស្រីចាំទេ ថាគាត់មានឋានៈអ្វីដែរ? ថាគាត់ជាមេបញ្ជាការមែនឬទេ?

**ឆ៖** ចាស ខ្ញុំដឹងថា គាត់គ្រប់គ្រងគេដែរ ព្រោះការងារនៅហ្នឹង គាត់អ្នកចាត់ចែង ប៉ុន្តែមិនដឹងជាឋានៈប៉ុនណាខ្ញុំអត់ដឹង ដឹងថាគាត់គ្រប់គ្រងគេមែន។

**ស៖** តើអ្នកស្រីដឹងទេថា តើគាត់ជាសមាជិករបស់កងពិការ ដោយសារតែគាត់ត្រូវរបួសនៅក្នុងសង្គ្រាម? តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំឃើញគាត់ពិការជើងមែន។

[០៩:៣២:១៣]

**ស៖** តើគាត់ធ្លាប់ប្រាប់អ្នកស្រីថា គាត់របួសនៅក្នុងសមរភូមិដែរឬទេ? ហើយប្រសិនបើគាត់ធ្លាប់ប្រាប់ តើគាត់របួសហ្នឹង របួសដោយសារអ្វីដែរ? <តើគាត់បានប្រាប់អ្នកស្រីទេ?>

**ឆ៖** ខ្ញុំចាំអត់បានដែរ។ មិនដឹងជាបានសួរ ឬក៏មិនបានសួរ ខ្ញុំអត់បានចាំទេ ខ្ញុំភ្លេចអស់ហើយ។ ប៉ុនដឹងថា គាត់ពិការសមរភូមិហ្នឹង តែមិនដឹងសមរភូមិខាងណា ព្រោះគាត់នៅខាងកងពល១១។

**ស៖** <>តើកងពល<>ហ្នឹង គឺជាផ្នែកនៃ<កងទ័ព>ភូមិភាគនិរតីមែនដែរឬទេ? <តើអ្នកស្រីដឹងដែរទេ?>

**ឆ៖** ខ្ញុំអត់ដឹងដែរ។ ដឹងកងពល១១មកពីខេត្តកណ្តាលហ្នឹង ដឹងនិរតី ដឹងខាងណា ខ្ញុំអត់ដឹងដែរ។

**ស៖** តើអ្នកស្រីចង់និយាយថា អ្នកស្រីមិនដឹងថា ភូមិភាគនិរតីហ្នឹង<នៅឯណាទេមែនទេ?>

តើអ្នកស្រីចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងថា កងពលនៅនិរតី ខ្ញុំអត់ដឹង ខ្ញុំដឹងតែថា១១ កង១១តែប៉ុណ្ណឹង។

**ស៖** ខ្ញុំនឹងសួរនៅពេលក្រោយបន្តិចអំពីប្ដីរបស់អ្នកស្រី ប៉ុន្តែឥឡូវ ខ្ញុំនិយាយអំពីភូមិភាគនិរតីសិន។ នៅក្នុងចម្លើយទី១ របស់អ្នកស្រី ជាមួយអ្នកស៊ើបអង្កេត ខ្ញុំសូមដកស្រង់៖ "មុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ខ្ញុំ<ជាទាហានក្នុងកងវរសេនាតូច៣០៤ ចំណុះឲ្យ> កងពល៥០២ ក្រោមមេបញ្ជាការឈ្មោះ ខុន គឺនៅប្រចាំ<ភូមិភាគ>និរតី បោះទីតាំងនៅសំរោង ខេត្តកំពង់ស្ពឺ"។ ហើយ<នៅខាងចុងនៃចម្លើយដដែល> អ្នកស្រីឆ្លើយថា៖ "ខ្ញុំដឹងថា តាម៉ុក គឺជាអ្នកគ្រប់គ្រង<ភូមិភាគ>និរតី។" តើអ្នកស្រីអាចពន្យល់ខ្ញុំបានទេ ហេតុអីបានជាមានចំណុចទាំងអស់នេះកើតឡើង?

**ឆ៖** ខ្ញុំដឹងថា ចំណុចនេះកើតឡើងដោយខ្ញុំនៅក្នុងកង ខ្ញុំឃើញគាត់ នៅខាងកងនិរតីហ្នឹង ខាង៥០២ហ្នឹង ហើយអត់ដឹងថានិរតីហ្នឹង មានប៉ុន្មានកងពល ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែកងពល៥០២ហ្នឹង។ ហើយខ្ញុំឧស្សាហ៍ឃើញគាត់ ឮគេថាគាត់ហ្នឹងជាអ្នកគ្រប់គ្រងនៅនិរតីហ្នឹង តាម៉ុក ហ្នឹង។

[០៩:៣៦:៤៨]

**ស៖** <គឺល្អណាស់>អ្នកស្រី<សាក្សី ខ្ញុំនឹងបន្តទៅមុខទៀតទៅនិយាយពីប្ដីរបស់អ្នកស្រីម្ដងទៀត>។ កាលពីម្សិលមិញ អ្នកស្រីបាននិយាយថា គេតម្រូវឲ្យអ្នកស្រីរៀបការជាមួយ ឡោត គឺជាប្ដីរបស់អ្នកស្រីនោះឯង។ ដូច្នេះ ប្រសិនបើខ្ញុំយល់មិនខុសទេ បានន័យថា ការរៀបការហ្នឹង គឺដោយបង្ខំ។ គឺថា -- <តើអ្នកស្រីចាំទេថា អ្នកណាស្នើឲ្យលោកស្រីរៀបការជាមួយនឹង ឡោត? គាត់នោះជាអ្នកណា ហើយគាត់និយាយថាម៉េចខ្លះ?><>

**ឆ៖** កាលណោះខ្ញុំអត់មានជម្រើសដែរ ព្រោះខ្ញុំដាក់ខ្លួនខ្ញុំថា ខ្ញុំតាមអង្គការ។ អង្គការចាត់ចែងយ៉ាងម៉េច ក៏ទៅតាមហ្នឹងទៅ។ ដូច្នេះ ខ្ញុំអត់ជម្រើស គឺតាមអង្គការទាំងអស់។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ អ្នកស្រី ប៉ុន្តែខ្ញុំចង់សួរថា ថាតើអ្នកណាជាអ្នកស្នើអ្នកស្រីឲ្យរៀបការជាមួយ ឡោត? ហើយខ្ញុំចង់ដឹងថា តើអ្នកដែលស្នើឲ្យអ្នកស្រីរៀបការហ្នឹង ថាគាត់ស្នើ នៅពេលដែលគាត់ស្នើហ្នឹង គេនិយាយយ៉ាងម៉េចដែរ? តើអ្នកស្រីចាំទេ ថាគាត់ប្រាប់អ្នកស្រីយ៉ាងម៉េច ឬក៏និយាយពាក្យអ្វីខ្លះដែរ?

**ឆ៖** គាត់ កាលហ្នឹងគាត់ឈ្មោះ ខ្ញុំភ្លេចឈ្មោះគាត់ឈ្មោះ ម៉ៅ ឈ្មោះអី ភ្លេចបាត់ហើយ។ ហើយគាត់និយាយប្រាប់ខ្ញុំថា "ឥឡូវអង្គការតម្រូវឲ្យមិត្តឯងឲ្យទៅរៀបការជាមួយគេម្នាក់នៅកំពង់ឆ្នាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅព្រលានកំពង់ឆ្នាំង។ ព្រឹកនេះម៉ោងប្រាំ មិត្តឯងចាប់រៀបខ្លួនទៅ"។ គាត់និយាយប្រាប់ខ្ញុំអ៊ីចឹង។ គេហ្នឹងគឺឈ្មោះ ខ្ញុំអត់ទាន់ស្គាល់គាត់ទេ។ ទាល់តែថ្ងៃគេរៀបការ ពេលល្ងាចរៀបការហ្នឹង បានខ្ញុំស្គាល់គាត់ ស្គាល់ឈ្មោះគាត់។ ពេលនោះខ្ញុំទាំងពីរ គឺអត់ដែលឃើញគ្នាទេ។

[០៩:៣៩:៤០]

**ស៖** តើអ្នកស្រីចាំទេ អ្នកដែលស្នើអ្នកស្រីឲ្យរៀបការជាមួយ ឡោត នោះតើគាត់មាននិយាយអ្វីប្រាប់អ្នកស្រីខ្លះ? តើគាត់មាននិយាយប្រាប់អ្នកស្រីអំពីរបួស ឬក៏ពិការភាពរបស់ប្ដីអ្នកស្រី<ក្នុងសមរ-ភូមិ>ដែរឬទេ?

**ឆ៖** ចាស ពេលនោះគាត់អត់ប្រាប់ទេ គាត់ប្រាប់តែឈ្មោះ។ គាត់ឈ្មោះ ឡោត ហ្នឹងនៅឯកំពង់ឆ្នាំងហ្នឹង គាត់ប្រាប់តែប៉ុណ្ណឹង។

**ស៖** សូមអរគុណអ្នកស្រី ខ្ញុំសូមបន្តទៅមុខទៀត។ នៅក្នុងចម្លើយរបស់អ្នកស្រីប្រាប់អ្នកស៊ើបអង្កេត អ្នកស្រីនិយាយថាមានម្ដងនោះ អ្នកស្រីបានចូលរណសិរ្សរំដោះជាតិកម្ពុជា។ តើអ្នកស្រីចាំទេ ថាហេតុអ្វីបានជាអ្នកស្រីចូលរួមក្នុងរណសិរ្សរំដោះជាតិកម្ពុជា?

**ឆ៖** កាលនោះ ខ្ញុំនៅក្នុងមូលដ្ឋាននៅភូមិឃុំខ្ញុំ ឃើញកម្មាភិបាលគេដើរហៅនារីតាមភូមិហ្នឹងឲ្យរៀនសូត្រ ឲ្យដឹងថាកម្ពុជាហ្នឹងមានរដ្ឋប្រហារសម្ដេច ហើយគ្រប់គ្រងដោយអាមេរិកាំង ហើយនិងធីវគី។ ពេលនោះគាត់ថា បើអ្នកស្ម័គ្រចិត្តសង្គ្រោះជាតិ ស្នេហាជាតិ លះបង់អាយុជីវិតដើម្បីជាតិ ឲ្យស្ម័គ្រចិត្តចូលក្នុងរណសិរ្សហ្នឹងតាមប្រធានភូមិ និងកម្មាភិបាលភូមិ។ ពេលនោះ ខ្ញុំក៏សម្រេចចិត្តថា បើខ្ញុំនៅជានារីភូមិ ក៏មិនដឹងទឹកដីហ្នឹងយ៉ាងម៉េច។ ខ្ញុំជឿនៅលើសង្គ្រោះជាតិហ្នឹង ព្រោះចលនាខាងកាលនោះគឺ ប្រជាជនស្រឡាញ់សម្ដេច គោរពសម្ដេច ក៏ទាំងអស់គ្នានាំគ្នាស្ម័គ្រចិត្តចូលសង្គ្រោះជាតិហ្នឹងចាស។

[០៩:៤២:៥០]

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រី គេសួរសំណួរដដែលគ្នានេះ គឺសំណួរទី២ នៅក្នុងឯកសារដដែលនេះ ហើយអ្នកស្រីបាននិយាយប្រាប់អ្នកស៊ើបអង្កេតថា៖ "នៅពេលនោះ គឺមានចលនា<មួយ>នៅ<តាម>ជនបទ<ក្នុងចំណោមប្រជាជន> ដើម្បីរំដោះប្រទេសជាតិចេញពី<ជិះជាន់>នាយទុន សក្ដិភូមិ ដែលជិះជាន់កសិករក្រីក្រ។" តើអ្នកស្រីចាំទេ ថាអ្នកស្រីបាននិយាយថា នៅជនបទមានចលនាមួយមកបំផុសបំផុលឲ្យប្រជាជនតស៊ូរំដោះជាតិប្រឆាំងនឹងការជិះជាន់ ដូចជានាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទុនសក្តិភូមិដែលជិះជាន់កសិករក្រីក្រ?

**ឆ៖** ចាស ខ្ញុំចាំបាន។ ហើយខ្ញុំក៏ចូលជាមួយគាត់ ប្តេជ្ញាចិត្ត និងដើរតាមមាគ៌ារបស់គាត់មែន ជំនាន់នោះ។ ចាស ខ្ញុំធ្វើតាម។ ខ្ញុំបានឃើញបានរៀនសូត្រពីកម្មាភិបាលគាត់ចុះដើរតាមមូលដ្ឋានហ្នឹង។

**ស៖** តើអ្នកស្រីចាំទេ ថាតើអ្នកស្រីមានន័យយ៉ាងដូចម្តេចនៅពេលដែលអ្នកស្រីនិយាយពាក្យថា "នាយទុន សក្តិភូមិ ដែលជិះជាន់ <និងកេងប្រវ័ញ្ច>កសិករក្រីក្រ" នោះ?

**ឆ៖** ចាស កាលនោះខ្ញុំយល់ថា នាយទុន គឺគេអ្នកមានអំណាច។ គេជិះជាន់ដល់យើងខ្ញុំមិនឲ្យ មានសិទ្ធិសេរីភាពអី ឬក៏ការចូលរួមអីទាំងអស់ និងការរកស៊ីអី។ ហ្នឹងខ្ញុំយល់ថាអ៊ីចឹង គឺផ្តាច់ការ។

**ស៖** សូមអរគុណអ្នកស្រីដែលបានពន្យល់។ ឥឡូវនេះ ខ្ញុំសូមបន្តទៅព្រលានយន្តហោះកំពង់-ឆ្នាំង។ កាលពីម្សិលមិញ គេសួរអ្នកស្រីអំពីកងទ័ពដែលអ្នកស្រីបានឃើញកំពុងតែធ្វើការនៅការដ្ឋានព្រលានយន្តហោះនោះ។ តើអ្នកស្រីចាំទេ គឺថា<គេសួរសំណួរនេះទៅអ្នកស្រី> ឥឡូវខ្ញុំសួរអ្នកស្រីជាទូទៅសិន ថាតើអ្នកស្រីចាំទេ ថាតើកងពលផ្សេងៗគ្នានោះ ថាតើកងពលជាច្រើនហ្នឹងមកពី<ណា? ហើយមកពី> ផ្នែកណាក្នុងប្រទេសខ្មែរយើងនោះ?

**ឆ៖** ចាស ខ្ញុំបានឮគាត់និយាយ ឬក៏មិត្តភក្តិខ្ញុំនិយាយគ្នា អ្នកធ្លាប់ស្គាល់ធ្វើការជាមួយគ្នាហ្នឹង ថាមកពីបូព៌ា អ្នកធ្វើ។ ខ្ញុំដឹងតែប៉ុណ្ណឹង បូព៌ានិងនិរតីហ្នឹង។

**ស៖** សូមអរគុណលោកស្រីសាក្សី។ នៅក្នុងចម្លើយរបស់លោកស្រី លោកស្រីបានឆ្លើយថា មានពីរកងពលមកពីបូព៌ា មួយកងពលមកពីឧត្តរ និង<ពីរ>កងពលទៀតមកពីនិរតី តើត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រូវហើយ។ ខ្ញុំដឹងប៉ុណ្ណឹង តែខ្ញុំភ្លេច។

**ស៖** លោកស្រីចាំ<លេខរបស់>កងពលទាំងអស់នេះទេ? លោកស្រីផ្ទាល់<មកពី>កងពល ៥០២ ចុះ លោកស្រីស្គាល់លេខកងពលពីរទៀត ដែលមកពីភូមិភាគបូព៌ាទេ?

**ឆ៖** ចាស ខ្ញុំអត់ស្គាល់ទេ ព្រោះអីខ្ញុំៗទៅហ្នឹងគឺរយៈពេលខ្លី ហើយអ្នកធ្វើការស្រែជាមួយគ្នា គាត់និយាយ ហើយខ្ញុំក៏អត់បានលម្អិត ចាំអី ដេញដោលអីដែរ។ គ្រាន់តែដឹងថា កម្លាំងនៅហ្នឹងគឺធ្វើ ចម្រុះ មានបីកងពលហ្នឹង។ ខ្ញុំអត់ស្គាល់លេខកងពលទេ។

**ស៖** លោកស្រីនៅចាំថា កងទ័ពចំនួនកងទ័ពចំណុះឲ្យកងពលមកពីភូមិភាគនិរតី គឺមានចំនួន ដូចគ្នា ស្មើគ្នាជាមួយនឹងកងទ័ពពីរកងពលទៀតមកពីភូមិភាគបូព៌ាទេ? <សួរមួយបែបទៀតថាអ៊ីចេះ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថាតើអ្នកស្រីអាចប្រាប់បានទេពីចំនួនកងទ័ពដ៏ច្រើនមកពីបូព៌ា មកពីឧត្តរ និងមកពីភូមិភាគនិរតីបានទេ?>

[០៩:៤៩:២០]

**ឆ៖** ចាស តាមខ្ញុំវិភាគមើលក្នុងខ្លួនរបស់ខ្ញុំ ខ្ញុំថាកងពលខាងឧត្តរ និងបូព៌ាហ្នឹងគឺមានចំនួនច្រើនណាស់ ព្រោះគាត់ធ្វើការបានច្រើន។ ហើយចំនួន៥០២ហ្នឹង គឺតិចដែរទេ ទៅធ្វើការឡូកជាមួយគ្នាហ្នឹង។

**ស៖** ពីម្សិលមិញលោកស្រីបានឆ្លើយថា សូមដកស្រង់ លោកស្រីឃើញថាប្រជាជនជាច្រើន -- អ្នកធ្វើការជាច្រើនស្លៀកពាក់ឯកសណ្ឋានកងទ័ព។ តើលោកស្រីអាចធ្វើការញែកពីគ្នាទៅតាមការសម្គាល់ឯកសណ្ឋាននេះ ថាតើកងទ័ពមកពីបូព៌ា ឧត្តរ <ឬក៏មកពីភូមិភាគ>និរតី? <>

**ឆ៖** ចាស ការស្លៀកពាក់ហ្នឹង គឺកងទ័ពហ្នឹង គឺដូចតែគ្នាទេស្លៀក មិនខុសគ្នាទេ។ ប៉ុន្តែថាការធ្វើការផ្នែកជាមួយបរទេសចិនហ្នឹង គឺវាមានពាក់ខោអាវគេ អ្នកធ្វើផ្លូវ អ្នកធ្វើខ្សែភ្លើង អ្នកសង់សំណង់ផ្ទះប្រាំជាន់អីអ៊ីចឹងទៅ។ ការស្លៀកពាក់ហ្នឹង ខ្ញុំពិនិត្យថា បើកងទ័ពស្លៀកដូចតែគ្នាហ្នឹង។

**ស៖** បាទ ដើម្បីឱ្យខ្ញុំយល់បានច្បាស់នោះ គឺថាកងទ័ពទាំងអស់ដែលលោកស្រីបានឃើញនេះ គឺថាស្លៀកពាក់ឯកសណ្ឋានដូចៗតែគ្នាទេ។ អ៊ីចឹងគឺថា ឯកសណ្ឋាននេះ គឺកងទ័ពទាំងមកពីបូព៌ា ទាំងពីឧត្តរ ទាំងនិរតីគឺថាស្លៀកពាក់ដូចតែគ្នាទេ ពណ៌ដូចតែគ្នាទេ<>អ៊ីចឹងមែនទេ?

**ឆ៖** ចាសៗ មែនហើយ ស្លៀកដូចតែគ្នា។

[០៩:៥២:០៨]

**ស៖** តើកងទ័ពមានស្លៀកពាក់ពណ៌ស្លឹកឈើ ពណ៌បៃតងដែរទេ ក្រៅពីឯកសណ្ឋានពណ៌ខ្មៅ?

**ឆ៖** ចាស អត់មានទេ។ អត់ មិនមានទេ។

**ស៖** កាលពីម្សិលមិញ លោកស្រីបានបញ្ជាក់អះអាងថា លោកស្រីក៏បានឆ្លើយប្រាប់អ្នកស៊ើបអង្កេត<ដែរ>ថា កម្លាំងកងទ័ពមកពីភូមិភាគបូព៌ាធ្វើការនៅ<ការដ្ឋាន គឺមកពីកងពល ឬក៏អង្គភាព> ដែលមេ<>នៅទីនោះត្រូវបានគេដកចេញ។ លោកស្រីដឹង<ទេ>ថា មេបញ្ជាការទ័ព<ភូមិភាគបូព៌ា><>ដែលត្រូវបានគេដកយកចេញទៅនោះ<ឈ្មោះអីដែរ>?

**ឆ៖** ចាស ខ្ញុំអត់បានស្គាល់ឈ្មោះទេ ហើយអត់បានដឹងជាលម្អិតដែរ ព្រោះពេលខ្ញុំទៅដល់ហ្នឹងគឺឃើញតែកងទ័ពហ្នឹងឃើញតែថ្នាក់ក្រោមៗទេ មេគេអត់ឃើញទេ។ ហើយគេឱ្យកង៥០២ហ្នឹង ទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គ្រប់គ្រង នាំកងទ័ពហ្នឹងទទួលផែនការពីចិន ពីអីធ្វើ។ ខ្ញុំអត់ដឹងថាឈ្មោះអីដែលគេដកហ្នឹង គឺខ្ញុំអត់ដឹងទេ ព្រោះខ្ញុំទៅពេលរយៈពេលខ្លីដែរ។

**ស៖** លោកស្រីដឹង<ពីមូលហេតុដែលគេដាក់ឲ្យកងទ័ពមកពីកងពល៥០២ ទទួលបន្ទុកការងារ គឺដោយសារតែកងពល៥០២នេះគឺជាកងទ័ពអាកាស ដែរឬទេ?>

**ឆ៖** ចាស ដឹង។

[០៩:៥៤:៥៩]

**ស៖** នៅពេលគេបញ្ជូនលោកស្រីទៅឲ្យធ្វើការនៅវាលស្រែ ក្បែរព្រលានយន្តហោះកំពង់ឆ្នាំង តើការបញ្ជូននេះ ដោយសារតែលោកស្រីជាកងទ័ពនៅក្នុងកងពល៥០២ ឬក៏យ៉ាងណា? <>ការបញ្ជាណាមួយឲ្យលោកស្រីធ្វើការណាមួយ <តើវាជាការងារធម្មតាក្នុងនាមជាកងទ័ពក្នុង>កងពល៥០២ ឬក៏យ៉ាងណា?

**ឆ៖** ចាស ពេលនោះខ្ញុំដឹងពីគាត់ឈ្មោះ ធួក ហ្នឹងហើយ គាត់បញ្ជាហៅខ្ញុំពីអូរបែកក្អមហ្នឹងឲ្យខ្ញុំវិលទៅធ្វើស្រែនៅឯហ្នឹង។

**ស៖** ប៉ុន្តែនៅពេលដែលគាត់ណែនាំឲ្យលោកស្រីធ្វើការណាមួយនោះ ថាតើវាជាការបញ្ជាក្នុងការបំពេញភារកិច្ច<យោធា>ជាធម្មតា <ដូចជាបញ្ជាដែលលោកស្រីទទួលពេលនៅជាទាហាន><> ឬមួយក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។<អង្គជំនុំជម្រះ និងភាគីសូមកែខ្ញុំត្រង់កន្លែងណាចាំបាច់ដោយសារថា> ខ្ញុំមិនបានអានប្រតិចារឹក<ឡើងវិញទេ មុនពេលសវនាការចាប់ផ្ដើម> ខ្ញុំ<គ្រាន់>តែអានទូវកំណត់ត្រារបស់ខ្ញុំ ក៏ប៉ុន្តែកាលពីម្សិលមិញ សាក្សីគាត់ដូចជានិយាយបានច្បាស់ហើយថា គាត់ត្រូវបានបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង គឺ<ក្នុងទម្រង់ជាការដាក់> ទណ្ឌកម្ម។ ដូច្នេះ អ្វីដែលបានលើកឡើងនោះ គឺថាវាផ្ទុយគ្នាទាំងស្រុងទៅនឹងចម្លើយរបស់សាក្សីដែលគាត់បានឆ្លើយកាលពីម្សិលមិញ។ អ៊ីចឹងសំណួររបស់មេធាវីការពារក្ដី <ខ្ញុំយល់ថា ទំនង>គឺជាសំណួរ

នាំមុខ។ សូមឲ្យគាត់រៀបចំសំណួរគាត់ឡើងវិញ<ឲ្យបានទូទៅជាងនេះ> ពីព្រោះថាសំណួរហ្នឹងវាផ្ទុយទៅនឹងអ្វីដែល<សាក្សី>បានឆ្លើយកាលពីម្សិលមិញ។ <អរគុណ។>

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:៥៧:៤៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ លោកអាចនិយាយបានទេ ថាតើ<បទបញ្ជា>កងទ័ពធម្មតាហ្នឹងយ៉ាងម៉េចដែរ? វាផ្ទុយពីអាមិនធម្មតាហ្នឹងយ៉ាងម៉េច? តើ<បញ្ជាហ្នឹងជាបញ្ជាយ៉ាងម៉េច?>

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ គឺថាមានបញ្ជាយោធាធម្មតាហ្នឹងច្រើនប្រភេទណាស់។ ខ្ញុំគិតថា រាល់ប្រទេសមានសន្តិភាព នាយទាហានជាមធ្យម ទទួលបញ្ជាច្រើនមុខណាស់ក្នុងមួយថ្ងៃៗ មានន័យថាបញ្ជាឲ្យចេញទៅហាត់បាញ់ ឲ្យធ្វើនេះ ធ្វើនោះជាដើម។ ហើយគេក៏យករបៀបនៃបញ្ជានេះមកអនុវត្តនៅក្នុងកងពល ៥០២ដូចគ្នាដែរ។> ដើម្បីឆ្លើយតបទៅនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺថា<គេមិនអាចច្រានចោលបទបញ្ជាផ្សេងៗនោះទេ។> វាអាចជាបញ្ហាក្នុងលក្ខណៈជាកងទ័ព ហើយជួនជាពេលខ្លះវា<ជា>ការបញ្ជា<ជាទម្រង់នៃ>ការដាក់ទណ្ឌកម្ម <តែ វានៅតែជាបញ្ជាកងទ័ពដដែល>។ ដូច្នេះ ខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យសួរ<សំណួរនេះ។ បើមើលតាមទស្សនទានច្បាប់យោធា វាអត់មានអីខុសគ្នារវាងចំណុចទាំងពីរនេះទេ។>

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀត លោក វ៉ិចទ័រ កូប៉េ។ សូមរៀបចំសំណួរចុងក្រោយរបស់លោកសាជាថ្មីព្រោះទំនងជាសាក្សីភ្លេចហើយ។

[១០:០០:០១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំឮសួរពាក្យជាអង់គ្លេសថា “រីប្រេស” ហ្នឹងមានន័យថា វាជាការសួរសាជាថ្មីឡើងវិញ ឬក៏--។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សីនៅពេលមេបញ្ជាការរបស់លោកស្រី បញ្ជាឱ្យលោកស្រីទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង តើជាការបញ្ជារបៀបកងទ័ព ដែលលោកស្រីធ្លាប់បានទទួលជាធម្មតា ឬក៏ធ្លាប់បានទទួលមុនពេលបញ្ជូនលោកស្រីទៅធ្វើការនៅឯព្រលានយន្តហោះកំពង់ឆ្នាំង?

**លោកស្រី ឃិន វ៉ាត៖**

**ឆ៖** ចាស ពេលនោះ ខ្ញុំៗអត់ចាប់អារម្មណ៍ថា ខ្ញុំនៅមានសិទ្ធិជាកងទ័ពទៀតទេ ព្រោះអីខ្ញុំនៅក្នុងស្ត្រីៗគ្រួសារយោធា។ ហើយគេចាត់ចែងឱ្យខ្ញុំទៅ ខ្ញុំរៀបចំអីវ៉ាន់ក៏ទៅៗ ធ្វើស្រែតាមបញ្ជារបស់គេដែរ។

**ស៖** លោកស្រីចង់មានន័យថាម៉េច នៅពេលលោកស្រីនិយាយថា "លោកស្រីលែងនៅជាកងទ័ពទៀតហើយ"? <ខ្ញុំមិនច្បាស់ថាខ្លួនឯងយល់ទេ។ ប្រហែលជាមានបញ្ហាបកប្រែក៏មិនដឹង> សូមលោកស្រីពន្យល់លម្អិតបន្តិចមើល៍ <ថាវាមានន័យថាម៉េច?><>

**ឆ៖** ពេលដែលខ្ញុំបានរៀបចំការជាមួយប្ដីខ្ញុំហើយ ប្ដីខ្ញុំបាត់ខ្លួននោះ ក៏ខ្ញុំចេញពីកន្លែងដាំបាយចិនហ្នឹងហើយ ខ្ញុំទៅនៅកងស្ត្រីធ្វើស្រែនៅអូរបែកក្អម នៅវត្តខាង -- នៅអូរបែកក្អមហ្នឹង ខ្ញុំក៏ថ្ងៃមួយនោះ ឃើញគេឱ្យខ្ញុំរៀបចំអីវ៉ាន់ទៅនៅខាងកំពង់ឆ្នាំងហ្នឹង ខ្ញុំនឹកថា ខ្ញុំគ្មាននៅកងទ័ពទៀតទេ។ ខ្ញុំនៅខាងធ្វើស្រែដូចជាសហករណ៍ ឬក៏មន្ទីរអ្នកធ្វើស្រែសម្រាប់ចិញ្ចឹមកងទ័ពហ្នឹងហើយ ប៉ុន្តែថាដូចជា គ្មានសិទ្ធិ។

[១០:០២:៥៦]

**ស៖** ឥឡូវនេះ ខ្ញុំយល់ហើយលោកស្រី។ ប៉ុន្តែលោកស្រីត្រូវបានគេ<បញ្ឈប់លែង>ឱ្យធ្វើជាកងទ័ពជាផ្លូវការ<មែន>ទេ<?> លោកស្រីមានបានទទួលលិខិតណាមួយ <ឬក៏ការជូនដំណឹងជាផ្លូវការណាមួយ>ថា លោកស្រីលែងនៅជាកងទ័ពជាផ្លូវការតទៅទៀតហើយ<ក្នុង>កងពល៥០២នោះដែរទេ?

**ឆ៖** ចាស ពេលនោះអត់ទេ។ អត់មានទេ។ អត់មានគាត់ប្រាប់អីទេ គ្រាន់តែថា ដកសិទ្ធិខ្ញុំពីដាំបាយចិនហ្នឹង ឱ្យខ្ញុំទៅធ្វើស្រែហ្នឹង ខ្ញុំដឹងថា ខ្លួនខ្ញុំប្រហែលជាអស់សិទ្ធិពេលហ្នឹងហើយ។ ខ្ញុំសន្និដ្ឋានខ្លួនឯងទេ។ ខាងបញ្ជាការហ្នឹង គេអត់មានឱ្យសំបុត្រ ឱ្យអីទេ។ គ្រាន់តែថា ផ្លាស់តំណែងការងារ គេផ្លាស់ឱ្យខ្ញុំទៅនៅស្រែហើយ ឱ្យទៅកំពង់ឆ្នាំងតែប៉ុណ្ណឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅពេលលោកស្រី<បញ្ចប់ការងារ>ធ្វើស្រែឯកំពង់ឆ្នាំង <តើ>លោកស្រីធ្វើអ្វី<បន្ទាប់មកទៀត?>

**ឆ៖** ធ្វើស្រែហ្នឹង ខ្ញុំធ្វើដី។ ខ្ញុំដឹកនាំចាស់ៗហ្នឹង គាត់ប្រាប់ឲ្យមេបញ្ជាការខ្ញុំហ្នឹង ប្រុសហ្នឹង គាត់ប្រាប់ថា ឲ្យនាំចាស់ៗហ្នឹង កម្លាំងខ្សោយហ្នឹង កម្លាំងទី២អីហ្នឹងរកកាប់ទន្រ្ទានខេត្តអីធ្វើជី ចិញ្ច្រាំ។ ពេលថ្ងៃកាប់ទៅ ពេលល្ងាចឡើងចិញ្ច្រាំទៅ សម្រាប់ដាក់ស្រែ សម្រាប់សាបនៅខាងត្បូងវត្តព្រះធាតុហ្នឹង។

**ស៖** នៅពេលលោកស្រីឮស្នូរគ្រាប់កាំភ្លើងវៀតណាមចូលមកឈ្លានពានកម្ពុជានេះ <តើពេលនោះ លោកស្រីនៅទីកន្លែងណា> លោកស្រីនៅនឹកឃើញទេ?

**ឆ៖** ហើយពួកខ្ញុំភ័យណាស់ ច្របូកច្របល់ពេលព្រលាន។ អ្នកខ្លះសម្រាលកូនលើឡាន មិនដឹងបែកគ្នីបែកគ្នាទៅណាទេ ឲ្យតែបានឡានជិះ។ ភ័យថាគ្មានជីវិតរស់នៅទៀតទេ។

[១០:០៦:០៩]

**ស៖** លោកស្រីមានហក់ចូលទៅជិះឡានកងទ័ពដែរទេ នៅពេលដែលលោកស្រីរត់គេចចេញពីកងទ័ពវៀតណាម?

**ឆ៖** ចាស ពេលនោះអ្នកដែលមានកូន អ្នកដែលពោះធំហ្នឹងបានជិះឡានកងទ័ពទៅលិច ហើយខ្ញុំហ្នឹងគេឲ្យជួយគ្រាប់អ្នកសម្រាលហ្នឹងឡើយឡាន ខ្ញុំបានជិះឡានហ្នឹងហើយ។ ហើយកម្លាំងរបស់ខ្ញុំដើរបែកគ្នីបែកគ្នាអស់ត្រឹមហ្នឹង។ មិនដឹងគេទៅណាទៅណីទៀត។

**ស៖** តើលោកស្រីរត់ចេញដោយខ្លួនឯង ឬក៏យ៉ាងណា? លោកស្រីរត់សំដៅទៅទិសខាងលិចដូចគេដូចឯងដែរ ឬក៏យ៉ាងណា?

**ឆ៖** ចាស ខ្ញុំទៅនេះទៅតាមឡានតាមគេតាមឯង។ តាមៗឡានហ្នឹងទៅតាមគេតាមឯងហ្នឹង។

**ស៖** ឡានកងទ័ព ឬក៏មិនមែនទេ?

**ឆ៖** ចាស ឡានហ្នឹងឡានកងទ័ពដែលចិនគាត់ឲ្យមកធ្វើព្រលានហ្នឹងហើយ សម្រាប់បម្រើការព្រលានហ្នឹង។ ដល់ពេលមានអាសន្នអីចឹងទៅ ក៏តែកុងឡានចេះជញ្ជូនមនុស្ស អ្នកណាអាចដើរបានក៏រត់ទៅតាមផ្លូវក្រាំងស្គារ សំដៅទៅឱរ៉ាល់ទៅ អ្នកដែលពោះធំកូនមិនអាចដើរបានឡើងឡានទៅ។

**ស៖** ជាការពិតហើយថា លោកស្រីអាចរត់គេចចេញពីកងទ័ពវៀតណាម <> គឺលោកស្រីរត់ចេញដោយជិះឡានកងទ័ពឬ<> <តើនេះមិនបញ្ជាក់ថាលោកស្រីនៅតែជាសមាជិកកងពល៥០២ទេ

ឬ?><>

[១០:០៨:៣៦]

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំយល់ឃើញថា <>សំណួរនេះ<មានលក្ខណៈជាសំណួរតទល់គ្នា។> ខ្ញុំយល់ឃើញថាសាក្សីមិនៗអាចឆ្លើយបានទេ ហើយក៏គ្មានប្រយោជន៍អ្វីនោះដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំដឹងថា សក្ខីកម្មខ្លះបានយោងទៅលើប្រភពទី២ ប្រភពព័ត៌មានទី២ ថាកងទ័ព <ជាច្រើនមិនពេញចិត្តនឹងការពិតដែលថាពួកគេ>ត្រូវបានគេបញ្ជាឲ្យធ្វើការងារ<គ្រប់យ៉ាង ដែលមិនមែន>ជា<ការងារ>កងទ័ព។ <ហើយនេះអាចជារឿងដែលកើតឡើងចំពោះសាក្សីដូចគ្នា> អ៊ីចឹងឯង <បានខ្ញុំព្យាយាមរកឲ្យឃើញថា គេបញ្ឈប់គាត់ពីការងារមិនមែនដោយសារតែសាក្សីមិនពេញចិត្តនឹងការងារគាត់ធ្វើនោះទេ។>

*(ចៅក្រមពិភាក្សាគ្នា)*

**លោក ត្រាវីស ហ្វារ៖**

លោក លោកស្រីចៅក្រម <ខ្ញុំគិតថា សួរបែបនេះ គឺនៅតែមានលក្ខណៈតទល់គ្នាដដែល។<ខ្ញុំចង់មានន័យថា ចម្លើយយោងដែលមេធាវីការពារក្តីគាត់ចង់បាននោះគឺថា បើសិនជាលោកស្រីសាក្សីគាត់ជិះឡានយោធា បានន័យថាសាក្សីក៏នៅតែជាយោធាដែរនៅពេលនោះ។> <ខ្ញុំគិតថា> គាត់<បាន>ឆ្លើយអ្វីដែលគាត់<អាច>ដឹងយ៉ាងច្បាស់<ហើយអំពីតួនាទីឋានៈជាទាហាន ឬក៏មិនមែនជាទាហានរបស់គាត់នៅពេលនោះរួចហើយ>។ <>

[១០:០៩:៥៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថា ខ្ញុំ<នៅតែ>អាចសួរបាន ដោយសារខ្ញុំគ្រាន់សួរថា តើគាត់នៅតែជាកងទ័ពចំណុះ<កងពល>៥០២ ឬក៏អត់ <ហើយចម្លើយ បើមិន "ចាស" គឺ "ទេ"> ហើយ<ប្រសិនបើចម្លើយគាត់ឆ្លើយថា "ទេ" អ៊ីចឹងខ្ញុំច្បាស់ហើយថាគាត់ឆ្លើយថា "ទេ"។>

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីជាតិ!

**លោក ពេជ អង្គ៖**

បាទ ខ្ញុំសូមបញ្ជាក់បន្តិច។ ខ្ញុំស្ដាប់លោកស្រីសាក្សីនេះគាត់ឆ្លើយ គាត់មិនដែលឆ្លើយថា គាត់មិនមែនជាកងទ័ពទៀតទេ។ ក៏ប៉ុន្តែគាត់បានប្រើពាក្យបីម៉ាត់ដែលមានន័យស្រដៀងគ្នា គាត់ថា គាត់នឹកថាខ្លួនគាត់លែងជា -- នឹកគិតថា ខ្លួនគាត់លែងចាត់ទុកថាទ័ពទៀតហើយ ឬក៏គាត់សន្និដ្ឋានខ្លួនគាត់ថា ខ្លួនគាត់ប្រហែលជាមិនមែនជាទ័ពទៀតហើយ ឬក៏គាត់មានប្រើពាក្យថា គាត់អារម្មណ៍ថា ខ្លួនគាត់ដូចមិនមែនជាទ័ព។ ដូច្នេះគាត់ អានេះគ្រាន់តែជាការគិតរបស់គាត់ទេ ក៏ប៉ុន្តែគាត់មិនបាននិយាយថា គាត់ត្រូវបានចេញពីជួរទ័ពទេ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បដិសេធសេចក្ដីជំទាស់។ មេធាវីអាចសួរបញ្ជាក់ចំណុចនេះឲ្យបានច្បាស់លាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី លោកស្រីទើបតែឆ្លើយថា លោកស្រីរត់គេចចេញពីកងទ័ពវៀតណាមដោយឡើងជិះឡានកងទ័ព។ ដោយស្ដាប់ឮយ៉ាងដូច្នេះ សំណួរខ្ញុំសួរទៅកាន់លោកស្រីហ្នឹង ថានៅពេលនោះ តើលោកស្រីឡើងជិះឡានកងទ័ព <>លោកស្រីនៅតែជាសមាជិកកងទ័ពចំណុះឲ្យកងពល៥០២ដដែល ឬក៏អត់ទេ?

[១០:១១:៥៦]

**លោកស្រី ឃិន វ៉ាត៖**

**ឆ៖** ចាស ពេលនោះខ្ញុំនៅតែនៅក្នុងកងពល៥០២ដដែលហ្នឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នក

ជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ហើយលោកមេធាវីការពារក្តីលោក នួន ជា មានអ្វីដែលចង់បន្តទេ? សូមអញ្ជើញ!

អត់មានទេ។ បាទ សូមអញ្ជើញមេធាវីការពារក្តី លោក ខៀវ សំផន បាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក <លោកស្រី>ចៅក្រម។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** <ជម្រាបសួរ>លោកស្រីសាក្សី។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ អ៊ីចឹងខ្ញុំនឹងសួរសំណួរខ្លីៗ ដើម្បីសុំការបំភ្លឺអំពីលោកស្រី ទាក់ទងទៅនឹងចម្លើយរបស់លោកស្រី។ ចំណុចទី១ នៅក្នុងការបកប្រែជាភាសាបារាំងមិនសូវច្បាស់។ លោកស្រីបាននិយាយថា នៅពេលដែលលោកស្រីបានរៀបការជាមួយប្តីរបស់លោកស្រី <ហើយនៅ>កំពង់ឆ្នាំងមួយអាទិត្យ។ តើលោកស្រីចាំ<កាលបរិច្ឆេទនៃការ>រៀបការនោះ នៅពេលណាដែរ?

[១០:៣២:១១]

**លោកស្រី ឃិន វ៉ាត៖**

**ឆ៖** ចាស ខ្ញុំរៀបការនោះនៅឆ្នាំ៧៧ ប៉ុន្តែអត់ចាំខែទេ។ ឆ្នាំចុងចិត -- ចុងឆ្នាំ៧៧។

**ស៖** ឲ្យច្បាស់លាស់តែម្តង លោកស្រីបាននិយាយថាលោកស្រីត្រូវបានគេចាត់ឲ្យទៅកំពង់ឆ្នាំង <ប្រហែល>នៅចុងឆ្នាំ១៩៧៧។ អ៊ីចឹងបើយើងយកពេលដែលគេចាត់លោកស្រីទៅកំពង់ឆ្នាំងឲ្យធ្វើការ

នៅស្រែ។ តើលោកស្រីអាចផ្តល់រយៈពេលចន្លោះពេលណាមួយបានទេ? គឺថាមួយខែ ពីរខែ <ឬក៏បីខែ>មុនពេលលោកស្រីរៀបការ ឬក៏លោកស្រីអាចផ្តល់កាលវេលាណាមួយច្បាស់លាស់ទេ ដើម្បីឲ្យ<លោកស្រី>កំណត់បានថា តើនៅពេលណាឲ្យពិតប្រាកដនោះ? បើលោកស្រីមិនចាំទេ ខ្ញុំមិនចង់ធ្វើឲ្យលោកស្រីទាល់ច្រកទេ។ គ្រាន់តែចង់សួរលោកស្រីថា តើលោកស្រីត្រូវបានគេចាត់តាំងឲ្យធ្វើការនៅវាលស្រែនោះ គឺក្រោយ ហើយបើក្រោយ ក្រោយរយៈពេលប៉ុន្មានដែរ? ហើយបើសិនជាលោកស្រីមិនចាំទេ <ខ្ញុំក៏មិនចង់ឲ្យលោកស្រីពិបាកដែរ។ តាមលោកស្រីនិយាយ លោកស្រីត្រូវបានគេចាត់តាំងក្រោយមកទៀត តើលោកស្រីមានចាំពីពេលវេលាណាមួយ ឬក៏អត់? បើ>លោកស្រីមិនចាំទេ <គ្រាន់តែឆ្លើយថា>មិនអាចឆ្លើយបានទេ <ទៅបានហើយ>។

**ឆ៖** ចាស ខ្ញុំអត់ចាំ។

**ស៖** អត់បញ្ហាអ្វីទេ។ តែទាក់ទងចំណុចមួយ<ដែលច្បាស់> គឺលោកស្រីបាននិយាយថាក្រោយពីការ<រួចហើយ លោកស្រីបានចំណាយពេល>មួយសប្តាហ៍ <នៅជាមួយនឹងប្តីរបស់លោកស្រី> ខ្ញុំសួរលោកស្រីថា តើក្នុងមួយសប្តាហ៍ហ្នឹង ពេលដែលលោកស្រីរៀបការហើយ នៅជាមួយប្តីលោកស្រីនោះ លោកស្រីធ្វើការនៅចង្ក្រានបាយ<ឬ?> <>

**ឆ៖** ចាស ខ្ញុំនៅជាមួយប្តីខ្ញុំហ្នឹង នៅចង្ក្រានហ្នឹង ពេលថ្ងៃគាត់ទៅធ្វើការទៅ ខ្ញុំនៅដាំបាយកន្លែងបន្ទាយចាន់សារិហ្នឹង។ ពេលយប់ឡើងក៏គាត់មកសម្រាន្តជាមួយគ្នាទៅ រយៈពេល៧ថ្ងៃហ្នឹង។

[១០:៣៥:១៥]

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ លោកស្រីបាននិយាយថា លោកស្រីបានធ្វើការនៅស្រែដែលចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីព្រលានយន្តហោះកំពង់ឆ្នាំង ហើយលោកស្រីបាននិយាយផងដែរថា លោកស្រីបានធ្វើការជាមួយនារីយោធាដែលមកពីភូមិភាគបូព៌ា។ អ៊ីចឹង សំណួរខ្ញុំចង់សួរថា តើលោកស្រីមានមុខងារអ្វីច្បាស់លាស់ដែរឬទេ នៅក្នុង<អង្គភាពហ្នឹង ពេលដែលលោកស្រីធ្វើការនៅវាល>ស្រែហ្នឹង?

**ឆ៖** ចាស ពេលនោះ ខ្ញុំហ្នឹងគាត់ឲ្យខ្ញុំគ្រប់គ្រងប្រពន្ធយោធាហ្នឹង អ្នកកម្លាំងទី២ មានកូនហ្នឹងធ្វើជី ដើរកាប់ទន្រ្ទានខែត្រអី ចិញ្ច្រាំធ្វើជី។ ហ្នឹងខ្ញុំអ្នកនាំមុខពួកគាត់។

**ស៖** អ៊ីចឹងការងារហ្នឹង លោកស្រីធ្វើការងារហ្នឹងតាំងពីពេលទៅដល់ <វាលស្រែដែលនៅជិតព្រលានយន្តហោះកំពង់ឆ្នាំងភ្លាមៗឬ? តើពេលណាដែលគេចាត់តាំងលោកស្រីឲ្យចាប់ផ្តើមការងារ

នេះ?>

**ផ៖** ចាស ទៅដល់ ខ្ញុំសម្រាកនៅកន្លែងខ្ញុំធ្វើការហ្នឹងនៅខាងជើងវត្តព្រះធាតុហ្នឹង អត់នៅយូរទេ។ ទៅដល់បានមួយថ្ងៃក៏គេប្រជុំគ្នាទៅ ក៏គេចាត់ការងារឲ្យខ្ញុំទទួលយាយៗចាស់ៗហ្នឹង កម្លាំងទី២ហ្នឹង ទទួលស្គាល់ខ្ញុំហ្នឹងហើយអ្នកដឹកនាំធ្វើជី ចាស។

**ស៖** អ៊ីចឹង<>បានន័យថា លោកស្រីមានសិទ្ធិអំណាចលើស្ត្រីទាំងអស់ដែលធ្វើការនៅក្នុងកងហ្នឹង ឬក៏យ៉ាងណា?

**ផ៖** ចាស ពេលនោះខ្ញុំទទួលផែនការពីប្រធានខ្ញុំមួយទៀត គាត់បុរស។ គាត់ប្រាប់ខ្ញុំឲ្យនាំកម្លាំងហ្នឹងធ្វើ ខ្ញុំទទួលពីគាត់ ហើយក៏នាំកម្លាំងគ្រួសារយោធាហ្នឹង អ្នកមានកូន អ្នកកម្លាំងទី២ហ្នឹងធ្វើ។ ខ្ញុំហ្នឹងហើយអ្នកនាំគាត់ធ្វើ។

[១០:៣៩:០៥]

**ស៖** ឥឡូវខ្ញុំសូមចូលនិយាយចំណុចមួយទៀត។ តើលោកស្រីចាំដែរទេថា នៅក្នុងឆ្នាំ១៩៧៧ដែលលោកស្រីធ្វើការនៅ<វាលស្រែ តើមានយោធាមកពីកងពល៥០២> ឬក៏កងពលផ្សេងទៀត<> ត្រូវបានគេបញ្ជូនទៅប្រយុទ្ធជាមួយវៀតណាម <ប្រសិនបើលោកស្រីស្គាល់ពួកយោធាទាំងនោះ តើលោកស្រីចាំពីរឿងនេះដែរទេ>?

**ផ៖** ចាស ខ្ញុំដឹងពេលហ្នឹង ខ្ញុំអត់ដឹងថា បានទៅប្រយុទ្ធជាមួយវៀតណាមទេ។ ដឹងតែថានៅធ្វើព្រលានជាមួយចិន អ្នកទាំងអស់គ្នាហ្នឹង។ ឯអ្នកប្រយុទ្ធជាមួយវៀតណាមហ្នឹង គឺខ្ញុំអត់ដឹង។

**ស៖** លោកស្រីបានឆ្លើយថា ជាច្រើនដងថា លោកស្រីនៅធ្វើស្រែជិតព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងរយៈពេលខ្លីទេ។ តើលោកស្រីចាំទេថា លោកស្រីធ្វើការនៅស្រែនោះ រយៈពេលប៉ុន្មានដែរ? ព្រោះបើតាមខ្ញុំ<កត់ត្រា ឃើញ> ថាលោកស្រីធ្វើការនៅទីនោះ៦ខែ <តែខ្ញុំអត់ច្បាស់ទេ ហើយចង់ឲ្យលោកស្រីជួយបញ្ជាក់>។ <> តើលោកស្រីចាំទេ ថាធ្វើការនៅទីនោះរយៈពេល<ប្រហែលជា>ប៉ុន្មាន<ខែ>ដែរ?

**ផ៖** ចាស ខ្ញុំចាំបានត្រឹមថា ពេលនោះខ្ញុំសាបស្រូវ សាបស្រូវហើយ ស្ទូងស្រូវហ្នឹងមិនទាន់បានច្រូតទេ។ មិនទាន់បានច្រូត ក៏ពួកខ្ញុំរត់ចោលស្រូវហ្នឹងទៅ។ ខ្ញុំចាំបានអ៊ីចឹង។

**ស៖** ខ្ញុំយល់តាមរយៈចម្លើយរបស់លោកស្រីហ្នឹង គឺថាលោកស្រីបានរត់ចេញទៅហ្នឹងមុនពេលច្រូតស្រូវ។ លោកស្រីនិយាយអ៊ីចឹងមែនទេអំមិញហ្នឹង?

**ឆ៖** ចាស ខ្ញុំនិយាយអ៊ីចឹងហើយ ប៉ុន្តែ--។

[១០:៤១:៤៩]

**ស៖** លោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាគេច្រូតស្រូវនោះ នៅខែណាដែរ?

**ឆ៖** គេច្រូតខែ១២។

**ស៖** លោកស្រីបាននិយាយកាលពីព្រឹកមិញ អំពីការធ្វើអត្តឃាត <ហើយសហភាតារបស់ខ្ញុំម្តងទៀតកាលពីព្រឹកមិញនេះ>ដែលអ្នកបើកបរឡានម្នាក់បាន<បានរាយការណ៍ជូនលោកស្រី ដោយលោកស្រីបាននិយាយកាលពីម្សិលមិញ>។ អ៊ីចឹងលោកស្រី<នៅ>ចាំឈ្មោះអ្នកបើកបរឡាន<ដែលនិយាយរឿងធ្វើអត្តឃាត>ហ្នឹងទេ? <>

**ឆ៖** ចាស ខ្ញុំអត់ស្គាល់ទេ។ ខ្ញុំគ្រាន់តែ គេសម្រាកហើយគេនិយាយគ្នាទេ និយាយគ្នាគេ ហើយខ្ញុំស្តាប់ឮ ខ្ញុំអត់បានសួរដេញដោលអីទេ។ ហើយខ្ញុំអត់បានស្គាល់ឈ្មោះ។ ខ្ញុំគ្រាន់តែឮគាត់និយាយគ្នា។

**ស៖** ឥឡូវខ្ញុំចូលទៅនិយាយអំពីអ្វីដែលលោកស្រីបានលើកឡើងកាលពីម្សិលមិញ ទាក់ទងទៅនឹងទស្សនកិច្ចរបស់លោក ខៀវ សំផន។ លោកស្រីបាននិយាយថា លោកស្រីផ្ទាល់នោះ មិនបានឃើញគាត់ទេ ក៏ប៉ុន្តែមិត្តភក្តិលោកស្រីម្នាក់បាននិយាយប្រាប់ពីរឿងទស្សនកិច្ចរបស់លោក ខៀវ សំផន នេះ។ តើបុគ្គលនោះជាប្រុស ឬស្រី ហើយឈ្មោះអ្វីដែរ?

**ឆ៖** ចាស គាត់ប្រុស។ គាត់ឈ្មោះ សុគន្ធ។ គាត់នៅធ្វើការជាមួយចិនខាងវាស់ស្ទង់ផ្លូវ គាត់និយាយប្រាប់ខ្ញុំ។

[១០:៤៤:២៤]

**ស៖** តើលោកស្រីដឹងទេ ថាគាត់ធ្វើការងារអ្វីដែរ ឈ្មោះ សុគន្ធ ហ្នឹង?

**ឆ៖** គាត់នៅកងទ័ព៥០២ហ្នឹង ហើយគាត់ដើរធ្វើផ្លូវជាមួយ កាន់កែវវាស់ស្ទង់ជាមួយចិនហ្នឹងគាត់ធ្វើផ្លូវ។

**ស៖** <>ខ្ញុំដឹងថារយៈពេលនោះវាកន្លងផុតយូរទៅហើយ ហើយអ៊ីចឹងខ្ញុំចង់សួរថា <តើលោកស្រីនៅចាំសម្តីផ្ទាល់ដែលគាត់ប្រើទេ នៅពេលគាត់និយាយពីដំណើរទស្សនកិច្ចរបស់ ខៀវ សំផន?>

**ឆ៖** ចាស ពេលនោះខ្ញុំអត់ចាំទេ។ តែក្រោយមកនោះដូចជាខ្ញុំចាំបានថា គេបើកសិទ្ធិឱ្យកងទ័ពនៅហ្នឹងបានមើលកុន។ ហើយពេលយប់ បើការងារហ្នឹងបន្ទះព្រលានហ្នឹង គេឱ្យសិទ្ធិកងទ័ពហ្នឹងសម្រាកថ្ងៃអាទិត្យ។ នេះខ្ញុំបានឮមិត្តភក្តិខ្ញុំនិយាយចចាមអារ៉ាមគ្នាអ៊ីចឹង ថាយើងខំធ្វើការទៅបន្តិចទៀត

យើងមានរបបធូរធារហើយ។ ខ្ញុំបាននៅចាំពេលហ្នឹង ក៏ខ្ញុំបានទៅចូលមើលកុនដែរនៅបញ្ចាំងនៅពេលយប់នៅផ្ទះប្រាំជាន់ហ្នឹង។

**ស៖** តើលោកដឹងដែរឬទេ ថានៅក្នុងពេលនៅរបបខ្មែរក្រហម កម្ពុជាប្រជាធិបតេយ្យហ្នឹង សួរថា អ្នកណាជា<សេនាធិការនៅពេលនោះ គឺ> អគ្គៗមេបញ្ជាការកងទ័ពហ្នឹង ឈ្មោះអ្វីដែរនៅរបបកម្ពុជាប្រជាធិបតេយ្យ លោកស្រីដឹងទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ដឹង ខ្ញុំអត់ស្គាល់ទេ ថ្នាក់លើខ្ញុំអត់សូវស្គាល់ អត់ដឹងទេ។

**ស៖** តើលោកស្រីស្គាល់ឈ្មោះ សុន សេន ទេ?

**ឆ៖** ចាស ខ្ញុំឮឈ្មោះគាត់ដែរ។ ឮឈ្មោះគាត់ តែខ្ញុំអត់ដែលស្គាល់មុខគាត់ ហើយអត់ដឹងជាតួនាទី។ តែឮតែគាត់ -- ឮតែឈ្មោះ។

[១០:៤៨:០០]

**ស៖** តើលោកស្រីស្គាល់ឈ្មោះបដិវត្តន៍គាត់ទេ?

**ឆ៖** អត់ស្គាល់ផង។

**ស៖** តើលោកស្រីស្គាល់ឈ្មោះបដិវត្តន៍របស់លោកខៀវ សំផន ដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់ស្គាល់ អត់ចាំបានទេ អត់ស្គាល់ទេ។

**ស៖** អង្កាល់ពីម្សិលមិញលោកស្រីបាននិយាយថា មានមនុស្សម្នាក់ដែលបានបញ្ជាក់ប្រាប់លោកស្រីថា គេហៅ ខៀវ សំផន "អ៊ំលេខ២"។ តើលោកស្រីមានឮបុគ្គលរូបនោះៗនិយាយប្រាប់លោកស្រីពីឈ្មោះអ៊ំផ្សេងទៀត ក្រៅពីអ៊ំទី២ ឬក៏លេខ២នេះដែរឬទេ?

**ឆ៖** ចាស ខ្ញុំដឹង ខ្ញុំឮតែគេហៅគាត់ "អ៊ំទី២" ហ្នឹង ខ្ញុំដឹងតែប៉ុណ្ណឹង អត់ស្គាល់ទៀតៗទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកស្រីសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយៗសហភាតារបស់ខ្ញុំ គឺលោកមេធាវី គង់ សំអុន គាត់សូមសួរបន្តទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១០:៤៩:៥៨]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកស្រី ឃិន វ៉ាត! ខ្ញុំមានសំណួរខ្លីទេ ទាក់ទងទៅនឹងពេលវេលាដែលអ្នកស្រីទៅធ្វើការនៅវាលស្រែខេត្តកំពង់ឆ្នាំង។ អ្នកស្រីបានជម្រាបខាងដើមថា អ្នកស្រីបានទៅរៀបការនៅឆ្នាំ១៩៧៧ ប៉ុន្តែអ្នកស្រីមិនបានដឹងថាក្នុងខែណាទេ។ ហើយអង្គហេតុមួយទៀត ដែលអ្នកស្រីបានជម្រាបនោះ គឺថាអ្នកស្រីបានរស់នៅ ធ្វើការនៅវាលស្រែជិតព្រលានខេត្តកំពង់ឆ្នាំងហ្នឹង គឺក្នុងរយៈពេលតិចជាង៦ខែ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់សួរអ្នកស្រីថា ពេលវេលាចុងក្រោយដែលអ្នកស្រីចាកចេញពីវាលស្រែខេត្តកំពង់ឆ្នាំង--

**លោក គ្រាវីស ហ្សារ៖**

លោកប្រធាន ខ្ញុំមិនចាំថា សាក្សីនិយាយថា គាត់ធ្វើ<នៅទីនោះ>រយៈពេល<តិចជាង>៦ខែនោះឡើយ<បើមានឯកសារយោងគឺប្រសើរណាស់>។ <ខ្ញុំក៏ដឹងដែរថា>មេធាវី អង់តា ហ្គីសសេ ក៏បានកត់ត្រាចំណុចនេះ ប៉ុន្តែខ្ញុំអត់ចាំថា សាក្សីបាននិយាយពាក្យនេះទេ ។<>

**លោក គង់ សំអុន៖**

លោកប្រធាន ពីម្សិលមិញខ្ញុំអាចឆែករកនៅក្នុងនេះបាន ក៏ប៉ុន្តែឥឡូវនេះខ្ញុំអត់មានទេ ដោយសារខ្ញុំកត់នៅក្នុងកំណត់ដៃរបស់ខ្ញុំ។ សាក្សីគាត់បានឆ្លើយ គឺគាត់ឆ្លើយបញ្ជាក់ថា គាត់ – តាមគាត់ចាំ គាត់នៅធ្វើការនៅវាលស្រែព្រលាន ក្បែរព្រលានខេត្តកំពង់ឆ្នាំងហ្នឹង មិនលើសពី៦ខែទេ បាទ។ សាក្សីអាចបញ្ជាក់បាននូវចំណុចនេះបាទ។

[១០:៥១:៤២]

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកស្រីអាចបញ្ជាក់ពីរយៈពេល ដែលអ្នកស្រីធ្វើការនៅវាលស្រែខេត្តកំពង់ឆ្នាំងជិតព្រលានហ្នឹង អ្នកស្រីអាចបញ្ជាក់បានទេ?--

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាវាមាននៅក្នុងប្រតិចារឹកអង់គ្លេស <គឺរយៈពេលប្រាំមួយខែ>។

**លោក គ្រាវីស ហ្សារ៖**

តើលោកអាចផ្តល់លេខទំព័ររបស់ប្រតិចារឹកនុ៎ងបានទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

មុនម៉ោងដប់ប្រាំ សាមសិបប្រាំពីរនាទី<បន្តិច> ម្សិលមិញ។ <សូមអរគុណក្រុមការងាររបស់ខ្ញុំដែលធ្វើការបានលឿន។>

**លោក គង់ សំអុន៖**

បាទ ខ្ញុំអាចបន្តទៀតបានលោកប្រធាន?

បាទ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ៊ីចឹងខ្ញុំចង់ត្រឡប់ទៅសំណួរដើមរបស់ខ្ញុំវិញ។ សូមលោកស្រីបញ្ជាក់បន្ថែមឲ្យច្បាស់ ពីព្រោះអ្នកស្រីបានបញ្ជាក់រួចហើយថា អ្នកស្រីបានចាកចេញពីខេត្តកំពង់ឆ្នាំងហ្នឹង ដោយឡើងជិះឡាន យោធា ហើយនៅពេលដែលមានកងទ័ពវៀតណាមវ៉ៃចូលមក។ តើអ្នកស្រីអាចបញ្ជាក់ថា នៅពេល នោះ គឺជាចុងឆ្នាំ១៩៧៨ ឬក៏ដើមឆ្នាំ១៩៧៩ អ្នកស្រីអាចបញ្ជាក់បានទេ?

**លោកស្រី ឃិន វ៉ាត៖**

**ឆ៖** ចាស ឆ្នាំខ្ញុំរត់ហ្នឹង មែនហើយខ្ញុំចាំថា៧៩។

[១០:៥៣:៣២]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងពេលវេលាមួយទៀតដែលអ្នកស្រីបានបញ្ជាក់ដោយ ប្រៀបធៀបទៅលើពេលវេលាដែលអ្នកស្រីធ្វើស្រែ ថាអ្នកស្រីបាន – នៅពេលអ្នកស្រីទៅដល់ អ្នកស្រី បានចាប់ផ្ដើមសាបស្រូវ ហើយស្រូវនោះមិនទាន់បានច្រូតទេ អ្នកស្រីក៏បានចាកចេញទៅ។ អ្នកស្រីអាច បញ្ជាក់បានទេថា ស្រូវដែលអ្នកស្រីធ្វើនៅពេលនោះ ជាប្រភេទស្រូវអីដែរ?

**ឆ៖** ចាស ស្រូវខ្ញុំធ្វើហ្នឹង គេហៅស្រូវធ្ងន់ ស្រូវហ្នឹងរយៈពេល៦ខែ។

**ស៖** បាទ សូមអរគុណ។ បើអ៊ីចឹងខ្ញុំអាចនិយាយថា នៅពេលដែលអ្នកស្រីទៅកំពង់ឆ្នាំង គឺនៅ ក្នុងអាចពាក់កណ្ដាលឆ្នាំ១៩៧៨។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ប្រហែលជាអ៊ីចឹងហើយ។ ខ្ញុំអាចច្រឡំឆ្នាំ ព្រោះខ្ញុំភ្លេចច្រើន។

**លោក គង់ សំអុន៖**

បាទ អរគុណលោកស្រីសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ការស្ដាប់សក្ខីកម្មរបស់លោកស្រី ឃិន វ៉ាត បានដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះសូមអរគុណលោកស្រី ឃិន វ៉ាត ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ គឺថ្ងៃម្សិលមិញមួយរសៀល ហើយនិងព្រឹកថ្ងៃនេះ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ បានសេចក្ដីសុខសេចក្ដីចម្រើន។

[១០:៥៦:០០]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី ឃិន វ៉ាត ត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលគាត់មានបំណងទៅចង់ទៅបានហើយ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-926 ពាក់ព័ន្ធនឹងការដ្ឋានទំនប់១មករា។ ហើយអង្គជំនុំជម្រះសូមជម្រាបថា ការស្ដាប់សក្ខីកម្មសាក្សី 2-TCW-926 ប្រសិនបើធ្វើសវនាការនៅរសៀលនេះមិនចប់ទេនោះ អង្គជំនុំជម្រះនឹងកោះហៅគាត់មកបន្តផ្ដល់សក្ខីកម្មនាពេលខាងមុខ សមស្របនាពេលខាងមុខទៀត។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-926 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:៥៨:២០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំៈ**

**សៈ** សួរស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក អ៊ុំ ជីៈ**

**ឆៈ** បាទ ខ្ញុំបាទឈ្មោះ អ៊ុំ ជី។

**សៈ** អរគុណលោក អ៊ុំ ជី។ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ ថាលោកកើតនៅ

ថ្ងៃខែឆ្នាំណា? លោកៗកុំអាលទាន់ឆ្លើយតប! រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាភ្លើងក្រហមជាមុនសិនណ៎ា។

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៥២។

**ស៖** អរគុណ។ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះអំពីទីកន្លែងកំណើតរបស់លោកបានដែរឬទេ? តើលោកកើតនៅថ្ងៃ នៅទីកន្លែងណា? កុំអាលទាន់ឆ្លើយតប! គិតបន្តិចសិន យកគិតសិន ដើម្បីឆ្លើយតបឲ្យបានត្រូវ។ ការគិតរបស់យើង នឹងនាំឲ្យមានពេលវេលាសមស្របសម្រាប់ទុកពេលវេលាក្នុងការបកប្រែភាសាទៅជាភាសាពីរទៀត ព្រោះនៅក្នុង អ.វ.ត.ក នេះប្រើប្រាស់បីភាសា។ ដើម្បីឲ្យប្រព័ន្ធសំឡេងរបស់លោកហ្នឹង គឺចែកចាយទៅលើប្រព័ន្ធសំឡេងសម្រាប់ភាគី សម្រាប់អង្គភាពគាំពារ -- អង្គភាពបកប្រែភាសាផ្ទាល់មាត់ ហើយនិងសាធារណជនផង។

**ឆ៖** ខ្ញុំបាទ កើតនៅភូមិជ័យមង្គល ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

[១០:៥៩:៥៦]

**ស៖** ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បច្ចុប្បន្នខ្ញុំនៅភូមិយាយទៀង ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**ស៖** អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ អ៊ុំ ជុន, ម្ដាយឈ្មោះ ប៊ុន ស៊ុន និងប្រពន្ធឈ្មោះ ហ៊ិន វុធ កូនប្រាំមួយនាក់។

**ស៖** បាទ អរគុណ។ ហើយលោក អ៊ុំ ជី តាមសមត្ថភាពដែលលោកអាចដឹង តើលោកមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលអង្គជំនុំជម្រះបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២ នេះដែរឬទេ?

**ឆ៖** ខ្ញុំបាទមិនជាប់ពាក់ព័ន្ធនឹងជនជាប់ចោទ និងជនបណ្ដឹងរដ្ឋប្បវេណីទេ។

**ស៖** អរគុណ។ ហើយតើលោកបានស្បថចំពោះមុខអ្នកតាដំបងដែកនៃ អ.វ.ត.ក ហើយឬនៅមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** ខ្ញុំបានស្បថរួចហើយ។

**ស៖** បាទ អរគុណលោក អ៊ុំ ជី។ ជាតទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬឲ្យលោកធ្វើការអត្ថាធិប្បាយណា

មួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនប្រឆាំងធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[១១:០១:៥១]

អំពីករណីយកិច្ច ក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប របស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិអម្បាញ់មិញនេះរួចហើយ។ ហើយក្នុងឋានៈជាសាក្សីលោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក អុំ ជី តើលោកដែលធ្លាប់ផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើ ប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណា?

**ឆ៖** ខ្ញុំបាទ កាលពីឆ្នាំ២០០៩ មន្ត្រីអង្គការ អ.វ.ត.ក នេះបានទៅចុះទៅសម្ភាសខ្ញុំនៅភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ វេលាម៉ោងដប់។

**សៈ** អរគុណ។ ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះ តើលោក អុំ ជី បានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលផ្តល់សក្ខីកម្មកាលពីពេលមុននោះ ជាមួយនឹងអ្នកស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរទេ?

**ឆ៖** បាទ ខ្ញុំបានអានខ្លះ មិនវា -- ភ្លេចភ្លាំងខ្លះដែរ ពីព្រោះវាយូរវាយាំង ៤០ឆ្នាំទៅហើយ។ វា -- បាទ។

**សៈ** ឥឡូវពិនិត្យមើលការដែលលោកបានអានខ្លះហ្នឹង តាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំ ថាតើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំគឺវាជាពិតជាត្រឹមត្រូវ ឬវាស៊ីចង្វាក់ស្របគ្នាទៅនឹងចម្លើយដែលលោកបានធ្វើកិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីពេលមុន ដែលលោកថា ធ្វើនៅទីកន្លែងដែលរស់នៅសព្វថ្ងៃកាលពីឆ្នាំ ២០០៩ នោះដែរឬទេ?

[១១:០៤:២៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំបានអានឯកសារនេះ ពីបញ្ហាដែលជនជាប់ចោទ និងជនរងគ្រោះ ឃើញថាបានមិនសូវជាច្បាស់លាស់ប៉ុន្មានទេ ប៉ុនថាវាអាចចាំខ្លះ មិនចាំខ្លះ អីចឹងណ៎ា។

**ស៖** យើងចង់ដឹងថា គ្រាន់តែវាស្របគ្នា បានន័យថាខ្លឹមសារនៃឯកសារដែលលោកបានអានថ្មីៗនេះ ធៀបជាមួយនឹងអ្វីដែលលោកបានផ្តល់សក្ខីកម្មជាមួយនឹងអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៩ នៅទីកន្លែងដែលលោករស់នៅខេត្តកំពង់ធំនុំង តើវាប្រហាក់ប្រហែលគ្នា ឬក៏វាស្របគ្នាដែរឬទេ? ឬក៏វាខុសគ្នា?

**ឆ៖** ឯកសារដែលខ្ញុំបានអាន គឺស្របនឹងដែលកាលមន្ត្រីអង្គការ អ.វ.ត.ក នេះទៅៗសម្ភាសជាមួយខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា សួរដេញដោលសាក្សី អ៊ុំ ជី មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃសវនាការ ក្នុងការសួរសាក្សីរូបនេះ។ ហើយបើអាចបន្ថយ បង្រួមពេលវេលានេះបាន ល្អ ព្រោះទំនងជាបើសិនជាប្រឹងប្រែង ក្រែងលោបានចប់នៅរសៀលនេះ ចំពោះការស្តាប់សក្ខីកម្មសាក្សីរូបនេះ ពីព្រោះគាត់មានមមាញឹកនៅក្នុងមុខរបររបស់គាត់ ពិបាកនឹងមកផ្តល់សក្ខីកម្ម។

សូមអញ្ជើញ បាទ!

[១១:០៦:០៨]

**លោក សេង លាង៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** ជាបឋម ខ្ញុំបាទសូមជម្រាបសួរលោកសាក្សី។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហ-ព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។ ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនចង់ចោទសួរទៅ

លោកសាក្សី។ សំណួរមុនដំបូងរបស់ខ្ញុំ គឺចង់ឲ្យលោកសាក្សីជួយបញ្ជាក់ថា តើនៅពេលណាដែល លោកត្រូវបានគេចាត់តាំងឲ្យទៅលើកប្រឡាយដែលតភ្ជាប់ជាមួយទំនប់១មករា?

**លោក អ៊ុំ ជី៖**

**ឆ៖** ដែលខ្ញុំបាទបានគេចាត់តាំងឲ្យទៅធ្វើទំនប់តភ្ជាប់ពី១មករា គឺនៅក្នុងឆ្នាំ១៩៧៨។

**ស៖** នៅក្នុងខែណាដែរ លោកចាំដែរទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោក អ៊ុំ ជី!

[១១:០៧:៣១]

**លោក អ៊ុំ ជី៖**

**ឆ៖** ចុះធ្វើនៅក្នុងខែ២។

**សួរដោយលោក សេង លាង៖**

**ស៖** ពេលហ្នឹង តើលោកមានតួនាទីអ្វីដែរ អាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំនៅពេលនោះ គេចាត់តាំងឲ្យទៅ ខ្ញុំជាប្រធានកងចល័ត។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ នៅក្រោមការគ្រប់គ្រងរបស់លោក?

**ឆ៖** ពេលនោះដែលគេប្រមូលប្រជាជនទៅឲ្យធ្វើប្រឡាយនោះ តាមភូមិទាំងអស់ក្នុងឃុំហ្នឹង ចំនួន៥០០នាក់។

**ស៖** នៅពេលដែលលោកទៅដល់ការដ្ឋានការងាររបស់លោក តើទំនប់១មករាហ្នឹង សាងសង់រួចហើយ ឬក៏នៅ?

**ឆ៖** ទំនប់១មករា គេសាងសង់រួចហើយ។

**ស៖** តើការដ្ឋានប្រឡាយដែលក្រុមរបស់លោកជីកនោះ គឺជាផ្នែកមួយរបស់ការដ្ឋានទំនប់ ១មករា ឬក៏គម្រោងផ្សេងពីរដាច់ដោយឡែកពីគ្នា?

**ឆ៖** ទំនប់នោះ ធ្វើតៗភ្ជាប់ពីទំនប់ ១មករា។

[១១:០៨:១៩]

**ស៖** តើលោកអាចប៉ាន់ស្មានបានទេថា មានមនុស្សប៉ុន្មាននាក់ចូលរួមក្នុងការលើកទំនប់តភ្ជាប់

ជាមួយនឹងទំនប់ ១មករាហ្នឹង?

**ឆ៖** ពីព្រោះដែលគេបើកវគ្គធ្វើទំនប់ហ្នឹង គឺជាទំនប់របស់តំបន់ មនុស្សប្រហែលជា៥ទៅ ៦.០០០នាក់ក្នុងហ្នឹង។

**ស៖** លោកអាចបញ្ជាក់អំពីទីតាំងប្រឡាយហ្នឹងបានទេ?

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយតប!

**លោក អ៊ុំ ជី៖**

**ឆ៖** ទីតាំងប្រឡាយនោះ ធ្វើភ្ជាប់នៅក្នុងឃុំចុងដូង និងឃុំបល្ល័ង្ក។

**សួរដោយលោក សេង លាង៖**

**ស៖** អម្បាញ់មិញ លោកបានមានប្រសាសន៍ថា មានមនុស្សប្រហែលជា ៥ ទៅ ៦០០០នាក់មកលើកទំនប់តភ្ជាប់នេះ។ តើប្រជាជនទាំងអស់ដែលមកធ្វើការនៅការដ្ឋាននេះ គាត់មកដោយស្ម័គ្រចិត្ត ឬក៏ត្រូវគេចាត់ឱ្យទៅ?

**ឆ៖** ការចុះធ្វើប្រឡាយនេះ គឺគ្មានអ្នកណាម្នាក់ស្ម័គ្រចិត្តទេ ប៉ុន្តែខ្លួននៅក្នុងរបបហ្នឹង គឺគេបង្ខំឱ្យទៅធ្វើ។

[១១:១១:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទៅលើចំណុចនេះទេ ប៉ុន្តែខ្ញុំចង់លើកយកចំណុចមួយ គឺទាក់ទងទៅនឹងយុត្តាធិការ ឬក៏យើងអាចនិយាយថា សំណួរដែលសួរអំពីវិសាលភាពនោះ។<>សាក្សីគាត់មិនដែលធ្វើការនៅទំនប់១មករាទេ ហើយយោងទៅតាមដីកាដំណោះស្រាយ ទំនប់១មករា បានបញ្ចប់<កៀក១នឹង>ពេលដែលគេកសាងទំនប់៦មករា។ ទោះបីថាការដ្ឋានទាំងពីរភ្ជាប់ជាមួយគ្នា គឺការដ្ឋានទំនប់៦មករាភ្ជាប់ជាមួយនឹង១មករា ប៉ុន្តែគម្រោងនេះ គឺជាគម្រោងពីរដាច់ផ្សេងពីគ្នា <ពេលវេលាខុសគ្នា>។ ដូច្នេះសំណួរដែលសួរថាតើសក្ខីកម្ម <របស់គាត់ស្ថិតក្នុងវិសាលភាពនៃវគ្គសវនាការជាក់លាក់ ឬក៏អត់នោះ។> យើងគិតថា វាមិនទាក់ទងនោះទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់នៅក្នុងសវនាការនេះ។ <ខ្ញុំគិតថា ការជំទាស់នេះ> ដូចជាមិនមានមូលដ្ឋានត្រឹមត្រូវទេ។ ឧទាហរណ៍ បើយើងមើលកថាខណ្ឌ៣៥២នៃដីកាដំណោះស្រាយ គឺមានបញ្ជាក់ច្បាស់ថា មានការជីកប្រឡាយ<ច្រើនខ្សែ>ដើម្បីនាំទឹកពីទំនប់ទៅកាន់ស្រែ។ <មានឯកសារយោងមួយ>និយាយអំពីប្រឡាយមេ<ហើយខ្ញុំគិតថាយើងក៏កំពុងជជែកគ្នាពីប្រឡាយមេ>ដែលឆ្ពោះទៅកាន់ផ្នែកខាងត្បូង<ដែរ>។ <ប្រឡាយទាំងអស់ហ្នឹងបូកបញ្ចូលគ្នា វាបង្កើតបានទៅជា<>ការដ្ឋានសាងសង់ទំនប់១មករានេះ។ ហើយ<>ក៏មានទំនប់៦មករាផងដែរ ហើយយើងឃើញថា ប្រសិនបើអត់មានប្រឡាយ<ទាំងអស់ហ្នឹង>ទេ គឺទំនប់ហ្នឹងគឺអត់អាចប្រើប្រាស់អីបានទេ គឺថាគោលដៅនៃការធ្វើទំនប់ហ្នឹង គឺថាដើម្បីស្រោចទឹកទៅដល់ស្រែ<នៅជុំវិញហ្នឹង>។ ដូច្នេះខ្ញុំគិតថា<សក្ខីកម្មរបស់សាក្សីវាមានភាពពាក់ព័ន្ធ> វាស្ថិតនៅក្នុងវិសាលភាព<នៃវគ្គសវនាការ> ហើយក៏វាមានចែងនៅក្នុងដីកាដំណោះស្រាយផងដែរ។ សូមអរគុណ។

[១១:១៣:២៩]

**កញ្ញា អង់តា ហ្គីសេ៖**

លោកប្រធាន ខ្ញុំសូមធ្វើអន្តរាគមន៍។ ខ្ញុំឮសហព្រះរាជអាជ្ញា គាត់និយាយថា ហាក់ដូចជាមានការនិយាយអំពីប្រឡាយខាងត្បូង។ ក៏ប៉ុន្តែមុននឹងអង្គជំនុំជម្រះសម្រេចលើបញ្ហានេះ សហព្រះរាជអាជ្ញាគួរតែសួរសំណួរបឋមៗ<មុន>សិន ដើម្បីកំណត់អំពីទីតាំងភូមិសាស្ត្រ<ណា> ដែលយើងកំពុងតែនិយាយ ដើម្បីឱ្យដឹងថាតើ<> វាមានការ<ភ្ជាប់>គ្នា<>ទៅនឹងទំនប់<១>មករា<ឬក៏អត់?> អ៊ីចឹងគួរតែសួរសំណួរបឋមៗសិន មិនគួរណាសួរសំណួរហ្នឹងភ្លាម<><ហើយព្រះរាជអាជ្ញាឡើងមកការពារអ៊ីចឹងទេ។>

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

<ឆ្លើយតបនឹង>ចំណុចនេះ លោកប្រធាន សាក្សីទើបតែនិយាយថា <ការដ្ឋានប្រឡាយ>ដែលគាត់ធ្វើហ្នឹង គឺស្ថិតនៅ<ចន្លោះ>ភូមិចុងដូង ហើយនិងបារាយណ៍។ អ៊ីចឹងបើយើងមើលផែនទី<ក្នុងពេលនោះ>ទៅ យើងឃើញថាទីតាំងហ្នឹងវាស្ថិតនៅខាងត្បូង<ត្រង់>ទំនប់១មករាហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវការជំទាស់របស់មេធាវីការពារក្តីចំពោះអង្គហេតុនេះ ព្រោះនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្នុងអង្គហេតុនេះ ក៏ជាវិសាលភាពពាក់ព័ន្ធជាមួយនឹងការដ្ឋានទំនប់១មករាផងដែរ ហើយវាមាននៅក្នុងដីកាដំណោះស្រាយ ដូចបញ្ជាក់ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញ!

[១១:១៥:១០]

**លោក សេង លាង៖**

អរគុណលោកប្រធាន។ ខ្ញុំសូមរៀបចំសំណួរឡើងវិញ។

**សួរដោយលោក សេង លាង៖**

**ស៖** លោកបានបញ្ជាក់ថា មានមនុស្សប្រហែលជា ៥ទៅ ៦០០០នាក់លើកប្រឡាយតភ្ជាប់ទៅនឹងប្រឡាយទំនប់១មករាហ្នឹង។ ខ្ញុំចង់សួរលោកថាតើក្នុងចំណោមអ្នកដែលទៅធ្វើការទាំងអស់ហ្នឹង ពួកគេស្ម័គ្រចិត្តទៅ ឬក៏ពួកគេតម្រូវឲ្យទៅដោយខានមិនបាន?

**លោក អ៊ុំ ជី៖**

**ឆ៖** ក្នុងការធ្វើទំនប់នេះ គឺគេតម្រូវឲ្យទៅ គឺគ្មានជនណាម្នាក់ស្ម័គ្រចិត្តចង់ទៅធ្វើ។ គឺថាមិនទៅ គឺមិនបានតែម្តងកាលពីសម័យហ្នឹង។

**ស៖** តើពួកគេមិនហ៊ានបដិសេធ ឬក៏ពួកគេមិនចង់បដិសេធក្នុងការមិនទៅ? លោកអាចបញ្ជាក់បានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១១:១៦:១៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគួរតែជំទាស់ទៅនឹងសំណួរតាំងពីមុននេះម្ល៉េះ ព្រោះសាក្សីគាត់មិនអាចឆ្លើយ<អំពី>អ្វី<ដែលមាននៅក្នុង>ចិត្តគំនិតរបស់កម្មករ<ទាំង>ប្រាំពាន់នាក់<>នោះបាន<>ទេ។ ប្រាកដណាស់គាត់អាចដឹង<ពីចិត្តខ្លួនឯង និង>អំពីអ្នកធ្វើការដែលនៅក្បែរៗគាត់ ប៉ុន្តែគាត់មិនអាចដឹងពីចិត្តគំនិតរបស់កម្មករ<> ចំនួន៥០០០នាក់ផ្សេងទៀតនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ ការជំទាស់របស់មេធាវី នួន ជា ធ្វើឡើងចំណុចនេះត្រឹមត្រូវ។ ហើយរឿងនេះ កើតឡើង

ញ្ញើកញ្ញាប់ហើយ ភាគីពាក់ព័ន្ធ ជាពិសេសតំណាងសហព្រះរាជអាជ្ញាគប្បីប្រុងប្រយ័ត្នក្នុងការតាំងសំណួរ ជៀសវាងការសួរទូលំទូលាយ ដែលវាក្របខ័ណ្ឌរហូតដល់វិសាលភាពដែលមិនអាច ស្ថានភាព ឬក៏អង្គហេតុដែលសាក្សីមិនដឹង មិនអាចយល់ដឹង មិនអាចឃើញទាល់តែសោះ ហើយឆ្លើយជារួមៗនោះ។ ធម្មតាការបង្ហាញភស្តុតាង គឺបង្ហាញអំពីអង្គហេតុជាក់លាក់។ យើងបានបញ្ជាក់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សីរួចហើយអម្បាញ់មិញនេះ ទំនងជាភាគីពាក់ព័ន្ធស្តាប់ឮរួចហើយ អំពីគោលបំណងនៃការប្រាប់អំពីកាតព្វកិច្ចរបស់សាក្សីក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

[១១:១៧:២៥]

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំសូមបង្រួមសំណួរខ្ញុំមកក្នុងកម្រិតមួយតូចវិញ។ ខ្ញុំសូមសួរលោកថាតើនៅក្នុងកងរបស់លោកដែលមានគ្នា៥០០នាក់នោះ អ្នកដែលមកធ្វើការហ្នឹង ភាគច្រើនជាមនុស្សស្ម័គ្រចិត្ត ឬក៏ភាគច្រើនត្រូវបានគេបង្ខំឱ្យមកធ្វើការ?

**លោក អ៊ុំ ជី៖**

**ឆ៖** គឺថាធ្វើការនៅពេលនោះ តាមខ្ញុំពិនិត្យទៅតាមកងតូចមួយៗ គ្មាននរណាស្ម័គ្រចិត្តទេ ពីព្រោះធ្វើកន្លែងហ្នឹងវាធ្ងន់ធ្ងរ អីចេះបាទ។

**ស៖** ហេតុអីក៏ពួកគេមិនព្រមបដិសេធមិនធ្វើ? ឬមួយក៏ពួកគេមិនចង់ ឬក៏ពួកគេមិនហ៊ាន?

**ឆ៖** គឺសម័យនោះ គឺអ្នកមកធ្វើហ្នឹងមិនហ៊ានតែម្តង ទាំងខ្ញុំទាំងគេហ្នឹងមិនហ៊ាន។ គឺថាផែនការ ដាក់ទៅត្រង់ណា គឺត្រូវធ្វើត្រង់ហ្នឹងតែម្តង។

**ស៖** ដោយសារមូលហេតុអ្វីបានជាលោកនិយាយថា សូម្បីតែខ្លួនលោកផ្ទាល់ហ្នឹង ក៏លោកមិនហ៊ានដែរ ដោយសារមូលហេតុអ្វី? លោកអាចបញ្ជាក់បានទេ?

**ឆ៖** កាលពីសម័យហ្នឹង ដូចលោកព្រះរាជអាជ្ញាដឹងស្រាប់ហើយ គឺថាមិនមែនតែនៅកន្លែងខ្ញុំ កន្លែងនានាគឺថា កន្លែងនោះគឺប្រើយោធាគឺថាខ្លាំង បើអ្នកណាមិនគោរពតាមគោលការណ៍របស់គេ យើងត្រូវនឹងមានទោសប្រឆាំងនឹងសង្គមរបស់គេដឹកនាំ។

[១១:១៩:៤២]

**ស៖** ប្រសិនបើមានទោសប្រឆាំងនឹងសង្គមគេដឹកនាំហ្នឹង តើវានាំឱ្យយ៉ាងម៉េចដែរ? លោកអាចបញ្ជាក់បានទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** វានាំឱ្យប៉ះពាល់ដល់ខ្លួន។ គេចាប់ទៅរៀនសូត្រនៅកន្លែងមន្ទីរសន្តិសុខរបស់គេ ឬក៏នៅកន្លែងឃុំ នៅកន្លែងសង្កាត់។

**ស៖** អរគុណលោកសាក្សី។ ឥឡូវខ្ញុំសូមសួរសំណួរបន្តទៀត។ ខ្ញុំសូមឱ្យលោកជួយបញ្ជាក់ថា នៅពេលដែលកូនក្រុមរបស់លោកនោះ កំពុងតែលើកទំនប់ តើប្រជាជននៅក្នុងកងចល័តរបស់លោក ស្នាក់នៅជាមួយក្រុមគ្រួសាររបស់គេ ឬក៏យ៉ាងណា?

**ឆ៖** កាលដែលធ្វើទំនប់នេះ កងចល័តដែលនៅជាមួយខ្ញុំគឺគ្មានអ្នកមានប្រពន្ធទេ សុទ្ធតែលីវៗទាំងអស់។

**ស៖** តើគេស្នាក់នៅកន្លែងណា? ស្នាក់នៅជាមួយក្រុមគ្រួសាររបស់គេ ឬក៏យ៉ាងម៉េច?

**ឆ៖** កាលនោះគេធ្វើជារោង ឱ្យនៅតាមប្រឡាយ និងមាត់ទំនប់ហ្នឹងឯង គឺនៅសម្រាកនៅហ្នឹង ដេកហ្នឹង អត់មានពេលមកផ្ទះទេ។ ទាល់តែពេលថ្ងៃណាដែលវគ្គគេសម្រាកបានមកលេងផ្ទះបានមួយថ្ងៃអីចឹងទៅ។

[១១:២១:២៩]

**ស៖** ក្រៅពីថ្ងៃសម្រាកដែលលោកទើបតែមានប្រសាសន៍អម្បាញ់មិញនេះ តើប្រជាជនអាចមានសិទ្ធិសុំច្បាប់មកលេងផ្ទះបានដែរឬទេ?

**ឆ៖** សម័យហ្នឹងបើមានការចាំបាច់ កូន ឬប្រពន្ធនៅឯផ្ទះឈឺ គឺអាចមកបានក្នុងរយៈពេលជាក់ស្តែងអីចឹង។

**ស៖** ចុះប្រសិនបើមិនមានការចាំបាច់ ប៉ុន្តែដោយសារហេតុផលថា នឹកគ្រួសារ នឹកបងប្អូន តើគេអាចសុំច្បាប់មកលេងបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេសាក្សី ប្រភេទសំណួរឧបមានវិធី អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យប្រើប្រាស់ទេ។

**សួរដោយលោក សេង លាង៖**

**ស៖** តើនៅក្នុងកងរបស់លោកនោះ មាននរណាម្នាក់ដែលធ្លាប់ទៅលួចរត់ទៅលេងផ្ទះដោយគ្មានការអនុញ្ញាតដែរឬទេ?

**លោក អ៊ុំ ជី៖**

**ឆ៖** នៅក្នុងសម័យហ្នឹងមាន ជួនកាលយុវជនខ្លះក៏គេចទៅផ្ទះទៅអ៊ីចឹងដែរ ប៉ុន្តែដោយប្រធានកងគេទៅតាមមកវិញមក។

**ស៖** ក្នុងករណីហ្នឹង តើមានទណ្ឌកម្មណាមួយដែលត្រូវបានដាក់ទៅលើអ្នកដែលទៅលេងផ្ទះដោយគ្មានការអនុញ្ញាតដែរឬទេ?

**ឆ៖** គឺប្រធានកងតូច កង -- គេតាមមកគឺមិនដែលមានទណ្ឌកម្មអី គ្រាន់តែធ្វើការណែនាំ និងអប់រំបន្តិចបន្តួច គឺឲ្យធ្វើការធម្មតាវិញ។

**ស៖** តើប្រជាជនក្នុងកងរបស់លោកហ្នឹង គោរពវិន័យបានល្អដែរឬទេ?

**ឆ៖** ក្នុងកងហ្នឹងវាគ្នាច្រើន គោរពវិន័យមិនបានទាំងអស់ទេ។ វាបានត្រឹម២០ភាគរយ ឬ៣០ភាគរយ។ មួយចំនួនហ្នឹងក៏គ្នាគោរពមិនបាន ប៉ុន្តែមានការអប់រំជាបន្តបន្ទាប់អ៊ីចឹង។

[១១:២៤:៣៨]

**ស៖** សូមអរគុណ។ ខ្ញុំសូមទៅមុខមួយទៀត ពាក់ព័ន្ធនឹងម៉ោងពេលធ្វើការ។ តើលោកអាចបញ្ជាក់បានទេ ក្នុងកងរបស់លោក គេបែងចែកម៉ោងពេលធ្វើការយ៉ាងដូចម្តេច?

**ឆ៖** ពេលវេលាម៉ោងធ្វើការចាប់ពីម៉ោងបួនភ្លឺ រហូតទៅដល់ម៉ោងដប់មួយថ្ងៃត្រង់ ទើបគេឲ្យមកហូបបាយ។ ប៉ុន្តែក្នុងធ្វើការនោះ មានពេលសម្រាកក្នុងរយៈចន្លោះម៉ោងប្រាំបួនទៅម៉ោងដប់សម្រាក១៥នាទី។

**ស៖** ចុះចំណែកពេលថ្ងៃ?

**ឆ៖** ពេលថ្ងៃ *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក អ៊ុំ ជី៖**

**ឆ៖** ពេលថ្ងៃចុះធ្វើវិញចាប់ពីម៉ោងមួយ ទៅទល់ម៉ោងប្រាំ ប៉ុន្តែមានពេលសម្រាកដូចគ្នាពេលព្រឹកដែរ ចន្លោះម៉ោងបី គឺសម្រាកម៉ោង ១៥នាទីដែរ។

**សួរដោយលោក សេង លាង៖**

**ស៖** តើមានការអនុញ្ញាតឲ្យ តម្រូវឲ្យធ្វើការនៅពេលយប់ដែរឬទេ?

**ឆ៖** ការដែលធ្វើហ្នឹង ពេលផែនការគេត្រូវឲ្យយើងរើសម្រុក មានធ្វើពេលយប់ចាប់ពីម៉ោង

ប្រាំមួយ ទល់ម៉ោងដប់មួយដែរ។

**ស៖** តើក្នុងការសម្រេចដាក់ម៉ោងពេលធ្វើការងារហ្នឹង ពីណាគេជាអ្នកសម្រេច ឬក៏មានការប្រជុំសម្រេចដែរ?

**ឆ៖** ការធ្វើការហ្នឹង គឺថាសម្រេចហ្នឹង គឺប្រធានការដ្ឋានជំនួសមុខឲ្យតំបន់នៅកន្លែងស្រុកមន្ទីរស្នាក់ការគេនៅកន្លែងស្រុក គេហៅប្រធានមុខព្រួញទាំងអស់ទៅប្រជុំ សម្រេចឲ្យដាក់ពេលវេលា។

**ស៖** តើប្រជាជននៅក្នុងកងរបស់លោកពេញចិត្តនឹងម៉ោងពេលធ្វើការខាងលើដែរឬទេ?

**ឆ៖** ប្រជាជននៅក្នុងកងនោះ មិនពេញចិត្តទេ ពីព្រោះធ្វើការទាំងយប់ទាំងថ្ងៃ វាពលកម្មវាស្ទុះមិនរួចដែរ វាអន់ពេក ប៉ុន្តែតម្រូវការគេឲ្យធ្វើហើយ ត្រូវតែធ្វើតាមគេ។

**ស៖** បើមិនពេញចិត្ត តើមានអ្នកណាគេតវ៉ាដែរឬទេ? បើគ្មានអ្នកតវ៉ា តើដោយសារថាគេមិនចង់តវ៉ា ឬដោយសារគេមិនហ៊ានតវ៉ា?

**ឆ៖** នៅសម័យនោះ ដូចលោកជ្រាបស្រាប់ហើយ គ្មានអ្នកណាហ៊ានតវ៉ាទេ ពីព្រោះថាគេដាក់ចង្អុលទិសត្រង់ណា គឺត្រូវតែធ្វើតែម្តង។

**ស៖** បើសិនជាមានអ្នកតវ៉ា តើនឹងមានអ្វីកើតឡើង?

[១១:២៨:២៩]

**លោក គង់ សំអុន៖**

បាទ លោកប្រធាន នេះជាប្រភេទសំណួរឧបមានវិធី ដូចលោកប្រធានបានជំទាស់មុនដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកកែសម្រួលនូវសំណួររបស់លោកឡើងវិញ។ ហើយយើងបានប្រាប់ហើយ បញ្ហាអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យប្រើប្រាស់សំណួរឧបមានវិធីទេ។ សំណួរឧបមានវិធីនាំឲ្យសាក្សីឆ្លើយព្រាវៗ ឆ្លើយស្មានតែប៉ុណ្ណោះ។

បើកក្បាលមីក្រូហ្វូន!

**លោក សេង លាង៖**

អរគុណលោកប្រធាន ខ្ញុំសូមតសំណួរទៅមុខទៀត។

**សួរដោយលោក សេង លាង៖**

**ស៖** លោកធ្លាប់បានលើកឡើងថា មានពេលខ្លះតម្រូវឲ្យធ្វើការពីម៉ោងប្រាំមួយ ទៅដល់ម៉ោងដប់យប់ ហើយក្រោកធ្វើការនៅម៉ោងបួនភ្លឺ។ តើកម្មវិធីធ្វើការងាររបៀបនេះ តើប្រជាជនអាចទ្រាំទ្របានទេក្នុងការលើកដីនៅទំនប់មួយនេះ?

**លោក អ៊ុំ ជី៖**

**ឆ៖** ប្រជាជនអាចគាំទ្រៗទៅធ្វើនៅគ្រប់ម៉ោងរាល់ពេល ប៉ុន្តែវាជាសតិអារម្មណ៍គឺមាន អន់ប៉ុនៗមិនអាចយើងគេចទៅណាបាន ចេះតែធ្វើទៅតាមផែនការរបស់គេទៅ។

[១១:៣០:០៤]

**ស៖** លោកថា គេអាចទ្រាំទ្រធ្វើបាន តើគេទ្រាំទ្រធ្វើបានហ្នឹងដោយសប្បាយចិត្ត ដោយសារថាគេមានសុខភាពល្អនឹងធ្វើ ឬក៏ដោយសារថាគេធ្វើទាំងត្រដាបត្រដួស ដោយសារគេមិនហ៊ានតវ៉ា?

**ឆ៖** គឺធ្វើនោះ ធ្វើទាំងត្រដាបត្រដួស គ្មានហ៊ានអ្នកណាម្នាក់ហ៊ានតវ៉ា ទាំងខ្ញុំ ទាំងសមាជិកទាំងអស់ហ្នឹង គឺត្រូវតែធ្វើតាមនុ៎ង។

**ស៖** ខ្ញុំសូមទៅមុខបន្តិចទៀត។ នៅព្រឹកម៉ោងបួនដែលគេដាស់ឲ្យប្រជាជនធ្វើការនោះ តើគេដាស់តាមរបៀបណាទៅ? លោកអាចរៀបរាប់បានទេ?

**ឆ៖** ដែលពេលទៅធ្វើការនៅព្រឹកម៉ោងបួន គឺគេឲ្យសញ្ញាទៅតាមកងមួយ គឺប្រើកញ្ចែកាលពីសម័យហ្នឹង។

**ស៖** ចុះមានរឿងអ្វីកើតឡើងចំពោះអ្នកដែលក្រោកទៅធ្វើការមិនទាន់ពេល?

**ឆ៖** ចំពោះអ្នកដែលទៅ គឺថាត្រូវតែទៅ បើទៅមិនរួចទាល់តែអ្នកឈឺ។ ជាក់ស្តែងគឺអាចនៅដេកសម្រាកបានតើ! បាទ។

**ស៖** ខ្ញុំចង់និយាយសំដៅទៅលើអ្នកដែលធ្វើការយប់ ហើយគាត់អស់កម្លាំង ហើយគាត់សម្រាកជ្រុល អត់ឮកញ្ចែ តើមានរឿងអីកើតឡើងចំពោះគាត់ បើសិនជាគាត់ក្រោកឡើងទៅធ្វើការមិនទាន់?

[១១:៣១:៥៥]

**លោក គង់ សំអុន៖**

លោកប្រធាន នេះជាប្រភេទ សំណួរដដែល ដូចការបដិសេធមុនរបស់ខ្ញុំ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ត្រឹមត្រូវ។ លោកតំណាងសហព្រះរាជអាជ្ញាជាតិ គប្បីរៀបចំសំណួរឲ្យ

បានល្អ ហើយសំណួរដូចជាច្រំដែលនូវពាក្យ ប្រើពាក្យ "ប្រសិនបើ" គឺជាឧបមានវិធីច្រើនញឹកញាប់។ យើងត្រូវការពេលវេលាពន្លឿនដើម្បី គិតថា ប្រឹងប្រែងឲ្យចប់ស្ដាប់សក្ខីកម្មសាក្សីនេះនៅថ្ងៃនេះ។ ហើយប្រសិនបើសំណួរឥតប្រយោជន៍ សំណួរដែលហាមឃាត់មិនឲ្យប្រើ ហើយនៅតែប្រើញឹកញាប់ដូចនេះ ទំនងជាអាចខាតពេលច្រើនណាស់។

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំសូមទៅសំណួរមួយទៀត។ ពាក់ព័ន្ធជាមួយនឹងផែនការ តើនៅក្នុងកងរបស់លោកនោះ គេតម្រូវឲ្យប្រជាជនម្នាក់រែកដីប៉ុន្មានម៉ែត្រគូប ក្នុងមួយថ្ងៃ?

[១១:៣៣:១៧]

**លោក អ៊ុំ ជី៖**

**ឆ៖** កាលពីជីកនៅខ្ទង់លើ នៅដីសុទ្ធ គឺសម្រេចឲ្យធ្វើម្នាក់៣ម៉ែត្រគូប។

**ស៖** តើប្រជាជនអាចឆ្លើយតបតាមផែនការ ដែលតម្រូវឲ្យធ្វើ៣ម៉ែត្រគូបក្នុងមួយថ្ងៃហ្នឹងបានដែរឬទេ?

**ឆ៖** ប្រជាជនដែលធ្វើជីកដីនោះ មួយចំនួនទៅគឺអាចធ្វើបាន មួយចំនួនមិនអាចធ្វើបានទេ។ ប៉ុន្តែសម័យនោះ នៅក្នុងការគ្រប់គ្រងរបស់ខ្ញុំ ខ្ញុំដើរពិនិត្យមើល បើសិនជាធ្វើមិនបានវានៅតិចតួច គឺបញ្ឈប់ទៅតាមម៉ោងពេលវេលាធម្មតា។

**ស៖** តើមានប្រជាជនប៉ុន្មានភាគរយអាចធ្វើបានតាមផែនការដែលកំណត់?

**ឆ៖** ប្រជាជនដែលអាចធ្វើការទៅបានតាមការកំណត់រវាង៦០ភាគរយ។

**ស៖** ៦០ ឬ៧០ តើលោកអាចបញ្ជាក់បានទេ?

**ឆ៖** វាអានេះជាតួរលេខ គឺថាមិនអាចបញ្ជាក់បានទាំងអស់ ប៉ុនថាវាអាចបាន៦០ទៅ៧០ គឺនៅតិចតួចទេដែលធ្វើមិនបាន។

**ស៖** លោកប្រធានខ្ញុំសូមអានកំណត់ហេតុសួរចម្លើយ -- សាកសួរ ឯកសារ E3/5265 ដើម្បីបញ្ជាក់ឲ្យលោកសាក្សីចងចាំអំពីព័ត៌មានមួយចំនួន ដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុហ្នឹង។ តើលោកអាចអនុញ្ញាតដែរទេ លោកប្រធាន?

[១១:៣៥:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដូចសម្រេចរួចហើយ ភាគីពាក់ព័ន្ធដូចមិនចាំបាច់សួរការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះជាមុនទេ។ វាអាស្រ័យទៅលើនីតិវិធីដែលលោកសួរពាក់ព័ន្ធរួចហើយ លើបញ្ហាហ្នឹង សួរសំណួរបើករួចហើយ។ ប្រសិនបើវាមានភាពខុសគ្នា អាហ្នឹងអាចយកសំណួរដែលឆ្លើយពីមុនៗរបស់គាត់មកសួរបាន ដកស្រង់អាចសួរបញ្ជាក់បាន ដើម្បីបញ្ជាក់មើលថាវាមានបញ្ហាខុសគ្នាដោយមូលហេតុអី។

**លោក សេង លាង៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំសូមអានសម្រង់ឯកសារ E3/5265 ត្រង់ ERN ជាភាសាខ្មែរ 00271398 រហូតដល់ 99 – ERN ជាភាសាខ្មែរ 00271398 រហូតដល់99, ERN ជាភាសាអង់គ្លេស 00282347, ជាភាសាបារាំង 00487925។ លោកបានឆ្លើយថា៖ "ការជីកប្រឡាយគេដាក់ផែនការ ក្នុងម្នាក់ត្រូវជីក៣ម៉ែត្រគូប កាប់ហើយរែកខ្លួនឯង ហើយភាគច្រើនគេមិន គេធ្វើមិនគ្រប់ផែនការនោះទេ សម្រាប់មានប្រជាជនប្រហែល៣០ភាគរយប៉ុណ្ណោះ ដែលអាចធ្វើគ្រប់ផែនការនេះ។ ពេលមានធ្វើមិនគ្រប់ផែនការហ្នឹង គឺខ្ញុំមិនរាយការណ៍ទៅថ្នាក់លើទេ ហើយថ្នាក់លើក៏មិនដឹងដែរ។ នៅក្នុងក្រុមរបស់ខ្ញុំចំពោះអ្នកធ្វើមិនគ្រប់ផែនការ ខ្ញុំមិនដែលដាក់ទណ្ឌកម្មលើអ្នកនោះទេ ដោយខ្ញុំបានរាយការណ៍កុហកទៅថ្នាក់លើថា បានសម្រេចតាមផែនការហើយ។" តើលោកអាចរំឭកការចងចាំរបស់លោកបានដែរឬទេ ចំពោះចំណុចនេះ? លោកអាចបញ្ជាក់បានម្តងទៀតមើល៍ ថាតើមានប្រជាជនប៉ុន្មានភាគរយ ដែលអាចធ្វើតាមផែនការហ្នឹងបាន?

[១១:៣៨:២០]

**លោក អ៊ុំ ជី៖**

**ឆ៖** រឿងហ្នឹង ដែលប្រជាជនខ្លះគ្នាខ្សោយ ធ្វើហ្នឹងម្នាក់ៗហ្នឹងខ្សោយធ្វើមិនបានមែន បានៗតែអ្នកដែលពលកម្មខ្លាំងៗអាចបាន។ ប៉ុន្តែដូចៗឯកសារហ្នឹង គឺខ្ញុំវារាក់ដែរគឺថា ដូចៗដែរតាមការលើករបស់ព្រះរាជអាជ្ញាអំមិញហ្នឹង គឺថា ខ្ញុំមិនដែលរាយការណ៍ទេ ពីព្រោះប្រធាន – ខ្ញុំទទួលមុខព្រួញមែនមានប្រធានគេគ្រប់គ្រងពីលើខ្ញុំទៀត ប្រធានការដ្ឋានហ្នឹង ហើយខ្ញុំពេលល្ងាច គេឲ្យរាយ ពេលបញ្ចប់

មួយថ្ងៃៗ គេឲ្យរាយការណ៍ទៅឲ្យគេ។ អាហ្នឹងអ៊ីចឹង ខ្ញុំក៏ឯកភាពដែរ អាហ្នឹងខ្ញុំនិយាយអំមិញវាខុសពីការពិតបន្តិច។

**ស៖** តើលោកអាចប្រាប់បានទេ ថាអ្នកណាគេជាអ្នកដែលកំណត់ដាក់ផែនការនេះ? ហើយការដាក់ផែនការនេះ មានបានស្ទង់អំពីសមត្ថភាពរបស់ប្រជាជនដែរឬទេ?

**ឆ៖** ដាក់ផែនការនេះគឺ ប្រធានការដ្ឋាននៅថ្នាក់ស្រុកដែលគេប្រជុំយើង ដែលចុះធ្វើដំបូងគេប្រាប់ឲ្យយើងដាក់ប៉ុណ្ណឹងហើយ ទាំងគ្រប់នៅក្នុងកងទាំងអស់ហ្នឹង ពីព្រោះមិនមែនមានតែកងខ្ញុំឯណា មនុស្សមួយការដ្ឋានមនុស្សវាច្រើន។

**ស៖** ក្នុងការអានសម្រង់អម្បាញ់មិញលោកបានបញ្ជាក់ថា ទទួលស្គាល់ថា លោកមិនធ្លាប់រាយការណ៍ទេ នៅពេលដែលប្រជាជនធ្វើមិនបានតាមផែនការហ្នឹង។ ហេតុអ្វីបានជាលោក--

[១១:៤០:១៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអភ័យទោស<ចំពោះការឡើងមកកាត់។ តែ>នេះមិនមែនជាការជំទាស់<អី>ទេ។ ក៏ប៉ុន្តែ<>យើង<ធ្វើសវនាការវា>ហួសម៉ោងសម្រាកដែលត្រូវបានកំណត់សម្រាប់សុខភាពលោក ខៀវ សំផន<ហើយ។ ខ្ញុំតែងតែសួរគាត់ពីស្ថានភាពអារម្មណ៍របស់គាត់ ហើយ>ឥឡូវនេះយើង<>ដល់ពេល<វេលាមួយដែល>គាត់<>មាន<អារម្មណ៍>លំបាកហើយ។ អ៊ីចឹង សូមឲ្យមានការឈប់សម្រាក<រយៈពេលខ្លី> លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយកន្លងមកក៏មានសំណើសុំរបស់លោកមេធាវីដែរ ថាករណីត្រូវមេធាវីមានករណីចាំបាច់ គឺមេធាវីខ្លួនឯងជាអ្នកសុំ យល់ថាគួរតែត្រូវបន្តរហូលដល់ម៉ោងដប់មួយ សែសិបប្រាំនាទី។ យើងអម្បាញ់មិញនេះ យើងបានជម្រាបហើយ បំណងរបស់យើងថា ចង់ធ្វើសវនាការ រុញសវនាការនេះឲ្យបានដោះស្រាយឲ្យបានបញ្ចប់នៅរសៀលនេះត្រឹមម៉ោងបួន ដោយសារមិនអាចធ្វើហួសពីម៉ោងបួនបានទេ។ ហើយថ្ងៃស្អែកហ្នឹង ក៏មិនអាចធ្វើសវនាការបានដែរ។ ហើយបញ្ហាសាក្សីរូបនេះ វាពិបាកនៅក្នុងមានលទ្ធភាពក្នុងការមកផ្តល់សក្ខីកម្ម។

ឥឡូវយើងសួរភាគីតែម្តងទៅ ហើយជាពិសេសខាងមេធាវីការពារក្តី ខៀវ សំផន ថាតើនៅរសៀលនេះ យើងអាចធ្វើសវនាការចាប់ផ្តើមពីម៉ោងមួយបានដែរទេ?

ឥឡូវនេះយើងយល់ថា សមស្របសម្រាកហើយ។ ប៉ុន្តែតើរសៀលនេះយើងអាចចាប់ផ្តើមម៉ោងមួយបានដែរឬទេ? ក្នុងន័យយើងចង់ជំរុញឲ្យការស្តាប់សក្ខីកម្មសាក្សីរូបនេះ ក្រែងលោបានចប់ ពីព្រោះដូចជា យើងបានកំណត់ហើយតាមផែនការយើងត្រូវចាប់ ប៉ុន្តែដោយសារយើងមានការតជំទាស់ តវ៉ាច្រើននៅក្នុងសប្តាស៍នេះ ជាពិសេសថ្ងៃចន្ទនោះយើងអាក់ខានរហូតដល់មិនអាចធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីមួយព្រឹកឯណោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

កូនក្តីរបស់ខ្ញុំបានបញ្ជាក់ថា គាត់នឹងប្រឹងប្រែងដើម្បី<>មកចូលរួម<សវនាការ>នៅម៉ោងមួយ<រសៀលនេះ>។ <ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា ប្រសិនបើខាងការពារក្តីចូលរួមសវនាការលើសពីពេលវេលាកំណត់ យើងតែងតែសួរលោក ខៀវ សំផន ថាគាត់មានអារម្មណ៍យ៉ាងម៉េចជាមុនសិន>។ លោក ខៀវ សំផន គាត់បានបញ្ជាក់ថាថ្ងៃនេះ គាត់អាចប្រឹងប្រែងចូលរួម<>បាន<នៅថ្ងៃនេះ> ក៏ប៉ុន្តែនៅថ្ងៃពេលរសៀលនេះ ខ្ញុំក៏មិនប្រាកដថាតើនឹងមានបញ្ហាអ្វីកើតឡើងដែរ។

[១១:៤៣:០៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ នេះគ្រាន់តែជាការសាកល្បងរបស់អង្គជំនុំជម្រះទេ ហើយជាការប្រឹងប្រែងដើម្បីក្រែងលោបានល្អសម្រាប់ទាំងកិច្ចដំណើរការនីតិវិធី ការរៀបចំអង្គ -- រៀបចំស្តាប់សក្ខីកម្ម កាលវិភាគសវនាការរបស់អង្គជំនុំជម្រះ ក៏ដូចជាការចូលមកផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះទេ។

បាទ អរគុណនូវការផ្តល់ព័ត៌មាននេះ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចសម្រាកថ្ងៃត្រង់ត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅរសៀលនេះចាប់ផ្តើមពីម៉ោងមួយ។ សូមភាគីជ្រាប។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅវេលាម៉ោងមួយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រសៀលនេះឲ្យបានមុនម៉ោងមួយ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤៤ នាទី ដល់ម៉ោង ១២:៥៩ នាទី)*

[១២:៥៩:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរសំណួរទៅកាន់សាក្សីបន្តពីសហព្រះរាជអាជ្ញាជាតិ<មុនពេលយើងឈប់សម្រាក>។ <> ឥឡូវនេះខ្ញុំសូមសួរបន្តពី<សហភាតារបស់ខ្ញុំ មានសំណួរមួយចំនួនជាដំបូង>

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**សៈ** លោកសាក្សី លោកនិយាយថា <លោកបានមកដល់>នៅខែកុម្ភៈ ឆ្នាំ១៩៧៨<នៅការដ្ឋានជីកប្រឡាយ>ដែលភ្ជាប់ទៅនឹងទំនប់១មករា។ ខ្ញុំចង់ដឹងថា តើលោកធ្វើការនៅកន្លែងជីកប្រឡាយ<ហ្នឹងដល់ថ្ងៃខែឆ្នាំណា>? ហើយលោកធ្វើការ<ដោយអត់មានពេលឈប់សម្រាកទេឬ>?

**លោក អ៊ុំ ជី៖**

**ឆ៖** ការជីកប្រឡាយនោះ ខ្ញុំធ្វើទាល់តែបិទវគ្គបានខ្ញុំឈប់។

**សៈ** តើការជីកប្រឡាយហ្នឹង បញ្ចប់រយៈពេលប៉ុន្មានខែដែរ មុនពេលវៀតណាមចូលមកដល់?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១៣:០១:១៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោក!

**លោក អ៊ុំ ជី៖**

**ឆ៖** នៅក្នុងឆ្នាំ២០០៨ហ្នឹង ប្រឡាយហ្នឹងគឺបញ្ចប់នៅឆ្នាំ -- នៅខែ៨៧ ឆ្នាំ២០០៨ហ្នឹង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** <ខ្ញុំឮ២០០៨ ប៉ុន្តែ ខ្ញុំគិតថាវានៅឆ្នាំ១៩៧៨ ជាកាលបរិច្ឆេទដែលលោកកំពុងតែលើកយកមកនិយាយ> អ៊ីចឹង <> គឺខែសីហា ១៩៧៨មែនទេ? <>

**ឆ៖** ខ្ញុំនិយាយអំមិញ នៅឆ្នាំ១៩៧៨ ធ្វើ -- ខ្ញុំធ្វើទ័ពបិទវគ្គ។ ដល់ពេលៗបិទវគ្គនៅក្នុងឆ្នាំហ្នឹងដដែល នៅក្នុងៗខែ៨។

**ស៖** សូមអរគុណ។ ក្នុងចំណោមក្រុម៥០០នាក់ដែលលោកដឹកនាំនោះ គឺយុវជន៥០០នាក់ តើមានអ្នកដែលជាប្រជាជនថ្មីទេ?

**ឆ៖** បាទ អ្នកទៅធ្វើហ្នឹងគឺចម្រុះ ទាំងប្រជាជនថ្មី ទាំងប្រជាជនចាស់។

**ស៖** ចុះជនជាតិចាម មានទេ?

**ឆ៖** ជនជាតិចាម មាន។

[១៣:០៣:១៦]

**ស៖** នៅពេលដែលលោកដឹកនាំកងទាំង៥០០នាក់ហ្នឹង លោកនិយាយថា<ជាការធ្វើការដោយបង្ខំ ហើយ>លោកទទួលបញ្ជា ឬក៏សេចក្តីណែនាំពី<ថ្នាក់លើរបស់លោក។> តើលោកផ្ទាល់នុំងលោក<មានកោះ>ប្រជុំ ដើម្បីបញ្ជូនបញ្ជាដែលលោកទទួលបានពី<ថ្នាក់លើ> ទៅដល់កូនក្រុមរបស់លោក<ដែរ>ទេ?

**ឆ៖** បាទ ដែលពេលៗចុះធ្វើ ខ្ញុំ ពីផែនការដែលធ្វើហ្នឹង ខ្ញុំត្រូវមកដល់ៗកន្លែងការដ្ឋានហ្នឹងដែលពេលនេះ ត្រូវប្រជុំតាមក្រុមតូចៗ ប្រាប់ពីៗហេតុការណ៍ហ្នឹង។

**ស៖** តើកូនក្រុមទាំង៥០០នាក់របស់លោកហ្នឹង គឺជាអ្នកមកពីឃុំបល្ល័ង្កទាំងអស់ដែលនៅធ្វើការជីកប្រឡាយហ្នឹងមែនទេ?

**ឆ៖** បាទ អ្នកទាំង៥០០នាក់ហ្នឹង នៅក្នុងឃុំបល្ល័ង្កទាំងអស់ ព្រោះគ្រប់ភូមិ។

**ស៖** <ប្រសើរណាស់!>ចំពោះការប្រជុំ តើលោកផ្ទាល់នុំង លោកមានបានចូលរួមក្នុងប្រជុំទិតៀន ឬស្វ័យទិតៀនទេ? ហើយលោកធ្លាប់ដឹកនាំប្រជុំបែបហ្នឹងទេ សម្រាប់ក្រុមរបស់លោកនោះ?

**ឆ៖** ខ្ញុំមិនដែលបានប្រជុំស្វ័យទិតៀន ទៅចុះទៅតាមក្រុមតូចៗទេ។ ពេលប្រជុំ គឺប្រជុំតែប្រធានក្រុមតែម្តង។

**ស៖** <តើ>កូនក្រុមទាំងអស់ហ្នឹង ត្រូវប្រជុំ<ទិតៀន ឬស្វ័យទិតៀន>ជាមួយមេ<កង>របស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្លួនមួយៗអ៊ីចឹងតាម<កង>អ៊ីចឹងទៅ មែនទេ? ហើយ<បើសិនជាប្រជុំមែន តើ> គេប្រជុំនៅ<ម៉ោងប៉ុន្មាន>ដែរ? <>

**ឆ៖** ប្រជុំនៅពេលយប់ ពេលក្រោយហូបបាយរួច។

**ស៖** អម្បាញ់មិញនេះ លោកបាននិយាយអំពីកិច្ចប្រជុំដែលលោកបានចូលរួម។ តើមេឃុំ ឬមេស្រុកមានបានពន្យល់ប្រាប់លោកថា ហេតុអ្វីបានជារបបខ្មែរក្រហមចាំបាច់ត្រូវកសាងទំនប់១មកវា ហើយនិងជីកប្រឡាយដែល<>ភ្ជាប់នឹងទំនប់ហ្នឹង<ដែរទេ>?

**ឆ៖** គោលការណ៍របស់សម័យខ្មែរក្រហមហ្នឹង ដែលឲ្យជីកទំនប់ -- អ៊ំ! លើកទំនប់ និងជីកប្រឡាយហ្នឹង គឺដើម្បីយកទឹកស្រោចស្រពធ្វើស្រែឲ្យបានបីដងក្នុងមួយឆ្នាំ។

**ស៖** នៅពេលប្រជុំ តើគេមានប្រាប់លោកទេថា ស្រូវបន្ថែមដែលបានមកពីការជីកទំនប់ <> ហ្នឹង គេយកទៅធ្វើអីទេ? គេមានប្រាប់លោកថា គេនាំ<ចេញ>ស្រូវហ្នឹង<>ទេ?

**ឆ៖** ខ្ញុំមិនដឹងច្បាស់ទេ តែស្រូវហ្នឹងដឹងតែធ្វើរួច ដឹងគេនាំទៅណាទេ។ គ្រាន់តែធ្វើបាន ប្រមូលផលរួច ក៏ឃើញឡានអីគេចូលដឹកទៅខ្លះ ប៉ុន្តែមិនដឹងជាទៅណា។

**ស៖** ចុះលោកឃើញឡាន<បើក>ចេញ<ទេ? ហើយបើសិនជាឃើញ តើបើកចេញ>ទៅតាមទិសណា? គេដឹកយកទៅចែកតាមឃុំ<ផ្សេងៗ>ឬក៏លោកឃើញឡានហ្នឹងចេញទៅ <ឬបើកទៅកន្លែងណា>ផ្សេង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី អង់តា ហ្គីសសេ លោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ជាថ្មីម្តងទៀត ខ្ញុំសូមអន្តរាគមន៍ <ដើម្បី>ឲ្យសហព្រះរាជអាជ្ញាសួរសំណួរបើក <ហើយ> កុំឲ្យមានការដាក់សំណួរ<ដែលមាន>ចម្លើយ<ជ្រើសរើស>ច្រើនអ៊ីចឹង។ <ឃ្លាពីរចុងក្រោយនេះ មិនចាំបាច់ទេ។>

[១៣:០៨:៤៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

<លោកប្រធាន> ខ្ញុំមិនឆ្លើយតបទេ ពីព្រោះថាយើងប្រញាប់ណាស់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** អ៊ីចឹង ខ្ញុំចង់សួរលោកថា តើគេដឹកផលស្រូវ<ដែលដាំនៅភូមិឋានរបស់លោក>ហ្នឹង <តើគេដឹក>យកចេញទៅណា<ដែរ>?

**លោក អ៊ុំ ជី៖**

**ឆ៖** ខ្ញុំមិនដឹងច្បាស់ ដូចខ្ញុំនិយាយខាងដើម គឺថាមិនដឹងគេដឹកទៅណាទេ។ ព្រោះប្រមូលផលរួច គេថាឲ្យអង្គការតម្រូវការឲ្យសុំដឹកស្រូវយកទៅជួយកងទ័ព ជួយអីអ៊ីចឹងទៅ មិនដឹងទៅណា។

**ស៖** សូមអរគុណ។ ក្នុងពេលដែលលោកធ្វើការនៅទីនោះ គឺប្រហែលជា<៦ ឬ>៧ខែ តើមាន <បើសិនជាខ្ញុំមិនខុសទេ តើមានរដ្ឋអំណាច>ដែលមកពីភ្នំពេញ ឬក៏មានជនបរទេសមកធ្វើទស្សនកិច្ចនៅសាងសង់ហ្នឹងទេ? <ជាកន្លែងដែលលោកកំពុងធ្វើការ មានអ៊ីចឹងទេ?>

**ឆ៖** មិនដែលមានជនបរទេសមកទេ គឺមានតែខាងគណៈតំបន់ និងគណៈស្រុកបានចុះទៅកន្លែងធ្វើហ្នឹង។

[១៣:១០:២៤]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីឈ្មោះថ្នាក់ដឹកនាំទាំងអស់នេះនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំចង់ដឹងថា នៅពេលដែលប្រជុំនៅក្នុងថ្នាក់ឃុំ ថ្នាក់ស្រុក ឬថ្នាក់តំបន់ <តើលោកបានចូលរួមប្រជុំថ្នាក់ណាមួយ?>តើលោកធ្លាប់ឮថ្នាក់លើនិយាយអំពីពាក្យថា "ខ្មាំង" ទេ?

**ឆ៖** ធ្លាប់ឮនិយាយថា "ខ្មាំង" ខ្ញុំធ្លាប់ឮ។ បើអ្នកណាមិនគោរពបញ្ជាគឺថា គេទុកជា "ខ្មាំង" សម័យហ្នឹង។

**ស៖** តើលោកអាច<ប្រាប់យើងបាន>ទេថា តើអ្នកណាខ្លះដែលនិយាយប្រាប់លោកអំពី<សញ្ញាណនៃពាក្យថា>ខ្មាំង<>?

**ឆ៖** គឺគណៈតំបន់ និងគណៈស្រុកហ្នឹង ដែលគាត់ធ្វើជាមីទ្ទីងប្រជុំហ្នឹងឯង។

**ស៖** តើគេមាននិយាយប្រាប់<អ្វីដល់>លោក<> អំពីជោគវាសនារបស់ខ្មាំងទាំងអស់នោះ<ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>?

**ឆ៖** ពីជោគវាសនាទាំងអស់ហ្នឹងដែលមានកើតឡើងគឺថា គេថានឹងកម្ទេច ពីព្រោះស្មុះនឹងចលនារបស់គេកសាងសម័យហ្នឹង។

**ស៖** នៅពេលដែលមេស្រុក ឬក៏មេតំបន់និយាយអំពីខ្មាំង តើគេមាននិយាយអំពីខ្មាំង<ជាក់

លាក់>ដែល<មានចេតនា>បំផ្លាញ<សំណង់>ទំនប់១មករា ឬក៏បំផ្លាញ<ប្រឡាយនៅ>ជុំវិញទំនប់ហ្នឹងទេ?

**ឆ៖** គេមិនដែលលើកថាខ្មាំងបំផ្លាញទីតាំង ឬទំនប់ទេ គេគ្រាន់តែលើកថាជាខ្មាំង បើធ្វើឲ្យស្ទះចលនាហ្នឹង គេនឹងកម្ទេច។ គេគ្រាន់តែនិយាយអ៊ីចឹង។

[១៣:១៣:១៧]

**សៈ** សូមអរគុណ។ នៅលើការដ្ឋាន<>សាងសង់ប្រឡាយ <>ដែលភ្ជាប់ទៅនឹងទំនប់<១មករា>នោះ តើលោកធ្លាប់ឃើញគេចាប់ខ្លួន<មនុស្ស>ម្នាក់ ឬក៏ចាប់ខ្លួនមនុស្ស<ច្រើន>នាក់ទេ?

**ឆ៖** ខ្ញុំធ្វើហ្នឹងធ្លាប់ឃើញដែរ ចាប់ ពីព្រោះការធ្វើហ្នឹងមានសន្តិសុខខាងស្រុកហ្នឹងគេដើរតាមដានពិនិត្យ ប៉ុន្តែចាប់មិនមែនជាសមាជិករបស់ខ្ញុំ ជាកូនក្រុមរបស់ឃុំត្នោតជុំដែលនៅជាប់គ្នា។

**សៈ** តើអ្នកដែលគេចាប់ខ្លួនហ្នឹង កម្មករហ្នឹងគាត់មានអាយុប៉ុន្មានដែរ?

**ឆ៖** កម្មករហ្នឹងតាមការប៉ាន់ស្មានប្រហែលជាអាយុ១៨ ទៅ១៩។

**សៈ** តើលោកដឹងទេថា ហេតុអ្វីបានគេ -- បានជាសន្តិសុខហ្នឹងចាប់ខ្លួន<កម្មករទាំង>ហ្នឹង?

**ឆ៖** ព្រោះគេចាប់ហ្នឹង គឺចាប់ដើម្បីបំបាក់ កុំឲ្យយើងនៅខាងក្រោយធ្វើតាមតទៅទៀត។

**សៈ** ខ្ញុំសូមដកស្រង់នូវចម្លើយជាក់លាក់របស់លោក គឺនៅក្នុងកំណត់ហេតុ<ស្តាប់ចម្លើយរបស់លោក គឺE3/5265>ជាភាសាខ្មែរគឺ<00271397ដល់98>ជាភាសាបារាំងគឺ<00482924>ជាភាសាអង់គ្លេស 00282346។ លោកបានឆ្លើយដូចតទៅ៖ "ថ្ងៃមួយខ្ញុំឃើញការចាប់ខ្លួនផ្ទាល់ភ្នែកនូវកុមារម្នាក់នៅកងចល័ត។ វានិយាយ -- វា<កំពុង>តែនិយាយ ហើយ<ភ្នាក់ងារ>សន្តិសុខផ្ទៃក្នុងនៅកន្លែងធ្វើការនោះចាប់វា។ គេហៅពីកន្លែងធ្វើការទៅដល់កំពូលទំនប់ ហើយគេចាប់ខ្លួននៅទីនោះ នៅចំពោះមុខគេឯងតែម្តង។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់ដឹងថា តើគេ<មាន>ហាម<ក្មេងហ្នឹងកុំឈប់ធ្វើការ និងហាម>មិនឲ្យនិយាយគ្នា <របៀបហ្នឹងដោយគ្មានការអនុញ្ញាតនៅការដ្ឋានសាងសង់ដែរឬទេ>? ហើយបើសិន<ជាគាត់ល្មើសទៅនឹងអ្វីដែលគេហាម តើគាត់ប្រថុយទទួលទណ្ឌកម្ម> ពីខាងកងកម្លាំងសន្តិសុខឬ?

**ឆ៖** សម័យហ្នឹង គេហាមមិនឲ្យនិយាយគ្នា ប្រាសចាកពីមាគ៌ារបស់បក្សគេហ្នឹង។

[១៣:១៦:៥៨]

**សៈ** សូមអរគុណ។ លោកនិយាយថា <ភ្នាក់ងារ>សន្តិសុខហ្នឹងមកពីថ្នាក់ស្រុក តើលោកដឹង

ទេថា សន្តិសុខហ្នឹងគាត់មកពីភូមិភាគណាដែរ?

**ឆ៖** សន្តិសុខអស់ហ្នឹងពេលក្រោយច្រើនមកពីទិសនិរតី។ កម្មាភិបាលនៅក្នុងថ្នាក់ឃុំ ថ្នាក់ស្រុក ច្រើនតែពួកនិរតី អត់មានទេអ្នកយើងនៅស្រុកកំណើត។

**ស៖** តើលោកធ្លាប់ឃើញអ្នកដែលគេចាប់ខ្លួនហ្នឹង<ម្តងទៀត>ទេ? <ឬក៏លោកដែលដឹងថាមានរឿងអ្វីកើតឡើងចំពោះបុគ្គលដែលគេចាប់ខ្លួនហ្នឹងទេ?>

**ឆ៖** អ្នកចាប់ខ្លួន ពេលចាប់ទៅបាត់ហើយ មិនដែលឃើញមកវិញទេ។

**ស៖** លោកនិយាយថា <មានគេចាប់ខ្លួនមនុស្ស ហើយក្នុងពេលនោះ លោកហាក់បីដូចជានិយាយអំពីមនុស្សតែម្នាក់ដែលលោកបានឃើញ> អ៊ីចឹងខ្ញុំចង់ដឹងថា តើលោក<បាន>ឃើញ<ឬក៏ឮ>គេចាប់ខ្លួន<មនុស្សផ្សេងទៀតនៅលើការដ្ឋានសាងសង់ទំនប់ដែរទេ>? ខ្ញុំមិនសំដៅទៅលើ<តែ>កងរបស់លោកទេ អាចជាអ្នកដែលនៅកងផ្សេង<ទៀត?>

**ឆ៖** ខ្ញុំមិនដែលឃើញ ពីព្រោះៗខ្ញុំនៅធ្វើតាមមុខព្រួញ វាមិនសូវបានដឹងព័ត៌មានឲ្យគ្រប់ជ្រុងជ្រោយទេ។

**ស៖** ចុះលោកធ្លាប់<>ឮ<><អំពីការចាប់ខ្លួនមនុស្ស>ផ្សេងទៀត<><ដែរ>ទេ?

**ឆ៖** មាន ខ្ញុំ -- ពិសេសប្អូនខ្ញុំហ្នឹង។ ខ្ញុំទៅធ្វើចម្ការ ដល់អ្នកធ្លាប់នៅជិតក្បែរខាងផ្ទះខ្ញុំ ដល់មកវិញខ្ញុំ ស្ងាត់ទៅ ខ្ញុំសួរគេ គេថា គេចាប់បាត់អស់ហើយ។ ធ្លាប់ឮ ធ្លាប់ឃើញ – ធ្លាប់ឮ អានេះមិនឃើញទេ។ បាត់មនុស្សតែម្តង។

[១៣:១៩:៥០]

**ស៖** បាទ សូមអរគុណ។ <យើងផ្អាកនិយាយអំពីការដ្ឋានសាងសង់ទំនប់ និងប្រឡាយបន្តិចសិនខ្ញុំនឹងបន្តវិញពេលបន្តិចទៀត។> ខ្ញុំនិយាយអំពីអ្វីដែលកើតឡើងនៅក្នុងភូមិរបស់លោក<មួយភ្លែត។> ប៉ុន្តែខ្ញុំចង់សូមបញ្ជាក់លោកបន្តិច ថាតើភូមិត្រស់ នៅក្នុងឃុំបល្ល័ង្កហ្នឹងមានមន្ទីរសន្តិសុខដែរឬទេ? ហើយប្រសិនបើមាន តើមន្ទីរសន្តិសុខហ្នឹងមានឈ្មោះអ្វីដែរ?

**ឆ៖** នៅក្នុងភូមិត្រស់មានមន្ទីរសន្តិសុខ។ សន្តិសុខនោះនៅកន្លែងវត្តបារាយណ៍ជាន់ដែក។

**ស៖** <តើលោកចង់ថា>មន្ទីរសន្តិសុខហ្នឹង នៅជិតវត្តបារាយណ៍ជាន់ដែក ឬក៏នៅក្នុងបរិវេណវត្តបារាយណ៍ជាន់ដែកតែម្តង?

**ឆ៖** មន្ទីរសន្តិសុខនោះនៅក្នុងបរិវេណវត្តបារាយណ៍ជាន់ដែកតែម្តង។

**ស៖** នៅក្នុងពេលប្រជុំ ឬក៏ពេលពិភាក្សាគ្នា តើលោកមានដឹងទេថា តើ<><មានរឿងអ្វីកើតឡើង>ចំពោះអ្នកទោសដែលគេឃុំនៅក្នុងវត្តបារាយណ៍ជាន់ដែកនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៣:២១:៣០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា មិនមានទំនាក់ទំនងអ្វី<រវាង>មន្ទីរសន្តិសុខ<ក្នុង>វត្តបារាយណ៍ជាន់ដែក <និងការដ្ឋានការងារ>នោះទេ។ ហើយបន្ថែមពីលើនេះទៀត គឺចំណុចទាំងអស់នេះ វាក្រៅវិសាលភាពនៃការជំនុំជម្រះ<នៃវគ្គសវនាការនេះហើយ>។ ដូច្នេះដោយយើងពិចារណាផងដែរទៅលើពេលវេលា ព្រះរាជអាជ្ញាគួរតែបន្តទៅចំណុចផ្សេង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ យើងបានពិភាក្សាគ្នារួចមកហើយ<នៅចំពោះមុខអង្គជំនុំជម្រះហើយ> អង្គជំនុំជម្រះបានកំណត់ហើយថា យើងអាចសួរសំណួរបានពាក់ព័ន្ធទៅនឹងវត្តបារាយណ៍ជាន់ដែក។ <ខ្ញុំសួរនេះគឺមានមូលហេតុពីរ ទី១> សាក្សីផ្សេងទៀតនោះ ក៏បាននិយាយ<ភ្ជាប់>រវាងវត្តបារាយណ៍ជាន់ដែក និង<ការដ្ឋានសាងសង់នេះផងដែរ។ ហើយក៏ដូចជា>មានការបោសសម្អាតនៅក្នុងឃុំបល្ល័ង្កផងដែរ <ដែលយើងនឹងចូលដល់ក្នុងពេលបន្តិចទៀត>។ <>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា ហើយការនេះគឺពិតដូចតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិបានលើកឡើងមែន គឺយើងបានសម្រេចរួចហើយកំណត់ គឺភាពពាក់ព័ន្ធនៃបារាយណ៍ជាន់ដែកទៅនឹងអង្គហេតុទំនប់១មករានេះ។

សាក្សីឆ្លើយតបទៅនឹងសំណួរ ដែលសួរដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ប្រសិនបើចាំសំណួរ។ បើអត់ចាំទេ សូមឲ្យតំណាងសហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរសាជាថ្មីឡើងវិញ។

[១៣:២៣:០៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី សំណួរខ្ញុំអម្បាញ់មិញនេះ ខ្ញុំចង់ដឹងថា តើគេធ្វើយ៉ាងម៉េចចំពោះអ្នកទោសដែលគេឃុំនៅក្នុងវត្តបារាយណ៍ជាន់ដែក?

**លោក អ៊ុំ ជី៖**

**ឆ៖** ខ្ញុំមិនបានដែលឃើញផ្ទាល់ភ្នែកទេ ពីព្រោះថាពួថាកន្លែងសន្តិសុខៗហ្នឹង វាមិនហ៊ាននឹងដើរជិតផង។

**ស៖** តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាមួយនៅ<កៀកនឹង>ចុងរបបខ្មែរក្រហម ដែលប្រព្រឹត្តឡើងនៅវត្តបារាយណ៍ជាន់ដែកទេ?

**ឆ៖** ធ្លាប់ ខ្ញុំធ្លាប់បានចូលរួមប្រជុំ ប៉ុន្តែសន្តិសុខនោះ ដល់ពេលសារាចរគណៈ៨៧០ គេលើកលែងទោសអ្នកភ័ន្តច្រឡំចូលខ្សែ សេ.អ៊ី.អា, កា.ហ្សេ.បេ សន្តិសុខនោះគេរើចេញ ហើយគេប្រគល់ឲ្យមកសហករណ៍វិញ គេហៅទៅប្រជុំនៅហ្នឹង ហ្នឹងធ្លាប់ទៅចូល។

**ស៖** សូមអរគុណ។ ក្នុងពេលប្រជុំនោះ តើលោកមានសង្កេតឃើញ<សញ្ញាណាមួយ ឬក៏>ស្លាកស្នាម ដែលបញ្ជាក់ថា <កន្លែង>ហ្នឹងជា<កន្លែង>ដែលគេប្រើសម្រាប់សម្លាប់មនុស្ស?

**ឆ៖** ធ្លាប់ឃើញ។ ចូលទៅប្រជុំនៅក្នុងជញ្ជាំងព្រះវិហារ និងសាលាឆាន់មានឈាមប្រឡាក់ជិតដាមនៅជញ្ជាំង។ ខ្លះនៅជិតដាម មិនរលុប មិនទាន់រលុបអស់ទេ ដែលខ្ញុំចូលទៅ ហើយនិងមានកណ្តាចចាស់ៗ ខោអាវរហែកនៅតាមដីធ្លីហ្នឹងជាគរ នៅដោយដុំៗ។

[១៣:២៥:២០]

**ស៖**<>តើ<នៅតែ>មានក្លិនស្អុយ<សាកសព>ជះមកដែរទេ នៅពេលដែលលោកចូលទៅនុ៎ង?

**ឆ៖** មានក្លិនជះស្អុយ នៅមិនទាន់អស់ក្លិនទេ នៅធុំក្លិនឆ្អួលបន្តិចៗ។

**ស៖** ឥឡូវត្រឡប់មកនិយាយអំពីប្រឡាយវិញម្តង។ <ប្រឡាយនោះប្រហែលជាមិនសូវជាជ្រៅប៉ុន្មានទេ ប៉ុន្តែ> តើមានគ្រោះថ្នាក់អ្វីកើតឡើងទេ ឧទាហរណ៍ដូចជាមានបាក់ដីដែល<កប់ ឬធ្វើឲ្យរបួសកម្មករដែលធ្វើការនៅទីនោះអី>ទេ?

**ឆ៖** ក្នុងប្រឡាយទាំងមូលហ្នឹងមានគ្រោះថ្នាក់ដូចថារ៉ៃឆ្នូន រ៉ៃអីទៅ គេថាដុំថ្មធ្លាក់ត្រូវកម្មកររងរបួសខ្លះ។ មិនចាំមិនអស់ទេ ប៉ុន្តែមានរងរបួសខ្លះ។

**ស៖** នៅពេលដែលមានរបួសហ្នឹង តើគេមាននាំអ្នកដែលរបួសហ្នឹងទៅមន្ទីរពេទ្យទេ? ហើយនៅពេលក្រោយមកហ្នឹង អ្នករបួសហ្នឹងមានត្រឡប់មកធ្វើការនៅអង្គភាពដើមរបស់ខ្លួនវិញទេ?

**ឆ៖** ក្រោយរបួសហ្នឹង គឺប្រធានមុខព្រួញហ្នឹងៗ គេឲ្យយកទៅពេទ្យ។ ប៉ុន្តែពេលចេញទៅពេទ្យបាត់ ដល់ចេញទៅ មិនដឹងជាទៅណាទៅណី ក៏ខ្ញុំមិនបានជាចាប់អារម្មណ៍ដែរអាហ្នឹង។

**ស៖** អម្បាញ់មិញនេះលោកនិយាយថា គេសង់<ខ្ទម>ស្នាក់នៅ<សម្រាប់កម្មករ>ហ្នឹងនៅជិតប្រឡាយ តើលោកអាចរៀបរាប់អំពី<ខ្ទម>ស្នាក់នៅហ្នឹងបន្តិចបានទេ? ហើយគេសង់ពីអ្វី ហើយជម្រកហ្នឹងរឹងមាំទេ?

[១៣:២៧:៤៨]

**ឆ៖** ជម្រកដែលគេសង់ឲ្យពួកកងចល័តនៅ គឺគេសង់អំពីកូនឈើ ហើយក្រងចំបើងប្រក់ឲ្យ ហើយកន្លែងដេកនៅ ខ្លះដេកលើផ្ទៃរ ខ្លះមានអង្រឹងដេកចងអង្រឹង ខ្លះមានកន្ទេលក្រាលកន្ទេលដេក ហើយកើយខ្នើយកើយមានបាឡូកើយជំនួសប៉ុណ្ណឹង។

**ស៖** លោកធ្វើការនៅទីនោះនៅ<កម្រិតខ្ពស់ក្នុង>រដូវវស្សា អ៊ីចឹងតើដំបូលហ្នឹងជិតទេ? មានទឹកភ្លៀងអីអាចជ្រាបចូលបានទេ?

**ឆ៖** ទឹកភ្លៀងមិនអាចគត់បានទេបើភ្លៀងធំ បើភ្លៀងតិចៗបានគត់បាន បើភ្លៀងធំគឺលិចទទឹកគ្មានកន្លែងដេកទេ។

**ស៖** តើលោកអាចរៀបរាប់អំពីសម្លៀកបំពាក់របស់កម្មករបានទេ? តើសម្លៀកបំពាក់ហ្នឹងស្ថិតនៅ -- មានសភាពបែបណាដែរ?

**ឆ៖** កាលពីសម័យនោះ បើនិយាយពីសម្លៀកបំពាក់គឺខ្វះខាតជាទីបំផុត គឺថាម្នាក់មានតែមួយកំប្លេ ហើយក៏មិនបានគត់មត់ ខ្លះក៏រហែក ខ្លះក៏អីទៅ ហើយចម្រុះពណ៌មាន កាលហ្នឹងគេបើកក្រណាត់ខូវប៊យអីឲ្យអ៊ីចឹងទៅ ខ្លះខ្មៅទៅ ខ្លះប្រផេះទៅ។

**ស៖** ចុះរបបអាហារវិញ <តើលោកអាចរៀបរាប់ពីគុណភាព និងបរិមាណនៃអាហារបានទេ?> ហើយអាហារហ្នឹងអាចឲ្យកម្មករមានកម្លាំងគ្រប់គ្រាន់ដើម្បី<បម្រើការងារ>ទេ?

**ឆ៖** ចំណែកអាហារវិញ ពេលព្រឹកគេឲ្យស៊ីបាយ ពេលល្ងាចស៊ីបបរ ប៉ុន្តែនិយាយពីសម្ល ការហូបចុកវាមិនគ្រប់គ្រាន់ទេ ពីព្រោះមានត្រកួនស្ងោរ និងជាមួយត្រីកញ្ចុះប្រឡាក់ឲ្យតូចៗហ្នឹង។ ជួនកាលយូរៗគេឲ្យសាច់ជ្រូកម្ដងអីអ៊ីចឹងទៅ។

[១៣:៣០:៤៨]

**ស៖** ចុះជនជាតិចាមដែលធ្វើការនៅក្នុងកងផ្សេងៗ<នៅពេល>ហ្នឹង <នៅពេលណាដែលមាន

សាច់ជ្រូកហូប តើពួកគេត្រូវតែហូបសាច់ជ្រូកឬ? ទោះបីមិនសូវមានសាច់នេះក៏ដោយ។>

**ឆ៖** ចាមសម័យហ្នឹង បើអ្នកណាគេកាន់បានគេអត់ហូបទេ សុខចិត្តៗហូបអំបិល។ បើអ្នកខ្លះគ្នាហេវ ចេះតែហុតៗទឹកទៅ ប៉ុណ្ណឹងគ្រាន់។

**សៈ** ចុះទឹកសម្រាប់កម្មករផឹក<វិញ> ជាទឹកស្អាតមានអនាម័យ <អាចផឹកបាន> ឬក៏យ៉ាងម៉េច?

**ឆ៖** ទឹកដែលកម្មករហូបគឺគ្មានអនាម័យទេ គឺថាលើក -- ដងទឹកប្រឡាយហ្នឹងឯងឲ្យផឹក គ្មានទេអនាម័យ គឺថាទឹកប្រឡាយដែលមានអនាម័យ ងូតផង ផឹកផងនៅកន្លែងដដែលហ្នឹង។

**សៈ** តើលោកអាចជម្រាបបានទេថា បុគ្គលិកពេទ្យ<ប្រចាំការ>នៅកន្លែងធ្វើការហ្នឹងមានជំនាញច្បាស់លាស់ទេ ហើយមានថ្នាំពេទ្យគ្រប់គ្រាន់សម្រាប់ព្យាបាលអ្នកជំងឺទេ?

**ឆ៖** នៅសម័យហ្នឹង និយាយពីក្រសួងពេទ្យវិញ គឺគ្មានជំនាញទេ គឺរកពីភូមិទៅក្មេងតូចៗអាយុ១៥, ១៤, ១៨ឆ្នាំអីហ្នឹង យកទៅរៀន១០ថ្ងៃ ឬក៏កន្លះខែហ្នឹង ក៏ឃើញចេញមកចាក់វិញ ដើរតាមព្យាបាលតាម។ ហើយបើនិយាយពីថ្នាំសង្កូវហ្នឹងវា គេចម្រាញ់ពីថ្នាំធម្មជាតិ មិនមានថ្នាំទៅតាមធាតុដើមដូចសព្វថ្ងៃទេ គឺឃើញមូលៗហ្នឹង គេថាអាចម៍ បើយើងចំណាំតែអ្នកខ្លះថា អាចម៍ទន្សាយៗ ឲ្យតែថ្នាំអស់ហ្នឹង លេងប្រើនឹងដបទឹកក្រូចច្រក ពណ៌ក្រហម ពណ៌អីហ្នឹង គេថាបេខូ បេអី គឺហ្នឹង គ្រាន់ប៉ុណ្ណឹង។

[១៣:៣៣:១៨]

**សៈ** តើមានអ្នកណាដែលឈឺធ្ងន់ពេក ហើយគេបញ្ជូនទៅមន្ទីរពេទ្យទេ? ហើយក្រោយពេលបញ្ជូនទៅមន្ទីរពេទ្យហើយហ្នឹង មានត្រឡប់មកវិញទេ ឬក៏លោកមិនឃើញមានត្រឡប់មកវិញទេ?

**ឆ៖** សម័យហ្នឹង បើអ្នកណាឈឺធ្ងន់ គឺបញ្ជូនទៅមន្ទីរពេទ្យស្រុក របស់សម័យហ្នឹង។ ហើយអ្នកខ្លះក៏អាចជាមកវិញទៅ អ្នកខ្លះក៏ស្លាប់នៅនឹងកន្លែងពេទ្យហ្នឹងទៅ។

**សៈ** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីប្រធានបទមួយផ្សេងទៀត គឺរឿងហេតុដែលកើតឡើងចំពោះប្រជាជនថ្មីនៅក្នុងភូមិរបស់លោក<គឺភូមិជ័យមង្គល>។ តើលោកធ្វើការនៅភូមិជ័យមង្គល ឃុំបល្ល័ង្ក ក្នុងចន្លោះឆ្នាំ<៧៥> ដល់ឆ្នាំ៧៩ ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោក អ៊ុំ ជី!

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក អ៊ុំ ជី៖**

**ឆ៖** សម័យហ្នឹង ខ្ញុំអត់មានការងារអីទេ ខ្ញុំជាយុវជន សម្រាប់តែគេប្រើឲ្យធ្វើការលើកភ្លឺៗស្រែ លើកអី។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** នៅពេលដែលលោកធ្វើការនៅភូមិជ័យមង្គល តើលោកឃើញមានប្រជាជនថ្មីដែលគេ <បញ្ជូនទៅ និងរស់នៅក្នុង>ភូមិរបស់លោកហ្នឹងទេ? ហើយបើមាន ប្រហែលជាប៉ុន្មាននាក់ដែរ?

[១៣:៣៥:១៩]

**ឆ៖** កាលពីសម័យហ្នឹងឃើញគេ ចិត -- រ៉ៃដាច់៧៥ ឃើញគេបញ្ជូនប្រជាជនថ្មីទៅក្នុងភូមិខ្ញុំ ប្រហែលជាទាំងជនជាតិចាម ទាំងជនជាតិពួកខ្មែរយើង ចិន វាប្រហែលជា២០គ្រួសារហ្នឹង។

**ស៖** តើប្រជាជនថ្មីមកដល់ភូមិរបស់លោកហ្នឹងមានប៉ុន្មានគ្រួសារដែរ?

**ឆ៖** ខ្ញុំ សម័យហ្នឹងខ្ញុំចាំមិនច្បាស់ទេ ពីព្រោះខ្ញុំមិនអ្នកចុះស្ថិតិមិនអី។ ខ្ញុំគិតតែពីធ្វើការ ទៅតាមផ្នែកយុវជន។

**ស៖** សូមអរគុណ។ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/5265 នៅទំព័រជាភាសាខ្មែរ 00271396, ជាភាសាបារាំង <0048293>, ជាភាសាអង់គ្លេស 00282345។ លោកបាននិយាយ<នៅទំព័រហ្នឹងថា> មានការជម្លៀស<ចេញពីភ្នំពេញ>មកភូមិរបស់លោកហ្នឹងប្រហែលជា២០គ្រួសារ <តើវាជួយដល់ការចងចាំរបស់លោកទេ អំពីចំនួនគ្រួសារដែលមកពីភ្នំពេញ?>

**ឆ៖** អានេះដូចខ្ញុំនិយាយខាងដើមអំមិញ ពីព្រោះខ្ញុំមិនបានទៅចុះស្ថិតិមកអី គឺថាតាមការប៉ាន់ស្មាន ប្រហែលជា២០គ្រួសារហ្នឹង ទាំងជនជាតិចាម ទាំងជនជាតិខ្មែរយើងដែលគេជម្លៀសចេញពីទីក្រុងទៅ។

**ស៖** តើលោកអាចរៀបរាប់ដោយខ្លីបានទេថា នៅពេលទៅដល់កន្លែងនុ៎ងហើយ តើពួកគាត់ស្នាក់នៅយ៉ាងម៉េចដែរ?

**ឆ៖** មុនដំបូងគេឲ្យនៅក្រោមផ្ទះប្រជាជនចាស់ខ្លះ។ ផ្ទះណាដែលធំទៅ អាចឡើងនៅបាន។ ផ្ទះណាដែលតូច គឺនៅក្រោមផ្ទះ។

[១៣:៣៨:១៨]

**ស៖** សូមអរគុណ។ <តើ>គេមានសាងសង់ជាខ្ទមតូចៗអីសម្រាប់អ្នកទាំងអស់នុ៎ងស្នាក់នៅ

ទេ?

**ឆ៖** ដល់នៅក្រោយមក គេធ្វើជាខ្មមឲ្យនៅ នៅក្នុងភូមិហ្នឹងចែកទៅតាមកន្លែងណាដែលស្រទ្បះ គេឲ្យនៅជុំវិញ សឹងតែនឹងជុំវិញភូមិហ្នឹង។

**ស៖** <នៅពេលមួយ>ចន្លោះឆ្នាំ៧៥ ទៅដល់ដើមឆ្នាំ៧៩ <តើគ្រួសារប្រជាជនថ្មីជាមុខសញ្ញានៃការ>ចាប់ខ្លួន និងសម្លាប់<>ទេ? ខ្ញុំនិយាយ<> ក្នុងចំណោមទាំង២០គ្រួសារ<ដែលលោកបានរៀបរាប់>ហ្នឹង។

**ឆ៖** មាន ដល់ឆ្នាំ៧៧ហ្នឹង គឺសម័យហ្នឹង ដល់ឆ្នាំហ្នឹងគេមានផែនការបោសសម្អាត ប៉ុន្តែសម័យហ្នឹងខ្ញុំមិនបាននៅទេក្នុងភូមិ។ ខ្ញុំគេចាត់ឲ្យទៅធ្វើចម្ការឆ្ងាយពីភូមិ។ មិនដឹងជាអ្នកណាខ្លះទេ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ម្តងទៀត<>ទេ<អំពីកាលបរិច្ឆេទ>? ខ្ញុំឮអម្បាញ់មិញបកប្រែមកថាឆ្នាំ១៩៧០ <វាហាក់ដូចជាមិនត្រឹមត្រូវទេ> លោកអាចបញ្ជាក់ឆ្នាំម្តងទៀតបានទេ<ហើយសូមរង់ចាំរហូតដល់ក្បាលមីក្រូហ្វូនប្រតិបត្តិការ។>

**ឆ៖** ដែលគេមានផែនការបោសសម្អាតនៅក្នុងឆ្នាំ៧៧។ ខ្ញុំដូចវាក់ ប៉ុន្តែ៧៧ប្រាកដហើយអាហ្នឹង ៧៧។

[១៣:៤០:២៦]

**ស៖** ក្រោយមកលោកជាមេក្រុមដែលមានគ្នា៥០០នាក់។ <តើនៅមុន>ឆ្នាំ១៩៧៧ហ្នឹង តើលោកមានចូលរួមប្រជុំនៅថ្នាក់ឃុំ ឬក៏ថ្នាក់ស្រុកដែលគេនិយាយអំពីផែនការបោសសម្អាតហ្នឹងទេ?

**ឆ៖** ដូចខ្ញុំជម្រាបខាងដើមហ្នឹងឯង។ ឆ្នាំហ្នឹង គេចាត់តាំងឲ្យខ្ញុំទៅធ្វើចម្ការនៅឆ្ងាយពីភូមិ នៅក្នុងទឹកដីឃុំគគីរធំ ហើយចម្ងាយពីភូមិប្រហែលជា២០គីឡូជាង គឺមិនសូវ មិនដែលបានទៅមកទេ។ តិចណាស់ ទាល់តែពេលអស់ស្បៀងម្តងៗ បានមកភូមិ។ អត់ដែលបានចូលប្រជុំទេ។

**ស៖** <អរគុណ។ ខ្ញុំមិនគិតថា លោកបាននិយាយពីចំនួនគ្រួសារដែលទទួលរងការសម្លាប់នោះទេ តើលោកអាចប្រាប់យើងបានទេថាមានប៉ុន្មាន? តើនៅចាំទេ?>

**ឆ៖** ដែលខ្ញុំមកលេងភូមិ ដូចខ្ញុំជម្រាបខាងដើមហើយ ដែលអ្នកនៅជិតៗផ្ទះខ្ញុំ បាត់ខ្ញុំសួររកគេ គេថាគេៗបោសសម្អាតអស់ហើយ ហើយមានគ្រួសារប្រហែលប្រាំគ្រួសារ។

**ស៖** បើតាមលោកស្តាប់ឮ <តើអ្នកណាជាអ្នកចាប់គ្រួសារប្រាំគ្រួសារនេះ? ហើយតើមានអ្វីកើតឡើងចំពោះអ្នកចាប់>? <>

**ឆ៖** សម័យហ្នឹង តាមព័ត៌មានអ្នកស្រុកដែលខ្ញុំមកភូមិម្ដងៗ គេថា គេហៅទៅប្រជុំ ឲ្យទៅនៅភូមិថ្មី ស្រាប់តែឡានចូលមកដឹកតែម្ដង ប៉ុន្តែមិនដឹងគេដឹកយកទៅកន្លែងណា។

[១៣:៤២:៥៩]

**ស៖** <> ខ្ញុំសូមអនុញ្ញាតដកស្រង់នូវ<ចំណុចមួយនៃ>ចម្លើយរបស់លោក នៅចំពោះមុខ <អ្នក>ស៊ើបអង្កេត<នៃការិយាល័យសហចៅក្រមស៊ើបអង្កេត មានលេខ E3/5265> ជាភាសាខ្មែរគឺ <00271397>, ជាភាសាបារាំង 00482923, ជាភាសាអង់គ្លេស 00282345។ គេសួរលោកថា៖ “តើជាអ្នក -- អ្នកណាជាប្រធានសហករណ៍ ហើយអ្នកណាជាអ្នកនាំគ្រួសារទាំងប្រាំហ្នឹងទៅសម្លាប់?” លោកបានបញ្ជាក់ថា៖ “នៅសម័យ<ហ្នឹង> គឺប្រធានសហករណ៍តូចឈ្មោះ ហេង និងឈ្មោះ លាក់ ជាប្រធានសហករណ៍ធំ។ ទាំងពីរនាក់នេះ ជាអ្នកយកប្រជាជនទាំងប្រាំគ្រួសារនេះទៅសម្លាប់។ ក្រោយមកអ្នកទាំងពីរ ក៏ត្រូវបានគេចាប់យកទៅសម្លាប់ដែរ នៅក្នុងឆ្នាំ១៩៧៧ហ្នឹង។” <បញ្ចប់ការដកស្រង់> តើលោកនៅរក្សាចម្លើយហ្នឹងដដែលឬ?

**ឆ៖** ចម្លើយហ្នឹងពិតៗមែន។ ខ្ញុំនិយាយនេះ គឺថាវាមិន -- ហួសពីការពិតបន្តិចអំមិញ ប៉ុន្តែវាដូចវាវាក់ នៅចងចាំវាដូចជាប៉ុន្មានយូរឆ្នាំហើយ។ ប៉ុន្តែសម័យហ្នឹង គឺប្រធានសហករណ៍តូច ហេង, ធំលាក់។ ដល់ពេលចុងក្រោយ ចាប់ពួកហ្នឹងអស់ ផែនការគេបោសសម្អាតកម្មាភិបាលទៀត គេចាប់ហេង, លាក់ ហ្នឹងទៅបាត់ទៀតទៅ។

**ស៖** តើលោកដឹងទេថា អ្នកទាំងពីរនេះ ឬក៏អ្នកផ្សេងទៀតហ្នឹង ត្រូវបានអ្នកដែលមកពីភូមិភាគផ្សេងទៀតហ្នឹងមកធ្វើការជំនួស មានអីចឹងទេ?

[១៣:៤៥:០២]

**ឆ៖** ក្រោយពីការចាប់អ្នកពីរនាក់ហ្នឹងអស់ទៅ បានចេញមកពីពួកនិរតីមកគ្រប់គ្រងនៅក្នុងឃុំបល្ល័ង្កហ្នឹង នឹងស្រុកបារាយណ៍យើងហ្នឹង។

**ស៖** <ខណៈដែលយើងនិយាយពីប្រធានបទរចនាសម្ព័ន្ធនៃបទបញ្ជា>នៅក្នុងតំបន់របស់លោក <អីចឹង យើងនឹងពិភាក្សាពីខ្សែសង្វាក់ថ្នាក់ឃុំ និងស្រុក។> ខ្ញុំចង់ដឹងថា បើតាមលោកដឹង តើអ្នកណាជាប្រធានតំបន់៤២ <ចន្លោះ>ឆ្នាំ១៩៧៧ និង១៩៧៨នោះ?

**ឆ៖** ក្នុងឆ្នាំ៧៧ និង៧៨ ប្រធានតំបន់គឺឈ្មោះ អឿន។

**ស៖** តើគាត់ជាសាច់ញាតិរបស់ កែ ពក មែនទេ? ឥឡូវខ្ញុំសូមសួរអីចេះវិញ ជាដំបូង តើលោក

ស្គាល់ កែ ពក ទេ?

**ឆ៖** ធ្លាប់តែឮឈ្មោះ មិនដែលបាននៅជិតគាត់ ឬទៅជួបធ្វើមីទ្ទិងជាមួយគាត់។ គ្រាន់តែឮតែឈ្មោះ កែ ពក១ ប្រធានតំបន់ មិនដែលបានទៅជិតទេ។

**ស៖** <អរគុណ។>នៅក្នុងឆ្នាំ៧៧, ៧៨<នៅ>មុន អឿន តើលោកស្គាល់លេខាតំបន់៤២ ដែលឈ្មោះ ចាន់ ម៉ុន ហៅ តុល ទេ <ដែលជាលេខាតំបន់>?

**ឆ៖** ខ្ញុំមិនដែលស្គាល់ទេ។ គ្រាន់តែឮតែឈ្មោះ តុល១ ហ្នឹងប៉ុន្តែមិនដែលស្គាល់ផង មិនដែលទាំងឃើញមុខផង។

[១៣:៤៧:២០]

**ស៖** តើលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះឈ្មោះ តុល នេះទេ?

**ឆ៖** ខ្ញុំមិនដឹងទេ។ ស្រាប់តែបាត់ យូរទៅក៏បាត់ឈ្មោះទៅ ក៏មិនដឹងជារឿងស្អី ផ្ទៃក្នុងរបស់បក្សគេ ខ្ញុំអត់ដឹងទេ។

**ស៖** <និយាយកៀកនឹងកម្រិតរបស់លោកម្តងគឺ ថ្នាក់>ស្រុកបារាយណ៍ តើលោកនៅចាំ<ឈ្មោះ>លេខា<ស្រុក>ផ្សេងៗ <ហើយនិងអ្នកដែលឡើងកាន់តំណែង>បន្តបន្ទាប់គ្នា<ក្នុង>ស្រុកបារាយណ៍ ចន្លោះពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ទេ?

**ឆ៖** ក្នុងហ្នឹង ខ្ញុំចាំតែឆ្នាំដែលចុះធ្វើការដ្ឋានហ្នឹង គឺឈ្មោះ មូល។ គាត់ទៅគ្រប់គ្រងដឹកនាំធ្វើមីទ្ទិង ធ្វើប្រឡាយឲ្យដំបូង។ ក្រោយធ្វើបានប្រហែលជាបីបួនខែ បានដូរឈ្មោះ មូល ហ្នឹងទៅនៅតាំងគោកវិញ បានឈ្មោះ ប៉ូច ហ្នឹងគាត់ចូលមកបន្ត ទល់តែនឹងចប់ប្រឡាយហ្នឹង។

**ស៖** តើ ប៉ូច ហ្នឹងមកពីភូមិភាគនិរតីមែនទេ?

**ឆ៖** បាទ ឮថាមកពីភូមិភាគនិរតី។ ហើយខ្ញុំកាលសម័យហ្នឹង មិនហ៊ាន ដែលទៅហ៊ានសួរគេដឹងអ្នកណា គេថានិរតី១ ចេះតែថានិរតីហ្នឹងគេទៅ។ មិនដឹងមកពីណា។

**ស៖** តើមានការផ្លាស់ប្តូរទេ ពាក់ព័ន្ធទៅនឹងជីវភាព<ប្រចាំថ្ងៃរបស់>ប្រជាជន<ឬទេ> <ក្រោយ>ពេល<កម្មាភិបាលភូមិភាគនិរតី> មកដល់អ៊ីចឹង? ហើយគេមានប្តូរកម្មាភិបាលចាស់ៗទេ? លោកមានឃើញការប្រែប្រួលទេ ឧទាហរណ៍ដូចជា ការបញ្ជា<ផ្សេងពីមុន> ការណែនាំ<ថ្មី> ហើយនិងលក្ខខណ្ឌរស់នៅរបស់ប្រជាជន<ផ្សេងពីមុនទេ><>?

[១៣:៤៩:៣៩]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** ក្រោយពីការផ្លាស់ប្តូរកម្មាភិបាលពីក្រៅមកក្នុង ស្របពេលនោះដោយមានសារាចរណែនាំរបស់បក្ស មិនដឹងពីថ្នាក់ណាច្បាស់ទេ គឺថាថ្នាក់៨៧០ បានណែនាំលើកលែងទោស អ្នកភ័ន្តច្រឡំចូលខ្មែរ សេ.អ៊ី.អា, កា.ហ្សេ.បេ លើកលែងទោស គឺថាទុកជាប្រជាពលរដ្ឋធម្មតាទាំងអស់គ្នា។ បាទប៉ុណ្ណឹង។

**សៈ** តើសារាចររបស់បក្សហ្នឹង ជាអត្ថបទលាយលក្ខណ៍ជាអក្សរ ហើយរូបលោកផ្ទាល់បានអានដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានអានទេ។ គ្រាន់តែពេលវគ្គដែលសម្រាកក្នុង១០ថ្ងៃម្តងនោះ មេឃុំគេលើកពីសារាចរហ្នឹង គ្រាន់តែបានស្តាប់។ អានមិនដែលបានអានទេ។

**សៈ** ហើយពេលប្រជុំហ្នឹងប្រជុំនៅកម្រិតណាវិញ? កម្រិតឃុំ ស្រុក ឬក៏តំបន់?

**ឆ៖** ប្រជុំនោះ ថ្នាក់ឃុំគេទទួលបញ្ជាពីថ្នាក់លើ។ ដល់ពេលបើកវគ្គប្រជុំនៅពេលសម្រាក១០ថ្ងៃម្តងៗ គេប្រកាសជាទូទៅប្រាប់ប្រជាពលរដ្ឋ ប្រាប់អ្នកស្រុកទាំងអស់ដែលទៅធ្វើមីទ្ទិងរួមគ្នា ត្រូវតម្រូវឲ្យធ្វើក្នុងពេលថ្ងៃសម្រាកហ្នឹង។

**សៈ** <>តើលោកដឹងថារយៈពេល<ហ្នឹងយូរប៉ុនណា>ដែរ<? មុនពេលការសាងសង់ ឬការ>ជីកប្រឡាយហ្នឹងចប់<ទើប>លោកបានទទួលសារាចរហ្នឹង? <>

[១៣:៥២:២១]

**ឆ៖** ឆ្នាំ -- ហ្នឹងមិនទាន់ចប់ទេប្រឡាយ វានៅតែធ្វើ ប៉ុន្តែដែលបានស្តាប់ កាលសម័យហ្នឹងក្នុងវគ្គ១០ថ្ងៃ គេឲ្យសម្រាកមួយថ្ងៃ គេទៅប្រជុំ ហើយអ្នកស្រុកហ្នឹងគេប្រកាសទាំងអស់គ្នា ហើយក៏មិនចាំច្បាស់ ក្នុងខែណាក៏អត់ចាំច្បាស់ដែរ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ឥឡូវខ្ញុំសូមកំណត់អត្តសញ្ញាណឯកសារ<នេះ>ជាមួយលោកសាក្សី។> លោកប្រធាន ខ្ញុំសុំអនុញ្ញាត<បញ្ចាំង>ឯកសារ E3/763 <នៅត្រង់ទំព័រដែលខ្ញុំជូនទៅលោកប្រធាន។> ឯកសារ<នេះ>ចុះថ្ងៃទី២០ មិថុនា ឆ្នាំ១៩៧៨ ដែលចេញមកពីគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ ខ្ញុំសុំឱ្យបញ្ចាំងទំព័រដំបូង ទំព័រទី១ ដែលមានចំណងជើងឯកសារហ្នឹង។ ហើយខ្ញុំសុំអានចំណងជើងឯកសារហ្នឹង។ លោកសាក្សី លោកមានអត្ថបទហ្នឹងហើយ។ ចំណងជើងដូចតទៅនេះ៖ “សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ស្តីអំពីគោលនយោបាយរបស់បក្សចំពោះ<ជនបន្ទំខ្លួនដែលចូលដៃចូលជើងជាមួយ> សេ.អ៊ី.អា <ឬជា>ភ្នាក់ងារយួន ឬចូល<ដៃចូលជើងជាមួយ> កា.ហ្សេ.បេ <ហើយ>ប្រឆាំង<នឹងបក្ស ប្រឆាំងនឹងបដិវត្តន៍ ប្រឆាំងនឹងប្រជាជន ហើយដែលប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។>

[១៣:៥៤:១៣]

លោកសាក្សី <យើងចង់ឱ្យលោកចាប់អារម្មណ៍ទៅនឹងផ្នែក>ដែលមានគូសបន្ទាត់ពីខាងក្រោមនេះ គឺថា<> មានប្រភេទ<មនុស្ស>មួយចំនួនដែល<>ត្រូវបាន<កំណត់ទុក។> ផ្នែកទី១ នោះគឺទាក់ទងនឹង<>អ្នកចូល<ដៃជើងជាមួយ> សេ.អ៊ី.អា <វៀតណាម> ឬក៏ចូល<ដៃជើងជាមួយ> កា.ហ្សេ.បេ ចន្លោះឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៦៧។ ហើយផ្នែកទី២ គឺចំពោះអ្នកចូល<ដៃជើងជាមួយក្រុមខាងលើនេះ> ចន្លោះឆ្នាំ៦៨ និងឆ្នាំ៧០។ ហើយផ្នែកទី៣ គឺឆ្នាំចន្លោះឆ្នាំ៧០ និង៧៥។ បាទ ឯកសារនេះទាក់ទងទៅនឹងប្រភេទមនុស្សទាំងបី<ប្រភេទ>នេះ បក្សថាគេមិនថ្កោលទោសមនុស្សទាំងបីប្រភេទនេះទេ<>ក្រោមលក្ខខណ្ឌដែលថា ពេលថ្ងៃក្រោយពួកគេ<មិនប្រព្រឹត្តអំពើក្បត់ណាមួយ>ទៀត។ តើលោកចាំចំណុច<ទាំង>នេះដែរឬទេ? <តើលោកចាំ>គឺថាទាក់ទងទៅនឹងអ្នកដែលបានចូល សេ.អ៊ី.អា មុនឆ្នាំ១៩៧៥ លោកមានបានឮគេនិយាយអំពីបញ្ហាហ្នឹងទេ មុនពេលប្រជុំ?

**លោក អ៊ុំ ជី៖**

**ឆ៖** ខ្ញុំមិនដឹងទេ។ គ្រាន់តែឮតែខ្សែ សេ.អ៊ី.អា មិនដឹងជាយ៉ាងម៉េចផង កា.ហ្សេ.បេ មិនដឹងជាយ៉ាងម៉េចផង អត់ដឹង។ គ្រាន់តែឮគេថា អ្នកចូលហ្នឹងឱ្យលើកលែងទោសៗ។

**ស៖** បាទ ខ្ញុំសូមដកស្រង់ចំណុចមួយទៀត<នៃឯកសារនេះ>។ ទាក់ទងទៅនឹងប្រភេទទី៤ ដែលមានសរសេរនៅក្នុងសារាចរនេះដែរ គឺចំពោះអ្នកដែលចូល<ដៃជើងជាមួយ> សេ.អ៊ី.អា <វៀត-ណាម> ឬចូល<ដៃជើងជាមួយ> កា.ហ្សេ.បេ នៅចន្លោះឆ្នាំ១៩៧៥ និង៧៨។ ហើយយើងឃើញប្រភេទមនុស្សបែបនេះ នៅទំព័រទី២ នៃភាសាទាំងអស់ ឯកសារជាភាសាផ្សេងៗ។ <> ខ្ញុំសូមដកស្រង់ <ការបែងចែកប្រភេទដំបូងគេនៃក្រុមទី៤នេះ> <>គេនិយាយដូចតទៅនេះ៖ “គឺថាអ្នករឹងរូស បន្តធ្វើសកម្មភាពប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងនឹងរដ្ឋអំណាចបដិវត្តន៍ <ឬក៏>កម្មករ កសិករ

ប្រឆាំងនឹងរបបសម្ពហភាពសង្គមនិយម ប្រឆាំងនឹងប្រជាជនកម្ពុជា និងប្រឆាំងកម្ពុជាប្រជាធិបតេយ្យ ពួកទាំងអស់នេះសុទ្ធតែមានទោស ពីព្រោះអ្នកទាំងនោះ បានធ្វើសកម្មភាពក្បត់ដោយចេតនា ដោយគោលជំហរប្រឆាំងដាច់ខាត ដោយគោលជំហរពេញចិត្តពេញថ្លើមបម្រើ<ស្រលាញ់>ខ្មាំងសត្រូវ<ដូច>ជា សេ.អ៊ី.អា <>យួន<ហើយនិង> កា.ហ្សេ.បេ។ <មនុស្សប្រភេទនេះ>គេបែងចែកព្រំដែនរបស់គេ<>ច្បាស់ហើយ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជាត្រូវតែកម្ចាត់<ពួកនេះចោល>។” សូមបញ្ចប់ការដកស្រង់។ តើលោកមានចាំប្រភេទមនុស្ស<ជាក់លាក់>នេះទេ?

[១៣:៥៧:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា <វាមានប្រយោជន៍ណាស់បើសិន>សហព្រះរាជអាជ្ញា<>អាននូវកថាខណ្ឌបន្ទាប់ទៀត។ <ខ្ញុំនឹងអានជំនួសសហព្រះរាជអាជ្ញា ដោយសារថាក្នុងអត្ថបទនិយាយថា “ចំពោះ>បុគ្គលណាដែលឈប់ធ្វើសកម្មភាពក្បត់ចាប់ពីខែកក្កដា ៧៨នេះតទៅ ហើយខិតខំ<កសាងខ្លួន> ខិតខំបំពេញភារកិច្ចបដិវត្តន៍ <បុគ្គលបែបនេះ>មិនមានទោសពៃរ៍ទេ។

**លោក គង់ សំអុន៖**

បាទ លោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរចុងក្រោយនេះរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។ ដោយហេតុថា ចម្លើយរបស់សាក្សី គាត់បានបញ្ជាក់ហើយថា គាត់អត់បានដឹងពីខ្លឹមសារនៃសារាចរហ្នឹងច្បាស់ទេ។ សូម្បីតែពាក្យថា កា.ហ្សេ.បេ ឬ សេ.អ៊ី.អា ក៏គាត់មិនយល់ដែរ។ ដូច្នេះការសួរសំណួរបន្ថែមទៀតនេះ គឺធ្វើឱ្យសាក្សីឆ្លើយស្មានៗតែប៉ុណ្ណោះបាទ។ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ គាត់ថា ជាដំបូងគេអានសារាចរ<>ណែនាំនេះ ឱ្យគាត់ស្តាប់។ <ខ្ញុំប្រុងតែនឹងចូលទៅកថាខណ្ឌទី២ហើយ តែខ្ញុំចង់សួរមួយសំណួរភ្ជាប់ទៅ>កថាខណ្ឌទី១<សិន។ ខ្ញុំ>មិនទាន់ទាំងបានសួរផង <គេជំទាស់ទៅហើយ ទាំង>ខ្ញុំមិនទាន់ទាំងចោទសំណួរលើកថាខណ្ឌដែលខ្ញុំទើបតែអានឱ្យគាត់ស្តាប់ផង។ អ៊ីចឹង ខ្ញុំសូមសួរសំណួរទៅគាត់។<>

[១៣:៥៩:៣៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតាំងសំណួរសិនទៅ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** បាទ ដើម្បីសង្ខេប អ៊ីចឹងនៅក្នុងប្រភេទទី៤នេះ តើមានការបែងចែក<>រវាងប្រភេទទី១ ដែលខ្ញុំអានអម្បាញ់មិញ<ទេ> គឺថាអ្នកដែល<>នៅតែ<ធ្វើសកម្មភាព>បន្តក្បត់ ហើយនិងប្រភេទទី ២ គឺជាអ្នកដែល<បញ្ឈប់សកម្មភាព>ក្បត់ចាប់ពីខែ៧ ឆ្នាំ១៩៧៨។ អ៊ីចឹង តើលោកមានចាំទេ នៅសម័យនោះ<យោងទៅតាមបក្ស>មានប្រភេទមនុស្ស<មួយ>ដែលត្រូវកម្ទេច<>ទោះបី<>ក្រោយពេលចេញ<សេចក្ដីណែនាំ>នេះហើយក៏ដោយ <ព្រោះថា ពួកគេនៅបន្តសកម្មភាពប្រឆាំងបក្ស>?

**ឆ៖** ក្រោយពីចេញសារាចរហ្នឹងមក គឺថាមនុស្សដែលប្រធានមុខព្រួញមួយៗ តែធ្វើខុសគោលការណ៍គេ គឺថាគេនៅតែចាប់ហើយ ប៉ុន្តែគេលើកលែងទោសប្រជាពលរដ្ឋឲ្យមានសិទ្ធិសេរីភាពលើសពីកាលដែលពីមុនចេញសារាចរហ្នឹង។

**ស៖** បាទ ដើម្បីបញ្ចប់ <ដោយសារខ្ញុំគ្មានពេលច្រើនសួរប្រធានបទនេះទាំងអស់នោះទេ> ក្រោយពីពេលចេញសារាចរនេះហ្នឹង តើលោកបានសង្កេតឃើញថា មានកម្មាភិបាល<ម្នាក់> ឬ <ច្រើន>នាក់នៅឃុំរបស់លោកឬស្រុករបស់លោកនោះ ត្រូវបានគេចាប់ខ្លួន<>ដែរឬទេ?

**ឆ៖** ក្នុងឃុំរបស់ខ្ញុំមិនដែលទេ។ មិនដែលមានចាប់ទេ ក្រោយពីចេញជាសារាចរហ្នឹង។ ឮតែពាក្យមិនពិត មិនដែលបានឃើញផ្ទាល់ភ្នែក ចាប់បន្តៗ គឺអត់ដែលឃើញ។ គ្រាន់តែឮគេថា អាហ្នឹងវាមិនយកជាកត្តាទេ អាហ្នឹងវា គ្រាន់ប៉ុណ្ណឹង។

[១៤:០១:៥៧]

**ស៖** បាទ សូមអគុណ។ ប៉ុន្តែ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកបាន<ឮ>គេនិយាយអំពីអ្វីខ្លះ <>ទាក់ទងទៅនឹងការចាប់ខ្លួន ក្រោយពេលដែលមានចេញសារាចរហើយនេះ?<>

**ឆ៖** ឮនិយាយតែ ដែលនាំប្រជាពលរដ្ឋធ្វើការបែកឆ្វេង មិនតាមគោលការណ៍របស់គេ គេចាត់ទុកជាខ្មាំង។ ឮតែប៉ុណ្ណឹងឯង យល់តែប៉ុណ្ណឹងឯង អត់យល់ទៀតផង។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់ត្រឹមណេះតែម្តង ដោយសារពេលវេលាតិច។ សូមអរគុណលោក

ប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ សូមអនុញ្ញាតផ្ទេរសិទ្ធិនេះជូនលោកមេធាវី ឡោ ជុនធី ដើម្បីសួរជំនួសមេធាវីនាំមុខ។ សូមលោកប្រធានអនុញ្ញាត សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី ឡោ ជុនធី!

[១៤:០៣:២២]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះទាំងមូល ហើយសូមជម្រាបសួរលោកសាក្សីនៅពេលនេះ។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរបន្ថែមនូវអ្វី ដែលលោកបានទទួលនូវព័ត៌មាននៃការចងចាំដែលបានកើតឡើងនៅក្នុងឆ្នាំ១៩៧៥ ទៅដល់៧៩។ សំណួររបស់ខ្ញុំ គឺចង់ផ្តោតទៅលើថា តើនៅជិតៗតំបន់របស់លោកហ្នឹង តើមានមន្ទីរសន្តិសុខមួយដែលឈ្មោះហៅថា "សារិកាកែវ" ហ្នឹងដែរអត់ទេ? តើលោកមានបានដឹងព័ត៌មានហ្នឹងទេបាទ?

**លោក អ៊ុំ ជី៖**

**ឆ៖** ខ្ញុំមិនដឹងទេ ពីព្រោះហ្នឹងនៅឃុំរបស់គេ គឺឃុំចើងដើង អ៊ីចឹងអត់ដឹង។

**ស៖** បាទ អរគុណ។ គឺចំណុចមួយទៀត ថាតើនៅពេលដែលលោកបានទៅលើកប្រឡាយហ្នឹងតើមាន -- អម្បាញ់មិញគេសួរថាតើប្រតិភូបរទេសអីទៅទស្សនកិច្ចដែរឬទេ? លោកថា អត់មានទេ។ ប៉ុន្តែលោកបានឆ្លើយថា មានគណៈតំបន់ ឬមួយគណៈស្រុកអីចុះទៅត្រួតពិនិត្យទីនោះ។ ខ្ញុំចង់ដឹងថា តើគណៈតំបន់ គណៈស្រុកនៅពេលនោះ ដែលបានចុះទៅនោះ គាត់អាចស្គាល់ឈ្មោះពួកគាត់ទេបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកសាក្សី!

[១៤:០៥:៣២]

**លោក អ៊ុំ ជី៖**

**ឆ៖** គណៈតំបន់ដែលចុះទៅត្រួតពិនិត្យហ្នឹងឈ្មោះ អឿន ឯងហើយនិងគណៈស្រុកមុនដំបូងឈ្មោះ មូល ដល់ទី២ឈ្មោះ ប៉ូច។ ស្គាល់ប៉ុណ្ណឹងឯង។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** បាទ អរគុណ។ មួយទៀត ថាតើនៅពេលដែលលោកថា លោកជាប្រធានកងនៅទីនោះ តើនៅពេលដែលគេបែងចែកការងារឲ្យធ្វើ ការបែងចែកការងារឲ្យធ្វើនោះ តើការបែងចែកការងារនោះគេដាក់កំណត់រយៈពេលមួយថ្ងៃ ឬមួយគេដាក់កំណត់យ៉ាងដូចម្ដេច ឲ្យការងារធ្វើទៅអ្នកដែលលើកទំនប់ហ្នឹង?

**ឆ៖** គឺគេកំណត់ពេល ពេលព្រឹកគឺម្ដង ល្ងាចម្ដង ប៉ុន្តែក្នុងមួយម៉ែត្រគូបហ្នឹង គេគិតក្នុងមួយថ្ងៃមួយព្រឹកគឺកន្លះ -- មួយម៉ែត្រកន្លះម៉ែត្រគូប ល្ងាចកន្លះម៉ែត្រគូប។

**ស៖** ចុះពេលដែលធ្វើការហើយ នៅពេលនោះគេបែងចែករបបអាហារ តើរបបអាហារក្នុងមួយថ្ងៃហ្នឹង យើងបានទទួលយ៉ាងដូចម្ដេចដែរ?

**ឆ៖** ក្នុងរបបអាហារ ដូចខ្ញុំនិយាយខាងដើមអ៊ីចឹង មិនបានគ្រប់គ្រាន់ទេ គឺពេលព្រឹកហូបបាយល្ងាចបបរ។

[១៤:០៧:២៨]

**ស៖** អម្បាញ់មិញ បានលើកឡើងពីស្ថានភាពអនាម័យដែរ។ ខ្ញុំចង់ដឹងថាតើអនាម័យនៅទីនោះដូចមានកន្លែងអីបត់ជើងបត់ដៃអីត្រឹមត្រូវដែរអត់ទេ?

**ឆ៖** កន្លែងអនាម័យបត់ជើងបត់ដៃ គឺជីកតាមវាលស្រែ បាំងធាងត្នោតពីរធាង ឬបីធាង គ្រាន់ប៉ុណ្ណឹង។ ដល់ពេលធ្វើយូរៗទៅ វាពេញទៅក៏ទឹកភ្លៀងមកខ្លាំងចូលទៅ ក៏គ្មាន គេឈប់ប្រើទៅ ដើរទៅតាមគុម្ពោតតាមអីទៅ។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀតដែលពាក់ព័ន្ធថា មានអ្នកជំងឺឈឺ។ ហើយលោកអម្បាញ់មិញបានលើកឡើងថា មានពេទ្យដែរប៉ុន្តែពេទ្យហ្នឹងបណ្ដុះបណ្ដាលប្អូនដប់ប្រាំថ្ងៃហ្នឹង គឺឲ្យមក

ចាក់ថ្នាំចាក់អី។ ខ្ញុំចង់ដឹងថា តើពេលនោះគេចាក់ថ្នាំអីដែរ?

**ឆ៖** ថ្នាំនៅសម័យនោះ ច្រើនគេប្រើថ្នាំចម្រាញ់ពីធម្មជាតិ ហើយគេច្រកដបទឹកក្រូច បិទផ្លាស្ទិក ហើយគេថាបេខ្ញ, បេអងអី ខ្ញុំក៏វាមិនស្គាល់ ហើយមិនដឹងថ្នាំណាការពាររោគណា ក៏ខ្ញុំអត់ដឹងដែរ កាលសម័យហ្នឹង គ្រាន់តែមានប៉ុណ្ណឹងឯង។ បើថ្នាំលេប មានតែថ្នាំចម្រាញ់ពីធម្មជាតិដែរ ខ្លះពណ៌ខ្មៅទៅ ខ្លះពណ៌ក្រហមទៅ មូលៗដូចខ្ញុំនិយាយខាងដើម ដូចអាចម៍ទន្សាយហ្នឹងទៅ ឲ្យលេប។ រួចខ្ញុំមិនអ្នកជំនាញខាងពេទ្យ អត់ដឹងទេ។

**សៈ** តាមការសង្កេតរបស់លោក ថាតើការប្រើថ្នាំហ្នឹងមានប្រសិទ្ធភាពដែរឬទេ?

[១៤:១០:០៥]

**ឆ៖** តាមការប្រើថ្នាំហ្នឹង ជួនកាលចាក់ទៅខ្លះក៏ជាទៅ ខ្លះក៏អត់ជាទៅ។ លេបអ៊ីចឹងដឹងដែរ បើខ្លះកំពុងចុកពោះទៅ លេបទៅបាត់ទៅ ខ្លះក៏អត់បាត់ មិនទៀង គ្មានប្រសិទ្ធភាព។

**សៈ** ថាតើនៅពេលនោះ ប្រជាជនដែលទៅលើកទំនប់នៅទីនោះ គាត់មានសាច់ឈាមយ៉ាងដូចម្ដេចដែរ?

**ឆ៖** នៅសម័យនោះ បើការហូបចុកៗមិនគ្រប់គ្រាន់ហើយ សាច់ឈាមក៏មិនជាធាត់មិនអីទេ គឺស្គម អត់មានធាត់ទេ។

**សៈ** លោកបានលើកឡើងថា មានលោកធ្លាប់ចូលទៅវគ្គសិក្សារៀនសូត្រអីហ្នឹង តើវគ្គសិក្សារៀនសូត្រអំពីអ្វីដែរបាទ?

**ឆ៖** វគ្គសិក្សារៀនសូត្រនោះ ដូចខ្ញុំលើកពីខាងដើមដែរ។ ទៅរៀនមិនមែនរៀនតែខ្ញុំ គឺរៀនទាំងប្រជាជនទាំងខ្ញុំ។ ពេលវគ្គក្នុងមួយ ក្នុង១០ថ្ងៃ គេឲ្យសម្រាកធ្វើមីទ្ទិងសរុបលទ្ធផល ពីលើកពីគុណសម្បត្តិ គុណវិបត្តិខ្លះ រៀនសូត្រនៅតែពេលហ្នឹងឯង។

**សៈ** តើនៅក្នុងពេលនោះគេបានបញ្ជា ឬមួយគេដាក់ផែនការឲ្យលោកដែលជាប្រធានកងៗនៅពេលនោះ ឲ្យអនុវត្ត ឬមួយក៏យ៉ាងម៉េច?

**ឆ៖** នៅពេលនោះគេប្រកាសជាទូទៅឲ្យប្រធានមុខព្រួញ មួយៗលើកសរុបលទ្ធផលអស់ហើយយើង គេជំរុញយើងឲ្យទទួលផែនការ ធ្វើឲ្យសម្រេចផែនការរបស់កំណត់ ដែលបក្សដាក់ឲ្យធ្វើ។

[១៤:១២:៥៨]

**សៈ** ខ្ញុំចូលទៅក្នុងបរិបទមួយទៀត។ ថាតើលោកបានដឹងទេ នៅទីនោះ ថាយុវជន យុវនារី

ប្រហែលជាច្រើននាក់ ហើយចំពោះក្រុមលោកគឺ៥០០នាក់ តើមានពិធីរៀបការនៅទីនោះដែរអត់ទេ?

**ឆ៖** ពិធីរៀបការនៅសម័យនោះគឺមាន ប៉ុន្តែគេមិនដែលរៀបការនៅកន្លែងការដ្ឋានទេ។ គេយកទៅរៀបការនៅមន្ទីរឃុំ ឬកន្លែងនៅមន្ទីរវត្ត ដែលដូចកន្លែងសន្តិសុខហ្នឹងក៏គេធ្លាប់យកទៅរៀបការដែរកន្លែងហ្នឹង។ ហើយម្តងៗពី១០គូ ទៅ១៥គូ។

**ប្រធានអង្គជំនុំ៖**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គប្បីប្រើប្រាស់ពេលវេលាតែ៥នាទីទៀតបានហើយ។ ហើយបញ្ជាក់ថា អង្គជំនុំជម្រះប្រឹងប្រែងដើម្បីបញ្ចប់ការស្តាប់សក្ខីកម្មសាក្សីរូបនេះ ហើយរសៀលនេះ អង្គជំនុំជម្រះមិនមានលទ្ធភាពធ្វើសវនាការលើសពីម៉ោងបួនទេ។ ដោយមូលហេតុអ្នកបកប្រែមួយចំនួន គាត់មានធុរៈចាំបាច់ត្រូវចាកចេញពីបន្ទប់សវនាការនេះ នៅវេលាម៉ោងបួន យ៉ាងយូរបំផុត។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** អម្បាញ់មិញគឺពាក់ព័ន្ធនឹងប្រធានបទពិធីរៀបការ។ សំណួរខ្ញុំមួយដែលពាក់ព័ន្ធនេះគឺ ថាតើអ្នកដែលផ្គូផ្គង ឬមួយអ្នកដែលចូលក្នុងរៀបអាពាហ៍ពិពាហ៍ហ្នឹង គាត់ត្រូវរូវគ្នា ឬមួយយ៉ាងដូចម្តេច?

[១៤:១៤:៥៥]

**លោក អ៊ុំ ជី៖**

**ឆ៖** រៀបការ គឺការកំណត់របស់មេភូមិ គេធ្វើប្រវត្តិរូបឲ្យស្របគ្នា បើមិនស្របគេមិនឲ្យការ។ អ៊ីចឹងទាល់តែប្រវត្តិរូបវាធាតុកសិករ កសិករដូចគ្នា។ ពួកវណ្ណៈថ្នាក់លើ ថ្នាក់លើដូចគ្នា ក្រោមៗដូចគ្នា។ ហ្នឹងស្រេចមេភូមិហ្នឹង គេធ្វើឲ្យ ទៅមេឃុំគេសម្រេចរើសឲ្យរៀប។

**ស៖** អ្នកដែលគេឲ្យរៀបការហ្នឹង គាត់យល់ព្រមនឹងគ្នា ឬមួយអត់?

**ឆ៖** មានគូខ្លះយល់ព្រម គូខ្លះមិនយល់ព្រម។ គ្រាន់តែគោរពផែនការហ្នឹង ប៉ុន្តែដល់ពេលការរួចទៅ មិនចុះសម្រុងគ្នា ក៏មាន។

**ស៖** លោកអម្បាញ់មិញ លើកឡើងថាមានការធ្វើប្រវត្តិរូប។ តើនៅក្នុងភូមិរបស់លោក ពីដំបូងមក គឺថាមានអ្នកជម្លៀសចូល តើពេលអ្នកជម្លៀសចូល មានធ្វើប្រវត្តិរូបដែរអត់ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អ្នកជម្លៀសក៏អ៊ីចឹងដែរ។ អានេះក្តាប់ទៅតាមសាមីខ្លួនគេសងខាងហ្នឹង បើគេថា ចម្លើយម៉ែឪគេ ប្រធានភូមិគេសួរថា បើមកពីភ្នំពេញដូចគ្នា គេអនុញ្ញាតឲ្យយកទៅ។

**ស៖** ចុះពាក់ព័ន្ធនឹងបងប្អូនជនជាតិចាម តើគេកំណត់យ៉ាងម៉េចដែរ?

**ឆ៖** បងប្អូនជនជាតិចាម ក៏កំណត់ដូចគ្នានឹងពួកពីមកពីភ្នំពេញដែរ។ ជនជាតិចាម គឺយកជនជាតិចាម គេមិនដែលបង្ខំឲ្យជនជាតិចាមយកខ្មែរទេ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងពីរកន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងពីរកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:១៧ នាទី ដល់ម៉ោង ១៤:២៧ នាទី)*

[១៤:២៧:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះគឺជូនទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរសំណួរលោកមួយចំនួន មិនជាច្រើនប៉ុន្មានទេ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងបញ្ចប់បានឆាប់រហ័ស។ លោកទើបតែផ្តល់ចម្លើយនៅមុននេះបន្តិច គឺមុនពេលឈប់សម្រាកបន្តិចនេះ <គឺអំពី>ពេលវេលាដែលលោក និងកម្មករ៥០០នាក់ទៀតដែលធ្វើការនៅទន្លេនោះ។ ខ្ញុំចង់សួរថា តើលោកធ្វើការជាមួយកម្មករទាំង៥០០នាក់នេះ តាំងពីដើមរហូតដល់ចប់<ឬ> គឺបានន័យថា តាំងពីខែកុម្ភៈ<ឆ្នាំ១៩៧៨>ទៅដល់ខែសីហា <ឆ្នាំ១៩៧៨ឬ? ប្រសិនបើអ៊ីចឹងមែន តើកម្មករទាំង៥០០នាក់នេះគឺជាក្រុមមនុស្សដដែលឬ?>

**លោក អ៊ុំ ជី៖**

**ឆ៖** កាលនោះ ខ្ញុំនៅលើរដែរ។ ដល់ពេល ដល់ខែ៨ ហ្នឹងខ្ញុំគេរៀបគ្រួសារឲ្យ ខ្ញុំចេញពីហ្នឹង ខ្ញុំទៅនៅតាមភូមិ។ មិនបាននៅធ្វើជាប់រហូតចប់ទេ។

[១៤:២៩:៣៣]

**ស៖** ខ្ញុំមិនប្រាកដថា សំណួររបស់ខ្ញុំបក<ប្រែ>ត្រឹមត្រូវឬក៏<អត់>ទេ ប៉ុន្តែខ្ញុំចង់និយាយពីកម្មករទាំង៥០០នាក់។ គឺលោកដឹកនាំកម្មករ ៥០០នាក់។ ដូច្នេះខ្ញុំចង់សួរថា តើមនុស្សទាំង៥០០នាក់ហ្នឹងនៅក្រោម ការគ្រប់គ្រងរបស់លោកតាំងពីដើម គឺតាំងពីខែកុម្ភៈ ១៩៧៨ រហូតទៅដល់ពេលដែលលោកបញ្ចប់<ការងារនៅទីនោះ> គឺនៅក្នុងខែសីហា ១៩៧៨ ដែរឬយ៉ាងណា?

**ឆ៖** មិនចប់ទេ ពីព្រោះធ្វើហ្នឹងមិនមែននៅ ៥០០ ឋិតថេរណាធ្វើ គេរើសទៅទ័ពខ្លះ គេការខ្លះយូរៗនៅតិចទេ ហើយខ្ញុំក៏ការដែរ គឺអត់បាននៅចប់ដែរ។

**ស៖** អ៊ីចឹងបានន័យថា អ្នកដែលចាកចេញហ្នឹង ត្រូវបានជំនួសដោយអ្នកថ្មី ដោយកម្មករថ្មីអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងអ្នកក្រោយ គឺនៅតាមប្រធានកងគេតូចៗហ្នឹង ហើយនិងអ្នកប្រធានគេទទួលមុខព្រួញពីថ្នាក់ឃុំ គេនៅជាប់។

**ស៖** ខ្ញុំ<ព្យាយាម>សួរលោក<តាមរបៀបផ្សេងវិញ។> នៅក្នុងពេលដែលលោកធ្វើការនៅទន្លេនោះ គឺនៅពេលដែលលោកដឹក<ប្រឡាយ> តើ<តែងតែ>មានកម្មករធ្វើការ ៥០០នាក់គ្រប់ពេលឬមួយក៏អត់ទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ធ្វើមិនគ្រប់ទេ មានឈឺតាមកងមួយៗហ្នឹង ឈឺហូរហែទៅ មិនដែលគ្រប់ចំនួនទេ។

**ស៖** នេះគឺជាចំណុចដែលខ្ញុំចង់សួរ។ ដូច្នេះចន្លោះពីខែកុម្ភៈ ដល់សីហា ឆ្នាំ៧៨ តើលោកចាំទេថា មានមនុស្សប៉ុន្មាននាក់ដែរ ក្នុងចំណោមកម្មករ៥០០នាក់ហ្នឹងដែលធ្លាក់ខ្លួនឈឺ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ ពីព្រោះអាហ្នឹងនៅតាមកងគេតូចៗ ហើយឈឺក៏មិនមែនឈឺរហូត ឈឺថ្ងៃណាជា ទៅធ្វើ ថ្ងៃឈឺៗ។ អត់ចាំ អត់មានចាំច្បាស់។

[១៤:៣២:៣៧]

**ស៖** ខ្ញុំនឹងជួយឱ្យលោកនឹកឃើញឡើងវិញ។ <សង្ឃឹមអីចឹងចុះ លោកសាក្សី> នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនៅទំព័រអង់គ្លេសមានលេខ 00282347, បារាំងមានលេខ 00482926 និងខ្មែរមានលេខ 00271399។ លោកបាននិយាយដូចតទៅនេះ៖ "ដោយសារតែមិនមានអាហារគ្រប់គ្រាន់មនុស្ស<មួយចំនួន>ចាប់ផ្តើមឈឺ។ មានមនុស្សបួនទៅប្រាំនាក់<ក្នុងចំណោមកម្មករ៥០០នាក់ធ្លាក់ខ្លួន>ឈឺ ហើយជំងឺទាំងនោះមកពីការឃ្លានពេក ខ្លះហើម ខ្លះស្គម<>។" តើអ្វីដែលខ្ញុំអានហ្នឹង តើធ្វើឱ្យលោកនឹកឃើញដែរឬទេ គឺទាក់ទងទៅនឹងមនុស្ស៥០០នាក់ហ្នឹងគឺមានបួនដប់នាក់ដែលឈឺ<ក្នុងពេលលោកធ្វើការនៅទី>នោះ តើលោកនឹកឃើញទេ?

**ឆ៖** បាទ ខ្ញុំនឹកឃើញមែន ព្រោះអីខ្ញុំនិយាយដូចហ្នួសអាហ្នឹង។

**ស៖** តើលោកចាំឈ្មោះរបស់អ្នកដែលឈឺ<ទេ>? តើលោកដឹងថា<មានរឿងអ្វីកើតឡើងចំពោះពួកគាត់ទេ?> តើលោកដឹងទេថា អ្នកដែលឈឺ<មួយចំនួន ឬក៏អ្នកដែលឈឺទាំងអស់>ហ្នឹងត្រូវបានគេនាំទៅពេទ្យដែរឬទេ?

**ឆ៖** ឈឺ អ្នកឈឺហ្នឹងគេនាំទៅពេទ្យ។ ហើយឈ្មោះ ខ្ញុំមិនចាំទេ។

**ស៖** តើលោកយល់ស្របទេ ប្រសិនបើខ្ញុំថា ក្នុងចំណោមមនុស្ស៥០០នាក់ហ្នឹងគឺមិនមានមនុស្សច្រើនទេដែលឈឺ<គឺបួន ទៅប្រាំនាក់ទេ>ក្នុងរយៈពេល<>ប្រាំមួយខែនោះ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំសូមជំទាស់។ សម្រង់នោះនិយាយពីអ្នកជំងឺបួន<>១០នាក់ ប៉ុន្តែមានចំណុច<ផ្សេង>មួយទៀត <ដែលខាងការពារក្តីអាច>សូមឱ្យ<សាក្សីគាត់>បំភ្លឺផងដែរ ព្រោះថាមិនច្បាស់ទេ។ តើពីបួនទៅ១០នាក់ហ្នឹង <> អវត្តមានរហូតនៅកន្លែងធ្វើការនោះ<ឬ?> ឬក៏ថាក្នុង<>ពេញមួយរយៈពេលដែលគាត់ធ្វើការនៅការដ្ឋានហ្នឹង គឺថាមានតែបួនដប់នាក់ទេ ដែលអត់បានទៅធ្វើការ

ដោយសារឈឺ។

[១៤:៣៥:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រាកដហើយ ខ្ញុំនឹងបញ្ជាក់ ប៉ុន្តែឥឡូវនេះ ខ្ញុំសួរម្តងទៀតឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <>មនុស្សបួនប្រាំនាក់ដែលឈឺនុ៎ង ថាតើ<>បួនប្រាំនាក់<ហ្នឹងគឺស្ថិត>ក្នុងចំណោម មនុស្ស៥០០នាក់ ក្នុងរយៈពេល៦ខែ<ពេញហ្នឹង> ឬក៏អត់ទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក អ៊ុំ ជី៖**

**ឆ៖** នៅក្នុងនុ៎ង ដូចខ្ញុំជម្រាប មុនស្សមិនមែននៅ៥០០នាក់ថិតថេររហូតដល់ចប់ការដ្ឋានទេ។ គេដកទៅទ័ពខ្លះ ការខ្លះ យូរៗនៅតិចតួច ប្រហែលជាខ្ទង់៣០០ ខ្ទង់អីហ្នឹងប៉ុណ្ណឹង។ ហើយអ្នកឈឺហ្នឹងក៏ឈឺ ដែលអ្នកឈឺធ្ងន់ទៅដឹកទៅពេទ្យ អ្នកឈឺនៅហ្នឹងក៏ឈឺហូរហែមួយថ្ងៃ១០នាក់ មួយថ្ងៃប្រាំនាក់ មិនដែលដាច់ទេ ពីរោងកន្លែងនៅ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ប៉ុន្តែមុនហ្នឹងលោកនិយាយថា មានតែមនុស្សបួនប្រាំនាក់ទេ <ហើយលោកបញ្ជាក់ច្បាស់ហើយ។ ឥឡូវ តើលោកចង់ថា>មានមនុស្សច្រើន<ជាងហ្នឹងធ្លាក់ខ្លួនឈឺ តើមែនទេ>?

[១៤:៣៦:៣៥]

**ឆ៖** អានេះដូចខ្ញុំនិយាយ ពីព្រោះរឿងដែលថា រែកទឹក មិនមែនឈឺទាំងអស់ មិនមែនតែ ដប់បួនដប់នាក់ៗ ខ្ញុំថាដែលអ្នកឈឺធ្ងន់ៗអាចបញ្ជូនទៅពេទ្យ អ្នកដែលនៅឈឺប្រចាំថ្ងៃហ្នឹង ឈឺរាល់តែថ្ងៃហ្នឹងក្នុងរោងមួយៗ គឺមិនដែលដាច់ទេ។ គឺថាអ្នកឈឺ តែងតែឈឺជាៗអ៊ីចឹង។ បើបួនដប់នាក់ហ្នឹងបញ្ជូនទៅពេទ្យទៅ។ ទៅជួនកាលមកទៅ ក៏គេនៅតាមសហករណ៍ទៅ ខ្លះក៏គេមកកន្លែងអង្គភាពចល័តវិញទៅ។ ខ្ញុំនិយាយនេះ វាមិនអស់ពាក្យ បានតែខ្ញុំមានការចោទប្រកាន់ពីអង្គចៅក្រម។

**ស៖** មិនអីទេ លោកសាក្សី ខ្ញុំនឹងបន្តទៅប្រធានបទថ្មី។ មុននេះលោកបាននិយាយពីការចាប់ខ្លួន គឺចាប់ខ្លួន<កម្មករ>យុវជនម្នាក់ គឺការចាប់ខ្លួនយុវជនដែលធ្វើការនៅទីនោះ ហើយលោកនិយាយថា

ការចាប់ខ្លួនហ្នឹង គឺដើម្បី "គំរាមដល់កម្មករដទៃទៀត"។ តើលោកធ្លាប់សួរនាំ<>ភ្នាក់ងារសន្តិសុខដែលចាប់យុវជនហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានសួរទេ ពីព្រោះសន្តិសុខសុទ្ធតែមកថ្មីៗ ហើយមិនស្គាល់ធ្លាប់ទំនាក់ទំនងអត់ដែលប៉ានសួរទេ។

**ស៖** តើលោកធ្លាប់ជួបនិយាយជាមួយអ្នកដទៃអំពីការចាប់ខ្លួន<យុវជន>ហ្នឹង<ដែរទេ?> <តើលោក>ធ្លាប់ជួបនិយាយជាមួយអ្នកដែលគេយកយុវជនហ្នឹងមកឲ្យដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ជួប។ ជួបតែប្រធានកងគេ ធ្វើជាប់នឹងខ្ញុំ ដូចថាខ្ញុំនិយាយពាក្យខ្លះ គឺមិនអស់សេចក្តីមានការចោទប្រកាន់ពីសហព្រះរាជអាជ្ញា។ ហើយខ្ញុំធ្វើនោះ ក៏ប្រឡាយហ្នឹងវាមិនមែនខ្លីឯណាប្រឡាយវែង ដាក់គេដាក់តាមឃុំមួយៗជាប់គ្នាហ្នឹង។ ហើយដល់ពេលប្រធានកងគេទៅតវ៉ា គេទៅយកមកវិញបានទៅ។ រួចអ៊ីចឹងដល់ពេលខ្លះ ដែលគេចោទប្រកាន់យើងទោសធ្ងន់ធ្ងរ គឺយកមិនបានទេ។

[១៤:៣៩:៣១]

**ស៖** ខ្ញុំ<រៀបសំណួរម្តងទៀត។> តើលោកធ្លាប់និយាយជាមួយអ្នកណាម្នាក់ដែលមានតួនាទីផ្លូវការ<>ដែលមានសិទ្ធិអំណាច<>អាចប្រាប់ថា ហេតុអ្វីបានជាគេចាប់<យុវជន>ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបាននិយាយទេ ដូចខ្ញុំនិយាយខាងដើមហ្នឹង ព្រោះថាខ្ញុំសម័យនោះ ខ្ញុំគ្រាន់តែតួនាទីដឹកនាំធ្វើការ ហើយឃើញគ្រាន់តែមានគេឋានៈធំ មិនដែលប៉ានទាក់ទងទេ។

**ស៖** លោកសាក្សី តើខ្ញុំ<>និយាយ<ត្រូវទេ> ការដែលលោកនិយាយថា គេចាប់យុវជនហ្នឹងដើម្បីគំរាមអ្នកដទៃហ្នឹង វាគ្រាន់តែជាការទាយស្មានរបស់លោក តើមែនដែរឬទេ?

**ឆ៖** ពិតប្រាកដមែនហើយ ព្រោះខ្ញុំថាចាប់ខ្លួន មិនមែនចាប់។ បើសិនជាចាប់មានទោសធំដុំ គេមិនចាប់ទេ។ អាហ្នឹងគេចាប់ដូចថា នៅក្នុងចំណោមធំ ឲ្យយើងប្រជាជនទាំងអស់នោះបាក់ស្បាតណ៎ាឃើញគេថាអ៊ីចឹង។ គ្រាន់ប៉ុណ្ណឹង អាហ្នឹងជាជំហររបស់ខ្ញុំឃើញ ដែលនៅជាក់ស្តែងជិតហ្នឹង។

**ស៖** ប៉ុន្តែទោះយ៉ាងណាក៏ដោយ វាជាការទាយស្មានរបស់លោក អ៊ីចឹងមែនទេ? <ខ្ញុំនឹងបន្តទៅមុខទៀតលោកសាក្សី>

**ឆ៖** បាទ។

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀតលោកសាក្សី<ទៅកាន់បញ្ហាផ្សេងមួយទៀត>។ <> មុននេះលោកបានឆ្លើយថា ការងារពេលយប់នៅការដ្ឋាននោះ គឺធ្វើឡើងម្តងកាលនោះទេ។ លោកនិយាយថា "នៅ

ពេលដែលមានការចាំបាច់ កម្មករពេលខ្លះធ្វើការងារ<ពេញមួយ>យប់"។ តើលោកអាចលើកឧទាហរណ៍បានទេ ថាតើក្នុងស្ថានភាព<ពេលល្ងាចណា ឬក៏យប់>ណាមួយ ដែលគេតម្រូវឱ្យធ្វើការនៅពេលយប់នុ៎ង? <សូមលោក>លើកឧទាហរណ៍<>មួយអំពីស្ថានភាព<>ពេលដែលគេតម្រូវឱ្យធ្វើការនៅពេលយប់នោះ?

[១៤:៤២:២០]

**ឆ៖** ដែលគេតម្រូវឱ្យធ្វើការយប់នោះ ការដ្ឋាននោះ មានគេឱ្យឆ្នូនមកវ៉ើ។ ដល់តែពេលវ៉ើបុកកន្លែងរណ្ដៅ វ៉ើមិនបាន គឺគេតម្រូវឱ្យធ្វើ ដើម្បីឱ្យទាន់ផែនការគេ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកមានដឹងទេថា <មានពេលមួយនោះ>មាន<គោលការណែនាំ ឬ>ការណែនាំមកពីថ្នាក់លើ ដែលថាការធ្វើការនៅពេលយប់ហ្នឹង <ជាទូទៅ>គួរតែមានការកម្រិតកំណត់<>ដោយសារតែមូលហេតុមួយចំនួន? <>

**ឆ៖** មាន ធ្លាប់ឮ ពីព្រោះដែលគេឱ្យធ្វើការយប់ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង គឺថាចង់ឱ្យលឿន គឺថាដើម្បីឱ្យសម្រេចផែនការប្រឡាយហ្នឹង កុំឱ្យដល់ពេលដល់ខែវស្សា ទឹកធ្វើមិនកើត។

**ស៖** ប្រហែលជាលោកមិនយល់ច្បាស់អំពីអ្វីដែលខ្ញុំចង់សួរ ប៉ុន្តែខ្ញុំចង់សួរថា តើ<លោកដឹងអំពីគោលការណ៍ ឬក៏>ការណែនាំ <ក្នុងខែតុលា ឬខែវិច្ឆិកា ឆ្នាំ១៩៧៧ទេ>ដែលថា<ត្រូវកម្រិត>ការងារនៅពេលយប់ឱ្យបានច្រើន<តាមដែលអាចធ្វើបាន> តើលោកធ្លាប់ឮទេ?

**ឆ៖** ខ្ញុំ អានេះជាក់ស្ដែងនៅប្រឡាយ ជាគោលការណ៍មានហើយ ប៉ុន្តែជាក់ស្ដែងដែលគេធ្វើ អ្នកនាំធ្វើ គេគោរពបានខ្លះ មិនបានខ្លះអ៊ីចឹងឯង គេធ្វើវាអ៊ីចឹង។

[១៤:៤៤:៤០]

**ស៖** លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវ<សម្រង់>ឯកសារតូចមួយមកពីទស្សនាវដ្ដីទង់បដិវត្ត <គឺអំពីចំនួនពិសេសមួយពីខែតុលា ដល់វិច្ឆិកា ឆ្នាំ១៩៧៧។> គឺឯកសារ E3/170 អង់គ្លេសមានលេខ 00182578, ខ្មែរមានលេខ 00064792 និងភាសាបារាំង ខ្ញុំមិនមានលេខERN នៅពេលនេះទេ ប៉ុន្តែបន្តិចទៀតខ្ញុំនឹងឱ្យលេខERN ជាភាសាបារាំង។ ដូច្នេះលោកសាក្សី នៅក្នុងទស្សនាវដ្ដីទង់បដិវត្ត គឺបានរៀបរាប់ដូចតទៅនេះ៖ "តាមបទពិសោធន៍កន្លងមករបស់យើង គឺថាការងារនៅពេលយប់ គឺមានផលប្រយោជន៍តិចតួច<ណាស់ តែផ្ទុយទៅវិញនាំឱ្យមានការខាតបង់ចំណាយច្រើនទៅវិញ> ទី១ ប៉ះពាល់សុខភាព។ ទី២ ចំណាយភ្លើង។ ខាតជាងគេគឺនយោបាយ<និងមនោគមន៍វិជ្ជា>។" ថាតើវាធ្វើ

ឲ្យលោកនឹកឃើញ<>ទេ <>អំពីមូលហេតុដែលគេបង្គាប់បញ្ជាឲ្យ<កម្រិត>ការធ្វើការនៅពេលយប់<តាមដែលអាចធ្វើបាន>ហ្នឹង តើលោកនឹកឃើញដែរទេ?

**ឆ៖** ខ្ញុំមិនច្បាស់តែម្តង គឺថាពីព្រោះនៅតែតាមមុខព្រួញ តែថ្នាក់ប្រធានការដ្ឋាន គេថាចុះធ្វើៗហើយ។ ជាគោលការណ៍ គឺនិយាយគឺថាវាខាតប្រយោជន៍នយោបាយ ខាតប្រយោជន៍អីអ៊ីចឹងមែន ប៉ុន្តែអាហ្នឹងបើគេឲ្យធ្វើ យើងមិនធ្វើ ក៏យើងមិនគោរពផែនការគេទៀតហើយអាហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ថាតើត្រឹមត្រូវដែរឬទេ ក្នុងចំណោមកម្មករ៥០០នាក់នៅការដ្ឋាននោះ គឺថាពួកគាត់ធ្វើការទៅតាមភូមិរបស់ពួកគាត់<ដែលគាត់មក>? បានន័យថា គេបែងចែកកម្មករហ្នឹង<ជាក្រុម>ទៅតាមភូមិដែលពួកគាត់រស់នៅ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ធ្វើការហ្នឹងគឺទៅតាមកង តាមភូមិគេមួយៗ។ ចេញមកមានប្រធានកងតាមភូមិគេមួយៗមកហើយ។ ខ្ញុំគ្រាន់តែជាអ្នកនាំធ្វើ និងទទួលផែនការពីថ្នាក់លើប៉ុណ្ណឹងឯង។

[១៤:៤៧:៣៩]

**ស៖** តាមចម្លើយរបស់លោក ខ្ញុំយល់ថាកម្មករដែលធ្វើការហ្នឹងត្រូវបានគេអនុញ្ញាតឲ្យយកសម្ភារៈផ្ទាល់ខ្លួនយកទៅកន្លែងស្នាក់នៅ ដូចជា <> កន្ទេល ឬក៏អង្រឹង <ជាដើម>។ ដូច្នេះខ្ញុំចង់សួរថាអ្នកណាជាអ្នកសម្រេច ថាតើកម្មករទៅធ្វើការហ្នឹងអាចយកអ្វីទៅតាមខ្លួន<បាន>? ឬមួយថាតើអ្នកដែលសម្រេចហ្នឹងជា<ប្រធានអង្គភាព> ឬមួយក៏<ជារូបលោកដែលជាមេរបស់ពួកគេ?>

**ឆ៖** អាហ្នឹងជាការសម្រេចហ្នឹង គឺប្រធានមុខព្រួញការដ្ឋានហ្នឹងឯង គេឲ្យសម្រេច។ បើថាយើងទៅបើគ្មានសម្ភារៈៗដេក គឺយើងទៅនៅម៉េចកើត។

**ស៖** ប៉ុន្តែ<តើនេះជាមូលហេតុដែល>អ្នកខ្លះគាត់<មាន>អង្រឹងទៅ អ្នកខ្លះមិន<មាន>អង្រឹង<ឧទាហរណ៍>ដោយសារតែការសម្រេចហ្នឹង<គឺធ្វើទៅថ្នាក់ក្រោម ហើយការសម្រេចនោះ> មិនមែន<>មជ្ឈិម<សម្រេច>ទេ <តើត្រឹមត្រូវដែរទេ?>

**ឆ៖** ជាក់ស្តែងសម័យនោះខ្វះខាត ដូចខ្ញុំលើកពីខាងដើមអ្នកខ្លះ អ្នកខ្លះអត់។ អ្នកមានទៅយកទៅៗ អ្នកអត់ក៏អត់មានទៅ អ្នកខ្លះក្រាលកន្ទេលទៅ អ្នកខ្លះដេកលើធ្នើរហ្នឹងទៅ ហើយកើយ មានអាគេថាកម្មសិទ្ធិសមរម្យ កាលពីសម័យនោះមានស្បោងមួយអាតូចហ្នឹង ដាក់មានស្អី មានតែអង្រឹង ខោអាវកញ្ចាស់ហ្នឹងឯង។

[១៤:៤៩:៥៧]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** មុននេះ<បន្តិច>នៅពេលដែលព្រះរាជអាជ្ញាសួរលោក<> លោកបាននិយាយ<អំពីការកម្ទេចខ្មាំង ហើយ>ជាពិសេសគឺកម្ទេចខ្មាំងដែល<ធ្វើវិទ្ធ្វេទកម្ម>ទៅលើចលនា។ តើលោកចង់មានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា "គេកម្ទេចខ្មាំងដែល<ធ្វើវិទ្ធ្វេទកម្ម>ទៅលើចលនា"? <តើលោកចង់មានន័យថាម៉េច?>

**ឆ៖** ខ្ញុំមិនច្បាស់ទេ ពីព្រោះដែលការដ្ឋានមួយៗអ្នកខ្លះទៅនិយាយឱ្យអសកម្មនឹងការងារហ្នឹង បើសិនជាថ្នាក់លើគេដឹង ទៅគេមិនទុកទេ ប៉ុន្តែជាមួយខ្ញុំវាអត់មានទេ គឺថានៅរហូត *(ឮមិនច្បាស់)* ព្រោះដូចខ្ញុំនិយាយខាងដើម ខ្ញុំមិនដែលរាយការណ៍ពីគេទេ។

**ស៖** <លោកសាក្សី> មានសក្ខីកម្មខ្លះៗដែរ ដែលសក្ខីកម្មទាំងនោះឆ្លើយថា ប្រសិនបើអ្នកណាម្នាក់ខ្ជិល មិនសកម្ម គាត់នឹងត្រូវគេ<ស្តីបន្ទោស ពេលខ្លះ>យកទៅអប់រំរៀបសូត្រ ឬក៏ពេលខ្លះគេធ្វើទណ្ឌកម្ម<ធ្ងន់ធ្ងរ>។ ថាតើលោកអាចបញ្ជាក់បានច្បាស់បន្តិចបានទេ ថាតើលោកដឹងទេ ថាមានអ្វីកើតឡើងចំពោះអ្នកដែលធ្វើវិទ្ធ្វេទកម្មទៅលើចលនានោះ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតបសាក្សី!

**លោក អ៊ុំ ជី៖**

**ឆ៖** ដូចខ្ញុំនិយាយបញ្ជាក់ខាងដើមអំមិញ គឺថាគេប្រជុំនៅវគ្គមួយៗ បើអ្នកណាធ្វើវិទ្ធ្វេទកម្ម ធ្វើឱ្យអសកម្ម ហ្នឹងបើគេថ្នាក់លើនឹងដឹង គេនឹងអាចយកទៅធ្វើទារុណកម្ម ឬក៏ទៅអប់រំ គ្រាន់ប៉ុណ្ណឹង។

[១៤:៥២:១៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកធ្លាប់ឃើញផ្ទាល់ មនុស្សដែលត្រូវគេធ្វើទារុណកម្មទេ?

**ឆ៖** ខ្ញុំមិនដែលឃើញផ្ទាល់ទេ ពីព្រោះកន្លែងខ្ញុំអត់ដែលឃើញ។ នៅនឹងប្រឡាយហ្នឹងក៏មិនដែលឃើញ ពីព្រោះដល់តែពេលដេកវានៅដោយខ្លួន ហើយពេលធ្វើការក៏ទៅតាមក្រុមដោយខ្លួនៗ។ បើថាក្នុងក្រុមរបស់ខ្ញុំ មួយក្នុងចង្កោមរបស់ខ្ញុំមិនដែលមាន មិនដែលឃើញ។ បើកន្លែងគេ ក៏ខ្ញុំមិនដែលឃើញ ព្រោះខ្ញុំមិនដែលសូវបានដើរ។

**ស៖** សូមអរគុណលោកសាក្សី។ ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺថាឯកសារបារាំង<ដែលខ្ញុំជំពាក់នោះគឺ> 00665429។ <លោកសាក្សី> ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មី។ ខ្ញុំចង់សួរអំពី

មនុស្សម្នាក់ឈ្មោះ ប៉ូចៗ។ <ខ្ញុំប្រកបមិនច្បាស់ទេ ដូច្នេះ>សហការីជាតិរបស់ខ្ញុំនឹងអានឈ្មោះនេះ។

**លោក សុន អរុណ៖**

ឈ្មោះ ប៉ូច។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកចាំទេ <ពេល>និយាយអំពីឈ្មោះ ប៉ូច នេះ<>?

**លោក អ៊ុំ ជី៖**

**ឆ៖** បាទ ខ្ញុំចាំតើ! ខ្ញុំនិយាយមែនឈ្មោះ ប៉ូច។

**ស៖** តើលោកនិយាយអ្វីអំពីឈ្មោះ ប៉ូច នេះ? លោកអាចប្រាប់បានទេ?

**ឆ៖** ឈ្មោះ ប៉ូច នេះខ្ញុំនិយាយគាត់ជាគណៈស្រុក គាត់ទទួលនៅស្រុកបារាយណ៍ តពីឈ្មោះ មូល។

[១៤:៥៤:៣៥]

**ស៖** តើលោកចាំអ្វីខ្លះដែរអំពីឈ្មោះ ប៉ូច នេះ?

**ឆ៖** ខ្ញុំមិនចាំអ្វីទេ។ ខ្ញុំគ្រាន់តែចាំថា គាត់ជាគណៈស្រុកទទួលបន្តពីឈ្មោះ មូល។ គ្រាន់តែចាំប៉ុណ្ណឹងឯង។ មិនដឹងគាត់សកម្មភាពអី ខ្ញុំមិនដែលដឹង អត់ដែលបានសួរ។

**ស៖** តើលោកធ្លាប់ឮរឿងរ៉ាវអំពីគាត់ ថាគាត់ជាមនុស្សកាចសាហាវ ឬក៏គេរៀបរាប់អំពីលក្ខណៈរបស់គាត់អ៊ីចឹងទេ? តើលោកធ្លាប់ឮទេ?

**ឆ៖** មិនធ្លាប់ឮទេ ពីព្រោះ ប៉ូច គាត់មកនៅស្រុកបារាយណ៍ គេចេញសារាចរលើកលែងទោសរួចហើយ បានគាត់មកនៅ ហើយក៏មិនដែលឮគាត់ គេនិយាយដែរ។ គាត់មកនៅចុងក្រោយបង្អស់។

**ស៖** ខ្ញុំមិនប្រាកដទេ ប៉ុន្តែឥឡូវខ្ញុំសូមសួរលោក<សំណួរផ្សេង។> តើលោកធ្លាប់<ឮ>ការចោទប្រកាន់ពីឈ្មោះ ប៉ូច នេះថា ប៉ូច ហ្នឹងគាត់ – <>ថា ប៉ូច ហ្នឹងសម្លាប់ក្រុមគ្រួសារដែលរស់នៅក្នុងស្រុករបស់គាត់ ដោយ<គ្មានការអនុញ្ញាត> គឺថាសម្លាប់តាមអំពើចិត្តរបស់គាត់ទេ?

**ឆ៖** ដូចខ្ញុំនិយាយអំមិញ គឺថាសម័យគេបោសសម្អាតហ្នឹងគឺ ប៉ូច គាត់មិនទាន់មកនៅទេ។ គាត់មកនៅចុងក្រោយហើយ លើកសារាចរចេញមកហើយ បានគាត់មកនៅ។ កាលហ្នឹងគឺថាធូរលុងការស្លាប់ ប្រជាជនក៏មានសិទ្ធិសេរីភាពត្រឹមត្រូវហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:៥៦:៥៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ខ្ញុំឮ<ពាក្យថា “ចោទប្រកាន់”> អ៊ីចឹងខ្ញុំសួរលោកថា លោកមានប្រភពមកពីណាដែរ <ពាក់ព័ន្ធនឹងការដែលគេ>ចោទប្រកាន់ទៅឈ្មោះ ប៉ូច នេះ? <លោកមានមូលដ្ឋានអ្វីក្នុងការនិយាយពាក្យ “ចោទប្រកាន់” នេះ?>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំផ្អែកទៅលើកំណត់ហេតុស្ដាប់ចម្លើយ E3/35 គឺជាកំណត់ហេតុស្ដាប់ចម្លើយរបស់កូន កែ ពក។ ខ្ញុំនឹងអាននូវកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់។ អង់គ្លេសមានលេខ<00346157> *(ស៊ីក)*, ខ្មែរមានលេខ 00340572 និងបារាំងមានលេខ 00367729។ នេះគឺជាប្រភពព័ត៌មានរបស់ខ្ញុំ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះខ្ញុំ<សូមត្រឡប់>ទៅ<សំណួររបស់ខ្ញុំវិញ ខ្ញុំមិនច្បាស់ថាខ្ញុំសួរអីទេអំមិញ។ តែខ្ញុំគិតថាខ្ញុំសួរថាតើ>លោកដឹង<>អំពីឈ្មោះ ប៉ូច នេះ<>ធ្លាប់សម្លាប់<មនុស្សទាំង>គ្រួសារនៅក្នុងស្រុករបស់គាត់ ដោយគ្មាន<បទបញ្ជា>ដែរឬទេ? តើលោកធ្លាប់ឮ<គេចោទប្រកាន់គាត់អ៊ីចឹង>ទេ?

**លោក អ៊ុំ ជី៖**

**ឆ៖** ខ្ញុំនិយាយបញ្ជាក់ពីមុនហើយថា ប៉ូច ហ្នឹងគាត់មកនៅស្រុកបារាយណ៍ហ្នឹង គឺចុងក្រោយបង្អស់ហើយ ដែលសម្លាប់អីគឺថាធូរ ឃើញថាធូរហើយ ប៉ុន្តែខ្ញុំមិនដឹង បើលោកយកព័ត៌មានពីណាមកក៏ខ្ញុំអត់ដឹង។ ខ្ញុំអត់ដឹង ចំពោះខ្លួនខ្ញុំមិនដឹង មិនដែលឮតែម្ដង។

[១៤:៥៨:៥៤]

**ស៖** លោកសាក្សី ខ្ញុំសូមអាននូវសម្រង់របស់កូនប្រុស កែ ពក គឺជាប្រធានភូមិភាគ។ លោកប្រធាន នេះគឺជា ERN ដែលខ្ញុំទើបតែបង្ហាញមុននេះបន្ដិច<មានដូចតទៅ៖> “ខ្ញុំចាំថា នៅពេលក្រោយមក ឪពុកខ្ញុំទទួលព័ត៌មានថាមានការសម្លាប់ប្រជាជនទាំងឡានៗនៅភ្នំប្រុសភ្នំស្រី។ក្រោយពេលដឹងរឿងនោះ មួយថ្ងៃមក គាត់បានចុះទៅទំនប់១មករា។ ពេល<ធ្វើដំណើរ>នោះ គាត់ឆៀងចូលទៅភូមិក្រវ៉ាំបាក់ស្នា ស្រុកបារាយណ៍ <ជាកន្លែងដែល>ប្រជាជនប្រហែល២០០គ្រួសារ ដែលគេចាប់យកមកដាក់ក្នុងវត្ត ដើម្បីសម្លាប់ចោល។ ពេលនោះគាត់សួរប្រជាជនទាំងនោះថា៖ តើមកជុំគ្នាអីច្រើនម្ល៉េះ?

ប្រជាជនឆ្លើយថា៖ ពក ឯងមិនសមធ្វើបែបហ្នឹងសោះ។ ឪពុកខ្ញុំសួរទៀតថា៖ មានរឿងអី? ប្រជាជនឆ្លើយថា៖ ពក ឯងបញ្ជាឱ្យគេចាប់ពួកអញយកមកសម្លាប់។ គេសម្លាប់ពួកអញយប់នេះហើយ។ ព្រឹត្តិការណ៍នេះ ឪពុកខ្ញុំបាននិយាយប្រាប់ខ្ញុំដោយផ្ទាល់។ ពេលនោះអ្នកបើកឡានជូនគាត់ទៅឈ្មោះ ជៀម។ គាត់បានស្គាល់ប្រជាជនទាំងអស់នោះ ព្រោះពួកគេជាអ្នកចិញ្ចឹមបាយទឹកគាត់ តាំងពីពេលគាត់នៅតស៊ូក្នុងព្រៃ។ ពេលនោះគាត់<បានឲ្យឈ្លប>ទៅហៅគណៈស្រុកឈ្មោះ ប៉ូច មកជួបគាត់ ប៉ុន្តែគណៈស្រុកមិនមកទេ។ ពេលនោះ គណៈឃុំក្រវ៉ា ឬក៏ឃុំបាក់ស្នាបានមកដល់ ហើយគាត់ក៏បញ្ជាឱ្យដោះលែងប្រជាជនទាំងនោះ ដែលបានដាក់កម្រិតថា មិនឱ្យអ្នកណាប៉ះពាល់ប្រជាជនទាំងអស់នោះទេ <ដាច់ខាត>។" លោកសាក្សី នេះគឺជារឿងរ៉ាវដែលកើតឡើងនៅក្នុងភូមិដែលលោកស្នាក់នៅថា តើរឿងរ៉ាវដែលខ្ញុំអាននេះ ធ្វើឱ្យលោកនឹកឃើញដែរឬទេ?

[១៥:០១:០៧]

**ឆ៖** វាខ្ញុំមិនដឹង។ អត់ដែលដឹង ព្រោះមិនមែនថា ខ្ញុំលាក់ឬស្អី អត់។ ខ្ញុំមិនដឹងមែនរឿងហ្នឹងមិនដឹង ពីព្រោះពួកមកនៅនៅក្នុងស្រុកបារាយណ៍នេះ ព្រោះកន្លែងគាត់នៅនឹងក្នុងឃុំបល្ល័ង្កហ្នឹងឯង នឹងផ្សារកំពង់ថ្មហ្នឹងឯង ហើយមិនឮសួរសកម្មភាពអី បើថាទៅណា យកទៅសាលាឃុំគេនានា ក៏ខ្ញុំអត់ដឹង។

**ស៖** បាទ មិនថ្វីទេលោកសាក្សី។ ពីខាងដើមនេះ លោកត្រូវបានសួរពីបុគ្គលម្នាក់ដែលលោកបានឆ្លើយថា លោកមិនស្គាល់ទេ បុគ្គលម្នាក់ដែលមានឈ្មោះ តុល។ មានពេលមួយនោះ តុល ត្រូវបានគេយក អឿន មកដាក់ជំនួសគាត់ ដែលជាប្អូនថ្លៃរបស់ កែ ពក។ <តើ>លោកដែលឮសួរថា មានគេដឹកអាវុធទាំងឡានៗ<បញ្ជូនទៅឱ្យឈ្មោះ អឿន ដែលមកពីកងពលកងទ័ពបដិវត្តន៍ គឺកងពល៣១០ ដែរឬទេ?>

**ឆ៖** ខ្ញុំមិនដែលដឹងទេ ឋានៈប្រហែលខ្ញុំពីសភាពការណ៍អស់ហ្នឹង គឺថាព្រោះធ្លាប់នៅតែតាមភូមិ មិនដឹង។ មិនដឹងជាចលនាគេដើរយ៉ាងម៉េច អត់ដឹងផង។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណច្រើនលោកសាក្សី។ ខ្ញុំចប់ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

[១៥:០៣:១០]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ក្នុងឋានៈជាមេធាវីគាត់នេះហើយ ដែលខ្ញុំសុំចោទសំណួរ សុំការបំភ្លឺ<ព័ត៌មាន>ពីលោកមួយ<ចំនួន>។ នៅពេលដែលលោកឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ ឬក៏ជាតិ ខ្ញុំភ្លេចហើយ<> លោកបានឆ្លើយថា នៅពេលដែលលោកចាប់ផ្តើមធ្វើការជីកប្រឡាយនោះ គឺក្រោយពេលដែលជីកប្រឡាយ១មករាចប់ហើយ។ អ៊ីចឹង <តើ>លោកចង់<បានន័យថា>យ៉ាងម៉េចដែរ<ពាក្យលោក>ថា <ការងារ>ហ្នឹងចប់ហើយ <ឬក៏សម្រេចហើយ អ្វីដែលត្រូវបានបញ្ចប់> ហើយនោះ<>?

**លោក អ៊ុំ ជី៖**

**ឆ៖** កាលពី៧៧ គេធ្វើទំនប់១មករា ហើយឆ្នាំហ្នឹងខ្ញុំនៅភូមិ ប្រធានភូមិគេចាត់តាំងឲ្យខ្ញុំធ្វើចម្ការ។ ដល់គេធ្វើប្រឡាយហ្នឹងរួច ដល់មកចូលឆ្នាំ១៩៧៨ គេឲ្យខ្ញុំមកធ្វើប្រឡាយតពីទំនប់១មករាមកហ្នឹង។ ប៉ុណ្ណឹងឯង បានថាខ្ញុំមិនដឹងរឿងរ៉ាវគេ ការធ្វើទំនប់១មករាហ្នឹង។

**ស៖** អ៊ីចឹង<តើ>ខ្ញុំត្រូវយល់ថា ប្រឡាយដែលលោកបាននិយាយក្នុងសវនាការនេះ គឺ<ភ្ជាប់ទៅ>នឹងទំនប់៦មករា<>មិនមែន<ទំនប់>១មករាទេ <អ៊ីចឹង>ឬក៏យ៉ាងណា? ឥឡូវខ្ញុំឃើញលោកសហព្រះរាជអាជ្ញាគាត់ក្រោកឡើង<ប្រហែលជំទាស់ទៀតហើយ ហើយខ្ញុំសុំឲ្យគាត់កុំផ្តល់ចម្លើយទៅសាក្សីនេះមុនឲ្យសោះ>។ <ខ្ញុំត្រូវការចម្លើយពីសាក្សីមុនសិន។> ខ្ញុំគិតថា ភាគីទាំងអស់គួរតែចាំស្តាប់ចម្លើយពីសាក្សីសិន។ ខ្ញុំសូម<ឲ្យមានការស្រាយបញ្ជាក់ពីសាក្សីសិន> មុននឹងឲ្យសហព្រះរាជអាជ្ញាគាត់ជំទាស់។ <អរគុណ។>

[១៥:០៥:២៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

<អរគុណ។>ការជំទាស់នោះ<ពាក់ព័ន្ធទៅនឹងការពិតដែលថា>សាក្សី មិន<ដែល>និយាយពីទំនប់៦មករាទេ ព្រោះថារហូតដល់ពេលនេះ គឺនិយាយតែពីប្រឡាយមួយដែលភ្ជាប់<នឹង>ទំនប់១មករា<ឆ្ពោះ>ទៅតំបន់គាត់នោះទេ។ អ៊ីចឹង ហើយខ្ញុំមិន<ដឹងថាគាត់បានយោងសំណួរចេញពីប្រភពណាមក

ទេ>។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** អ៊ីចឹងខ្ញុំសូមកែសំណួរខ្ញុំ<ឲ្យបានច្បាស់ជាងនេះបន្តិច>។ លោកនិយាយថា លោកមិនដឹងអំពី<អ្វីដែលបានកើតឡើងចំពោះ>ទំនប់១មករា នោះទេ។ តើអ៊ីចឹងខ្ញុំ សុំសួរលោកថា តើលោកចង់និយាយពីប្រឡាយមួយណា? ប្រឡាយណាដែលលោកនិយាយ<នៅថ្ងៃនេះ>ថា លោកថាលោកជីកប្រឡាយនោះ? អ៊ីចឹង លោកអាចជម្រាបជូនតុលាការបានទេ <ថាតើទំនប់មួយណាដែល>ប្រឡាយ<ទាំងអស់ហ្នឹងវាភ្ជាប់ទៅ?>

**លោក អ៊ុំ ជី៖**

**ឆ៖** ប្រឡាយហ្នឹង គឺប្រឡាយតភ្ជាប់ពី១មករាមក។ ប៉ុន្តែគេធ្វើហ្នឹង គេធ្វើពីកន្លែងទំនប់មក ធ្វើបានចម្ងាយប្រហែលជា៥គីឡូ ហើយបានគេស្តុបចោលត្រឹមហ្នឹង។ ដល់ឆ្នាំ៧៨ហ្នឹង បានគេឲ្យពួកខ្ញុំតទៅ ធ្វើតហ្នឹងទៅទៀត នៅប៉ែកខាងត្បូង មកប៉ែកខាងត្បូង។

[១៥:០៦:៤២]

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថាមានគេជីកប្រឡាយបានមួយផ្នែកហើយនៅពេលដែលលោកចាប់ផ្តើមជីកប្រឡាយនោះបន្តនោះ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** គឺត្រឹមត្រូវ ដូចលោកថាអ៊ីចឹង។

**ស៖** តើប្រឡាយដែលគេជីកហើយស្រេចហើយ មុនលោកចូលទៅធ្វើការហ្នឹង ប្រឡាយហ្នឹងដំណើរការហើយឬនៅ ដើម្បីស្រោចស្រពស្រែស្រូវ<នៅក្នុងតំបន់>នោះ? >

**ឆ៖** ប្រឡាយហ្នឹងមិនទាន់ដំណើរការទេ គឺថាធ្វើបានតែទឹកដីឃុំបល្ល័ង្កហ្នឹងបន្តិចបន្តួច នៅខាងក្រោមបន្តិចៗហ្នឹង។ បើថាប្រឡាយហ្នឹងដែលខ្ញុំជីកតហ្នឹង គឺធ្លាក់មកនៅឆ្លងឃុំពីរទៀត គឺឃុំឈូកខ្សាច់ និងឃុំទ្រាល ដល់ឃុំទ្រាល ដែលគេធ្វើបន្ត គោលការណ៍គេថាឲ្យដល់ទ្រាល។

**ស៖** តើរូបលោកផ្ទាល់ធ្លាប់បានទៅទំនប់១មករាដែរឬទេ? គឺចង់សំដៅទៅលើកន្លែងដែលមានអាងស្តុកទឹក ហើយនិង<>មានស្ពាន<អីជាដើម>។ រូបលោកផ្ទាល់ លោកធ្លាប់ទៅកន្លែងសំខាន់ជាងគេនៃទំនប់១មករាហ្នឹងទេ?

**ឆ៖** ដែលពេលយួនចូលមក ក្រោយយួនចូលមកហើយ ដែលទំនប់ហ្នឹងវាគេប្រើជាសាធារណៈ: រទេះគោ រទេះអី ខ្ញុំធ្លាប់បររទេះកាត់ហ្នឹងតើ។

**ស៖** ដើម្បីឲ្យច្បាស់លាស់ជាងហ្នឹងទៀតនោះ <> ខ្ញុំចង់ដឹងថា មុនឆ្នាំ១៩៧៩ <ឬ>មុន<> ពេល<>ដែលលោកធ្វើការដឹកប្រឡាយដែលលោកនិយាយ<រៀបរាប់ប្រាប់យើង>នោះ <ថាតើ> លោកធ្លាប់ទៅទំនប់<ហ្នឹង>ដែរឬទេ? <ឬក៏ វាជាលើកទី១ហើយដែលលោកបានទៅទំនប់មេហ្នឹង ក្រោយពេលវៀតណាមចូល?>

[១៥:០៩:៣០]

**ឆ៖** អានេះដូចខ្ញុំនិយាយពីខាងដើម ព្រោះឆ្នាំហ្នឹង ខ្ញុំគេឲ្យទៅនៅចម្ការ ខ្ញុំអត់ដែលបានមកទេ ហើយមិនដែលបានទៅលេងនឹងទេ។ ទាល់តែពេលចប់ យួនចូលមកហើយ បានខ្ញុំធ្លាប់ដើរកាត់ទៅមកៗ តាមហ្នឹង ដឹកអុស ដឹកអី។ បើកាលពីសម័យហ្នឹង ពីព្រោះគេប្រគល់តែមុខព្រួញណា យើងដើរចោល ការងារយើងអត់កើតទេ។

**ស៖** សូមអរគុណ។ ឥឡូវ ខ្ញុំសូមចូលទៅនិយាយអំពីតួនាទីរបស់លោកជាប្រធានកង<>។ <លោកប្រាប់ថា លោកជាប្រធានកងគ្រប់គ្រងកម្មករ៥០០នាក់> ខ្ញុំសួរលោកថា តើអ្នកណាជាអ្នក ចាត់តាំងឲ្យលោកធ្វើជាមេកង៥០០នេះ?

**ឆ៖** ចាត់តាំងឲ្យធ្វើហ្នឹង គេដកខ្ញុំពីចម្ការមក ដល់ពួកនិរតីគាត់មកដំបូង គឺថាពួតែពួកនិរតី គឺ រងាហើយ។ ខ្ញុំពីដើម ក៏ខ្ញុំមិនដែលធ្វើអីទេ ប៉ុន្តែដល់ពេលហ្នឹងគេដកមក ខ្ញុំនៅលីវ គេថាឲ្យទៅធ្វើទំនប់ ហើយមេភូមិប្រាប់ខ្ញុំថា មិនទៅមិនបានទេ អញសុទ្ធតែគ្នាគេ អីចេះ។ ខ្ញុំ គឺឈ្មោះ ជិន នេះនិង ដុង នេះ ដែលគាត់មកឈរនៅឃុំបល្ល័ង្កហ្នឹង គាត់អ្នកចាត់តាំងឲ្យខ្ញុំដឹកនាំកម្លាំងធ្វើការ។ ឈ្មោះ ដុង ហ្នឹងគាត់ ទៅឈរផ្ទាល់នៅកន្លែងការដ្ឋានហ្នឹង។ គ្រាន់តែប៉ុណ្ណឹង។

**ស៖** តើមានមូលហេតុអីជាក់លាក់ដែរឬទេ ដែលនាំឲ្យគេចាត់តាំងអ្នកនៅលីវនោះ ទៅធ្វើការ នៅលើការដ្ឋានហ្នឹង? លោក<ទើបតែ>បាននិយាយថា គេបានចាត់តាំងលោកនោះ ដោយសារលោក នៅលីវ ហើយលោកក៏បានឆ្លើយផងដែរថា លោកជាអ្នកដឹកនាំកងនៅលីវហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោក ថា <តើ>មានមូលហេតុជាក់លាក់អី<ដែរទេ ចំពោះការចាត់តាំងនេះ>?

[១៥:១១:៥៤]

**ឆ៖** នេះគេថានៅលីវ គឺថាកម្លាំងយើងទៅនៅជាមួយវ័យកណ្ដាល គេអត់ឲ្យនៅ គេមកដល់គេ ប្រមូលឲ្យបង្កើតជាកងចល័តហ្នឹង ឲ្យទៅធ្វើ ហើយទៅនៅក្នុងពេលនោះ ខ្ញុំវាងចាស់ខែថ្ងៃជាងគេ ក៏គេ ឲ្យធ្វើទៅ។

**ស៖** ប៉ុន្តែសំណួរខ្ញុំនោះ អម្បាញ់មិញរាងខុសពីហ្នឹងបន្តិច។ ខ្ញុំកែសម្រួលសំណួរម្តងទៀត។ តើគេរើសតែអ្នកនៅលីវទេឬ ដើម្បីឱ្យចូលទៅក្នុងកងចល័តនោះ? <>

**ឆ៖** នៅក្នុងហ្នឹង ដែលរើសកងចល័តសុទ្ធ គឺលីវសុទ្ធតែម្តង អត់មានលាយអ្នកមានប្រពន្ធមានអីទេ សុទ្ធតែលីវ។

**ស៖** <>នៅក្រោមលោក<> ដែលលោកជាមេកងនោះ គឺថាមានមេក្រុម <ឬក៏អនុប្រធានកង>ដែរ។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកហើយហ្នឹងឬជាអ្នករើសមេក្រុម <ឬអនុប្រធានកង ឬយ៉ាងម៉េច>?

**ឆ៖** មេក្រុម គឺក្រុមហ្នឹងមកពីតាមភូមិគេស្រេចៗមក។ មកប្រធានភូមិគេរើសមកស្រេចៗមក គេមកនៅចូលប្រឡាយហ្នឹង ដើម្បីធ្វើការហ្នឹងឯង។

[១៥:១៣:៤១]

**ស៖** អ៊ីចឹង កាលនោះលោកជា<ថ្នាក់លើរបស់ពួកកម្មករ>ទាំងអស់<>នៅកន្លែងជីកប្រឡាយ <និងការដ្ឋានទំនប់>ហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** ទទួលកម្លាំងរួម និង ចល័តផង ហើយខ្ញុំក៏ជាមេក្រុមដែរ។ ភូមិខ្ញុំ ខ្ញុំជាអ្នកមេហ្នឹងឯង។

**ស៖** លោកបានឆ្លើយថា សមាសភាពកងរបស់លោកនោះ គឺមានប្រជាជនថ្មីផង មានប្រជាជនមូលដ្ឋានផង។ តើលោកក្នុងឋានៈជាមេកងនោះ លោកមានផ្តល់សេចក្តីណែនាំ<> ឱ្យធ្វើការប្រព្រឹត្តទៅលើប្រជាជនថ្មី និង ប្រជាជនចាស់ហ្នឹងខុសគ្នា<ដែរឬទេ>?

**ឆ៖** មិនដែលមានសកម្មភាពអស់ហ្នឹង គឺថាធ្វើៗទាំងអស់គ្នា គ្មានគិតថាចាស់ គិតថ្មី ពិសេសហ្នឹងប្រជាជនថ្មីហ្នឹង គឺកម្លាំងធំៗ ពីព្រោះនៅគេរៀនសូត្រ គេនៅចាស់ៗ បើអ្នកមូលដ្ឋានតូចៗ។ ហើយខ្ញុំមិនដែលគិតថា អ្នកនេះថ្មី អ្នកនេះចាស់ គឺធ្វើ យើងធ្វើទាំងអស់គ្នា។ គ្រាន់តែប៉ុណ្ណឹង។

**ស៖** តើក្នុងឋានៈជាមេកង លោកធ្លាប់ចេញការណែនាំទៅមេក្រុមឱ្យដាក់ទណ្ឌកម្ម ធ្វើទារុណកម្ម<លើរូបរាងកាយទៅ>លើ<កម្មករក្នុងកង>របស់លោកដែរឬទេ?

**ឆ៖** គ្មាន ខ្ញុំគ្មាន។ មានមេក្រុមខ្លះ គេមកសុំខ្ញុំធ្វើទារុណកម្មនោះ ប៉ុន្តែខ្ញុំថាមិនឱ្យធ្វើ យើងជាមនុស្សដូចគ្នា។ បើសិនជាខ្ញុំប្រព្រឹត្តអាក្រក់ ដាច់៧៩ហ្នឹង គឺក៏ខ្ញុំមិននៅរស់ដល់ពេលសព្វថ្ងៃដែរ។

[១៥:១៦:០៦]

**ស៖** មេក្រុមដែលសុំការអនុញ្ញាតធ្វើទារុណកម្ម<លើរូបរាងកាយ ឬទារុណកម្មទូទៅ> គឺថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<ជាគំនិតផ្តួចផ្តើមរបស់ពួកគេហ្នឹងផ្ទាល់ ឬក៏គេមកសុំការអនុញ្ញាតពីលោកសិន?>

**ឆ៖** គឺគ្មានទេ គឺតាមការនេះយល់ ហើយខ្ញុំពិនិត្យជាក់ស្តែងដែលនៅជាមួយគ្នា រងៗគឺថា ដូចថាកូនក្រុមខ្លះ វាគ្នាក្មេងវាច្រឡើសបើស វាដើរទៅ ជួនកាលវាឈឺអីច្រើនអីអ៊ីចឹងទៅ។ ហើយក្រុមហ្នឹងដូចខ្ញុំនិយាយពីខាងដើម មិនមែនតែចេញមួយកន្លែង ភូមិណានៅភូមិហ្នឹង ហើយក្នុងឃុំហ្នឹងវាមានប្តូរដប់ភូមិមកនៅធ្វើការហ្នឹង។

**ស៖** លោកបាននិយាយជាមួយសហព្រះរាជអាជ្ញា អំពីកិច្ចប្រជុំមួយដែលប្រព្រឹត្តទៅនៅពេលល្ងាច ដែល<ធ្វើឡើង>ដោយមេក្រុម <ឬអនុប្រធានកងនោះ>។ តើលោកដឹងដែរឬទេ ថាកិច្ចប្រជុំបែបហ្នឹង គេធ្វើរាល់ថ្ងៃ ឬក៏គេធ្វើហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ក្នុងហ្នឹង គឺមិនដែលធ្វើរាល់ថ្ងៃទេ គឺធ្វើមួយអាទិត្យធ្វើម្តង ជួនកាលមិនធ្វើ ចាំដល់ពេលថ្ងៃគេបើកវគ្គហ្នឹង យើងចាំស្តាប់ជារួមទាំងអស់គ្នា ប៉ុណ្ណឹង។

[១៥:១៨:២៦]

**ស៖** លោកបាននិយាយអំពីរបបអាហារ <និងការហូបចុក។> នៅក្នុងកងរបស់លោកនោះ តើលោករៀបចំយ៉ាងណាដែរ ដើម្បីធ្វើម្ហូបអាហារឲ្យសមាជិកកងរបស់លោក? ហើយអ្នកណាជាអ្នកទទួលបន្ទុកខាងដឹកអង្ករ ហើយ<អ្នកណាជាអ្នក>ដាំបាយឲ្យ<> សមាជិកកងហ្នឹងហូប?

**ឆ៖** នៅក្នុងកងហ្នឹងមានចាត់តាំងមួយក្រុម ឲ្យសម្រាប់ដាំបាយ និងស្ល ហើយអង្ករគេដឹកនាំពីតាប្រុកមក។ កាលហ្នឹងតាប្រុកហ្នឹងគេចូលឃុំបល្ល័ង្គ ប៉ុន្តែបច្ចុប្បន្ននេះ គេនៅក្នុងឃុំឈូកខ្សាច់។ គេដឹកពីហ្នឹងយកមកឲ្យ។ ហើយការហូបចុក សម្ល លោកដឹងហើយ យុវជនដែលចេះធ្វើអីប៉ុន្មាន ហើយវាអត់មានសាច់ឈាមត្រឹមត្រូវផង មានតែស្ងោរៗហ្នឹង មិនដឹងគេស្ងោរអីគេ វាលេបមិនចង់ចូល ប៉ុន្តែបើយើងមិនស៊ី វាអត់។

**ស៖** លោកនិយាយថា អង្ករហ្នឹងយកមកពីភូមិ។ អ៊ីចឹងពេញមួយរយៈពេល<ប្រាំ ប្រាមួយខែ> ដែលលោកធ្វើការនៅកន្លែងជីកប្រឡាយហ្នឹង ប្រាំប្រាំមួយខែហ្នឹង គឺដឹកអង្ករហ្នឹងមកតែពីភូមិតែមួយទេ ឬក៏មានខែខ្លះដឹកមកពីភូមិផ្សេងដែរ?

**ឆ៖** គ្មានទេ។ ដឹកតែពីភូមិមួយហ្នឹងទេ ប៉ុន្តែថាប្រធានគេនោះចេះតែបញ្ជាក់មកខ្ញុំហ្នឹង ឲ្យធ្វើស្ថិតិឲ្យច្បាស់លាស់។ ហើយដូចខ្ញុំជម្រាបពីខាងដើម យុវជនស៊ីច្រើន ហើយគេដកទៅទ័ពខ្លះ គេរៀបការ តែរៀបការគេទៅនៅតាមភូមិ ហើយរបបអង្ករនោះ ខ្ញុំក៏មិនដែលធ្វើត្រឹមត្រូវទៅតាមកំណត់មនុស្ស

ទេ។ បើៗធ្វើទៅតាមកំណត់មនុស្ស គឺស៊ីមិនឆ្អែតតែម្តង។

**ស៖** តើប្រធានភូមិហ្នឹងជាអ្នកផ្តល់ស្បៀងឲ្យលោក ឬក៏មានអង្គភាពណាផ្សេងមួយទៀតដែល <ផ្តល់>របបអាហារហ្នឹងឲ្យលោក?

[១៥:២១:០៣]

**ឆ៖** ចំណែកអង្ករ គឺមានតែភូមិតាប្រុកមួយហ្នឹងឯង អ្នកដឹកមកឲ្យ។ ចំណែកម្ហូប យកក្នុងឃុំ គេមានកន្លែងពាណិជ្ជឃុំរបស់គេ។ គេឲ្យព្រលឹមឡើង គេឲ្យទៅយក។ គ្រាន់តែប៉ុណ្ណឹង។

**ស៖** នៅលើការដ្ឋានការងារតែម្តងឬ ដែលគេធ្វើម្ហូបអាហារឲ្យកម្មករធ្វើការនោះ?

**ឆ៖** ធ្វើនៅកន្លែងការដ្ឋានហ្នឹងឯង នៅកន្លែងជិតមាត់ទឹកដែលប្រឡាយគេជីកមុន ដែលយើងតភ្ជាប់មក វាធ្វើនៅនឹងមាត់ទឹកហ្នឹងឯង។

**ស៖** តើក្នុងឋានៈជាមេកង តើលោកដែលធ្លាប់អនុញ្ញាតឲ្យអ្នកធ្វើការនៅក្រោមបង្គាប់របស់លោកដើម្បីទៅនេសាទត្រី ដើម្បីយកមកបំពេញ<បន្ថែមទៅលើ>របបអាហារដែលគេផ្តល់ឲ្យនៅពេលនោះដែរឬទេ?

**ឆ៖** មិនដែលទេ ពីព្រោះម្ហូបពីឃុំគេធានាខុសត្រូវហើយ។ យើងតែទៅធ្វើខុសការចាត់តាំង ពីព្រោះអាហ្នឹងចេញជាទ្រង់ទ្រាយ តែយើងចេញជារូបរាងទៅរក គឺថាអាហ្នឹងគេឃើញ យើងធ្វើមិនបានទេ ចាំយកតែពីគេទេ។

**ស៖** លោកនិយាយយ៉ាងដូច្នេះ ដោយសារលោកធ្លាប់ឃើញមានការបន្ថយរបបអាហារ <ដោយសារតែឃុំគេបានដឹងព័ត៌មានហ្នឹង> ឬក៏យ៉ាងម៉េច?

[១៥:២៣:១៤]

**ឆ៖** ពីព្រោះអាហារ គោលបំណងគ្មានបន្ថយទេ ប៉ុន្តែថាបើយើងចាត់តាំងឲ្យកម្លាំងយើងទៅរក ហ្នឹងវាខុសពីបទបញ្ជារបស់គេ គឺថាបន្លែ -- ម្ហូបគេរកឲ្យយើងហើយ យើងទៅរកអីទៀត។ អ៊ីចឹងបានយើងមិនហ៊ានទេ ចាំយកតែពីគេទេ ទោះគេឲ្យកម្រិតណា ក៏យើងចេះតែហូបទៅសម័យហ្នឹងនោះ។

**ស៖** ខ្ញុំនិយាយយ៉ាងដូច្នេះ ពីព្រោះយើងមានសាក្សីមួយទៀតដែលបានមកផ្តល់សក្ខីកម្មនៅទីនេះ ហើយដែលជាប្រធានកងដែរ គឺសាក្សី ឱ ហូ ដែលមកផ្តល់សក្ខីកម្មនៅទីនេះ<នៅថ្ងៃទី១៩ ឧសភា ២០១៥>គឺឯកសារ E1/301.1។ មុនម៉ោងប្រាំបួន សែសិបបីនាទីបន្តិចនោះ គាត់បាននិយាយថា ក្នុងឋានៈគាត់ជាមេកង គាត់អនុញ្ញាតឲ្យអ្នកនៅក្រោមបង្គាប់របស់គាត់នេសាទត្រី ហើយគាត់មិនដែលធ្លាប់

ត្រូវបានគេកាត់បន្ថយរបបអាហារនោះទេ។ អ៊ីចឹង<ហើយបាន>ខ្ញុំសួរលោក<ពីចំណុចនេះ។> <លោកសាក្សី តើលោកមានធ្លាប់ធ្វើដូច ឱ ហូ ដែរទេ ក្នុងការអនុញ្ញាតកម្មករចេញទៅរកត្រី?>

**ឆ៖** ខ្ញុំមិនដែលបានទេ ពីព្រោះនៅការដ្ឋានតែចេញទៅយុវជន គេដឹងថា កងនេះមកពីផ្នែកណា។ ដូចលោក ឱ ហូ ហ្នឹងគាត់មិនមែនជាប្រធានកងទេ គាត់ជាប្រធានភូមិ ហើយគាត់មានសិទ្ធិចាត់ចែង ហើយអ៊ីចឹងបានថា ហើយគាត់ៗនិយាយអ៊ីចឹងក៏ខ្ញុំឯកភាពជាមួយគាត់ដែរ ពីព្រោះហ្នឹងនៅភូមិមួយៗ ស្តាប់រស់នៅលើមេភូមិ អ៊ីចឹងបើមេភូមិចាត់ចែងអាហ្នឹងខ្ញុំ បើកន្លែងខ្ញុំ ការដ្ឋានខ្ញុំ អត់បានទេ។

**ស៖** អ៊ីចឹង បានន័យថា នៅក្នុង<>កងរបស់លោកហ្នឹងគឺ ប្រធានភូមិទេ<>ដែលលោក<អាចទៅបើក>អង្ករ<បាន ហើយ> គឺគាត់មាន<សិទ្ធិអំណាចផ្សេងៗទៀតផងដែរ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរទេ?>

[១៥:២៥:៥៣]

**ឆ៖** បើក្នុងភូមិ ដោះស្រាយក្នុងភូមិ ភូមិគេគ្រប់គ្រងភូមិ គេអាចមានសិទ្ធិចាត់តាំងកម្លាំងទៅនេសាទ គេឱ្យទៅរកថែមអ៊ីចឹងបាន។ ហើយបើយើងខ្ញុំនៅតាមកងចល័ត គឺតាមភូមិគេដឹកមកឱ្យ ឃុំគេមានកន្លែងគេឱ្យហើយ គ្រប់គ្រាន់ មិនគ្រប់គ្រាន់យើងអត់បានទៅរកទេ។

**ស៖** ក្នុងឋានៈលោកជាមេកងហ្នឹង តើលោកធ្លាប់ស្នើទៅប្រធានភូមិ ដើម្បីសុំការអនុញ្ញាតដើម្បីទៅរកស្បៀងបន្ថែមដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានសុំទេ ពីព្រោះបានថាមិនបានសុំ ថាយើងទៅសុំទៅ គេថាស្បៀងគេឱ្យស្រេចហើយ យើងចាំទៅធ្វើយ៉ាងម៉េចទៀត។ ហើយបើយើងទៅថែមទៀត គេថាយើងអត់មានការលត់ដំ ហើយសម័យហ្នឹងគេឱ្យលត់ដំ។

**ស៖** លោកក៏បាននិយាយផងដែរអំពីទឹកដែលកម្មករប្រើប្រាស់ដើម្បីហូប ហើយនិងដើម្បីងូតសម្អាតខ្លួន <ហើយ>លោកថាទឹកហ្នឹងមិនស្អាតទេ <មិនមែនជាទឹកអាចផឹកបានទេ>។ នៅថ្ងៃទី០២ មិថុនា<ឆ្នាំ២០១៥ នៅចំពោះមុខអង្គជំនុំជម្រះ> យើងមានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សៀង សុវិដា គឺឯកសារ E1/308.1។ គាត់បានមកនិយាយអំពីកន្លែងដែលគាត់ធ្វើការ ថាមានការចាត់វិធានការដើម្បីឱ្យដាំទឹកហូប។ អ៊ីចឹងសំណួរខ្ញុំចង់សួរថា នៅ<ពេលណាមួយ>នោះ លោក<>ដែលចាត់វិធានការ<ស្រដៀងគ្នានេះទេគឺ> ឱ្យដាំទឹកហូបទេ<>?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** នៅសម័យនោះ ដោយខ្វះឧបករណ៍ផង អ្នកដាំ ហើយតម្រូវការគ្នាច្រើន គឺខ្ញុំមានការខ្វះខាត មិនបានណែនាំឲ្យដាំជាប្រចាំទេ គឺថាប្រើទៅតាមទឹកធម្មជាតិ ឃើញថាគគ្រិចអ៊ីចឹងមែន។

**ស៖** លោកបានឆ្លើយថា <កម្មករអាច> សុំដើរហើរ<បាន>នៅថ្ងៃសម្រាក។ បើតាមខ្ញុំយល់ចម្លើយរបស់លោកនោះគឺថា <ថ្ងៃឈប់សម្រាកគឺ>រាល់១០ថ្ងៃម្តង។ នៅក្នុងកងរបស់លោក បើសិនជាអ្នកធ្វើការ<>ចង់ដើរហើរ<ទៅកន្លែងណាមួយ>នោះ តើគេត្រូវសុំច្បាប់ទៅអ្នកណា សុំការអនុញ្ញាតពី<>មេក្រុម ឬក៏សុំច្បាប់ទៅលោកដែលជាមេកង?

[១៥:២៨:១៤]

**លោក សេង លាង៖**

លោកប្រធានខ្ញុំឮលោកតំណាងមេធាវីគាត់ប្រើពាក្យ “បើសិនជា” ដូច្នេះខ្ញុំគិតថាសំណួរនេះ ជាការឲ្យសាក្សីសន្និដ្ឋាន។

**កញ្ញា អង់តា ហ្គីសសេ៖**

មិនបញ្ហាអ្វីទេ ខ្ញុំគិតថាប្រហែលជាបញ្ហាភាសាតែប៉ុននុ៎ងទេ។ ឥឡូវខ្ញុំកែសំណួររបស់ខ្ញុំ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងនៅពេលដែលមនុស្សម្នាក់ចង់ដើរហើរពេលថ្ងៃសម្រាកនោះ តើគាត់ត្រូវសុំច្បាប់ទៅមេក្រុម ឬក៏មេកង?

**លោក អ៊ុំ ជី៖**

**ឆ៖** ពេលថ្ងៃសម្រាក គេមិនដែលសុំមកខ្ញុំទេ គឺមេក្រុមរបស់គេមានគ្រប់គ្នា។ ហើយពេលសម្រាកហ្នឹង ពេលព្រឹកត្រូវទៅធ្វើមីទ្ទិង ដូចខ្ញុំលើកខាងដើមហ្នឹង គេលើកពីគោលនយោបាយ ពីការចំណេញ ឬខាត ពីការដឹកនាំ។ រួចទៅ គ្មានដែលយុវជនណាមកកន្លែងវិញទេ មានមួយចំនួនតិច គឺពាក់កណ្តាលទៅភូមិ ពាក់កណ្តាលមកណោះ។ ហើយទៅដល់ភូមិ ដឹងគេបានអីហូប ក៏ខ្ញុំមិនដឹងដែរ មិនដែលទៅតាមដានឲ្យច្បាស់លាស់ដែរ។ គ្រាន់តែគេទៅៗ ទៅបាត់ទៅ។ រួចល្ងាចដល់ថ្ងៃក្រោយ គេមកធ្វើការវិញដដែល អត់ដឹង។

[១៥:៣០:៥១]

**ស៖** បើតាមចម្លើយរបស់លោកនោះ ខ្ញុំយល់ថា គេចេញការអនុញ្ញាតឲ្យអ្នកធ្វើការ<អាច>ទៅភូមិ<របស់ពួកគេបាន>។ បើសិនជាមិន<មែន> លោកអនុញ្ញាតទេ គឺអ្នកធ្វើការទាំងអស់នុ៎ង កម្មករ

ទាំងអស់នុ៎ង សូមច្បាប់ទៅមេក្រុមគេតែម្តង ឬក៏យ៉ាងម៉េច?

**ឆ៖** គេសុំច្បាប់ទៅពីមេក្រុមគេ។ ខ្ញុំក៏មិនដែល ក្រែងលោមិនចាប់អារម្មណ៍ពីបញ្ហាណាមួយទេ ព្រោះថ្ងៃហ្នឹងជាថ្ងៃសម្រាក។ ស្រេចតែមេក្រុមគេ គេសុំទៅណា ទៅៗដើរលេង ទៅភូមិអីចឹង។ អ្នកខ្លះមកវិញដេកទៅ នៅនឹងរោងទៅ។ ហ្នឹងគ្រាន់តែប៉ុណ្ណឹង។

**ស៖** ឥឡូវខ្ញុំសូមនិយាយ<ប្រធានបទ>មួយទៀត។ លោកបាននិយាយជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិ អំពីវត្តបារាយណ៍ជាន់ដែក។ លោកបានឆ្លើយប្រាកដថា ទីនោះជាមន្ទីរសន្តិសុខ ហើយៗបើក្រោយមក គឺត្រូវគេដូរទីតាំងទៅកន្លែងផ្សេងទៀត។ ហើយពេលមួយលោកបានទៅវត្តនុ៎ង ដើម្បីចូលរួមកិច្ចប្រជុំមួយ។ អ៊ីចឹងខ្ញុំសួរលោកថា លោកច្បាស់ទេដែលថាខ្លួនលោកផ្ទាល់នេះ បានទៅចូលរួមប្រជុំមួយ ដែលប្រព្រឹត្តឡើងនៅក្នុងវត្តបារាយណ៍ជាន់ដែកហ្នឹង?

**ឆ៖** ពេលហ្នឹងខ្ញុំបានចូលទៅប្រជុំមែន ដែលពេលសន្តិសុខរើអស់ ហើយកន្លែងហ្នឹង គេដាក់ជាសិប្បកម្មតាៗនៅក្នុងហ្នឹង ហើយខ្ញុំធ្លាប់ចូលទៅប្រជុំតើ។

[១៥:៣២:៤៧]

**ស៖** លោកសាក្សី ខ្ញុំចោទសំណួរនេះទៅលោកនោះ ព្រោះថាសវនាការថ្ងៃទី២៥ ឧសភា ឆ្នាំ២០១៥ មានសាក្សីម្នាក់<មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ឈ្មោះ មាស ឡាយហួរ> គឺឯកសារ E1/304.1។ ក្រោយម៉ោង<១៥:៥១:១៩>បន្តិច គាត់បាននិយាយថា មន្ទីរសន្តិសុខហ្នឹង បន្តដំណើរការរហូតដល់ពេលវៀតណាម<ចូល>ឯណោះ។ អ៊ីចឹងសំណួរខ្ញុំហ្នឹង <តើអ្វីដែលគាត់និយាយអាចខុសទេ? ហើយ> ខ្ញុំចង់សួរលោកថា <តើ>លោកប្រាកដក្នុងចិត្តហើយថា ន៎មន្ទីរសន្តិសុខហ្នឹង គឺត្រូវបានផ្លាស់ប្តូរទីតាំង<មុនពេលដួលរលំ>របបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** គឺច្បាស់អ៊ីចឹងមែន។ ខ្ញុំមិនមែនចេះតែនិយាយដោយគ្មានការពិត។ បើមិនជឿ លោកទៅតាមដានសួរប្រជាពលរដ្ឋនៅជិតៗហ្នឹង តើមែនឬមិនមែន។ អានេះក្រែងលោខ្ញុំចេះតែថាពន្លើស ឬក៏ឆ្លើយយករួចខ្លួន គឺកន្លែងហ្នឹង គេដូរពីកន្លែងហ្នឹង គេទៅនៅនឹងកន្លែងថ្នល់បែកផ្សារកំពង់ថ្មសព្វថ្ងៃ ប៉ុន្តែកន្លែងហ្នឹងមិនចេញជាទ្រង់ទ្រាយធំទេ អ្នកខ្លះអត់ទាំងដឹងផង កន្លែងសន្តិសុខ។ សុទ្ធតែពួកនិរតីគេទៅទទួលខុសត្រូវកន្លែងហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែសហភាតារបស់ខ្ញុំលោក គង់ សំអុន គាត់សុំសួរបន្ត

លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៣៤:៣៦]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក អ៊ុំ ជី! ខ្ញុំចង់សួរបញ្ជាក់លោកអំពីតួនាទីរបស់លោកដែលលោកថា លោកមើលការខុសត្រូវយុវជនកងចល័ត៥០០នាក់។ ខ្ញុំឮលោកបញ្ជាក់ថា ជាមេកង។ តើលោកអាច បញ្ជាក់បានទេថា ជាមេកងថ្នាក់ឃុំ ឬក៏ថ្នាក់ស្រុក ឬក៏ថ្នាក់ណាផ្សេង ទាក់ទងទៅនឹងតួនាទីរបស់លោក នេះ?

**លោក អ៊ុំ ជី៖**

**ឆ៖** តួនាទីរបស់ខ្ញុំកាលហ្នឹងគឺថ្នាក់ឃុំ ហើយចេញពីភូមិទាំងអស់គ្នានៅក្នុងឃុំ ទៅនៅម្ដុំហ្នឹង។ ថ្នាក់ឃុំ ខ្ញុំ។

**ស៖** បាទ សូមអរគុណ។ អ្នកណាគេដែលលោកត្រូវរាយការណ៍អំពីសកម្មភាពការងារ?

**ឆ៖** ដែលខ្ញុំរាយការណ៍ពីសភាពការងារនៅទទួលមុខព្រួញហ្នឹង រាយទៅឲ្យឈ្មោះ ដុង ដែល គាត់ជាអនុប្រធានឃុំ គាត់ទៅឈរនៅការដ្ឋានហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចុះលោកគ្រប់គ្រងអ្នកណាខ្លះដែលជាមេក្រុម ឬក៏មេកងបន្ទាប់? ជា ការបែងចែករចនាសម្ព័ន្ធថ្នាក់ក្រោមរបស់លោកហ្នឹងជាអ្វីដែរ? លោកអាចបញ្ជាក់បានទេ?

[១៥:៣៦:៣០]

**ឆ៖** ជារចនាសម្ព័ន្ធ ដូចខ្ញុំនិយាយហូរហែហើយ គឺថាមានតាមភូមិ កងៗក្រុមៗតាមភូមិ ខ្ញុំ ទទួលតាមកងតាមក្រុមៗហ្នឹង នាំដឹកនាំធ្វើការ អត់មានបញ្ហាពីថ្នាក់ណាទេ គឺថាតាមតែគោលការណ៍ របស់មេឃុំដែលគេប្រធានមុខព្រួញហ្នឹងឯង។ មានតែបញ្ជាតាមប៉ុណ្ណឹងឯង។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឃុំរបស់លោក លោកអាចបញ្ជាក់បានទេថា មានប៉ុន្មានភូមិ ដែរ ដែលកងចល័តមកធ្វើការក្រោមការគ្រប់គ្រងរបស់លោក?

**ឆ៖** នៅសម័យហ្នឹង ក្នុងឃុំកាលពីសម័យហ្នឹងមាន១០ភូមិ ដែលមកធ្វើការរួមនៅកន្លែងការដ្ឋានរួមរបស់ឃុំគេហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចុះក្នុងភូមិនីមួយៗ គេបែងចែកជាក្រុមតូចៗទៀត ឬមួយក៏ជាក្រុមសម្រាប់ភូមិហ្នឹងតែមួយទេ?

**ឆ៖** ភូមិមួយៗ គេបែកក្រុមជាតូចៗ។ ភូមិខ្លះតូចគ្នាតិច ចែកជាក្រុមតូចៗ បាន១០នាក់ក្នុងមួយក្រុម។ ភូមិណាធំទៅ បាន១០នាក់ដូចគ្នា ប៉ុន្តែមានប្រាំក្រុមតូចទៀតអីចឹងទៅ។ កាលណាលើសពីហ្នឹង ក៏ចាត់ទៅតាមហ្នឹងឯង។

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងការងារគ្រប់គ្រងទៅលើមេក្រុមក្នុងភូមិនីមួយៗ លោកអាចបញ្ជាក់បានទេថា លោកបានធ្វើអ្វីខ្លះ?

**ឆ៖** ក្នុងក្រុមនីមួយៗ តាមភូមិមួយៗ ខ្ញុំតែងតែនិយាយតាមមេក្រុមធំៗថា យើងត្រូវឧស្សាហ៍អប់រំកុំឱ្យកូនក្មេងដើរតាពីសតាពាស ពីព្រោះថ្នាក់លើឃើញ គេថាយើងហ្នឹងក្តាប់កម្លាំងមិនបាន ម៉្លោះហើយខ្ញុំតែងតែនិយាយអីចឹង។ គ្រាន់តែប៉ុណ្ណឹងឯង។

[១៥:៣៩:៣៩]

**ស៖** បាទ សូមអរគុណ។ មុននេះ លោកមានប្រសាសន៍អំពីការស្នើសុំរបស់មេក្រុមក្នុងការដាក់វិន័យកូនក្រុមរបស់លោក ប៉ុន្តែលោកបដិសេធ។ ខ្ញុំចង់សួរលោកថា តើនៅក្នុងកងរបស់លោក ក្នុងឃុំរបស់លោក មានដែលមេក្រុម ឬក៏មេកងក្នុងភូមិណាដែលដាក់ទណ្ឌកម្ម ដោយមិនបានឆ្លងកាត់ការសម្រេចរបស់លោកដែរទេ?

**ឆ៖** តាមខ្ញុំពិនិត្យមើលទៅ មិនដែលមានទេ មិនដែលក្រុមណាហ៊ានធ្វើទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការផ្តាច់របបអាហារប្រចាំថ្ងៃ តើលោកមានករណីបែបហ្នឹងកើតឡើងទេ សម្រាប់កងចល័តនៅក្នុងក្រុមរបស់លោក?

**ឆ៖** សូមឱ្យបញ្ជាក់ម្តងទៀត ខ្ញុំមិនយល់ពីសំណួរដែលលោកសួរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបញ្ជាក់សាជាថ្មី ទាក់ទងទៅនឹងការផ្តាច់របបអាហារប្រចាំថ្ងៃ ដោយសារតែយុវជន ឬក៏កងចល័តណាម្នាក់ គាត់មិនបានគោរពតាមវិន័យ។ ហើយខ្ញុំសួរថា តើមានករណីផ្តាច់អាហារនោះដែរឬទេ នៅក្នុងក្រុម ឬក៏ក្នុងកងរបស់លោក?

**ឆ៖** តាមការពិនិត្យទៅគ្មានដែលផ្តាច់អាហារទេ ពីព្រោះតែពេលនេះទៅយកនៅកន្លែងចុងភៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គេចំហុយឡាំងសឹង ដាក់មួយក្រុមៗ មួយក្រុមមួយថាសៗ ឲ្យស្រេចៗអ៊ីចឹងហើយ។ មិនដែលឮសួរថា អ្អេ! ប្រធានកងនេះ ផ្តាច់អាហារយុវជននេះ គឺមិនដែលឃើញមាន។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចម្លើយមួយដែលលោកបានបញ្ជាក់មុននេះ ថាមុនពេលដែលលោកត្រូវបានបញ្ជាឲ្យ ឬក៏បញ្ជូនឲ្យមកកាន់ការដ្ឋានធ្វើប្រឡាយទំនប់តភ្ជាប់ពីទំនប់១មករា លោកបានបញ្ជាក់ថា ឈ្មោះ ដុង ដែលជាមេឃុំ អម្បាញ់មិញលោកថា ជាមេឃុំរង បាននិយាយថា លោកត្រូវតែមកធ្វើដោយសារតែអ្នកដែលសន្តិសុខជាដើមសុទ្ធតែជាគ្នាគេ។ លោកអាចបញ្ជាក់បានទេ ពាក្យថា "សុទ្ធតែជាគ្នាគេនេះ" មានន័យដូចម្តេចដែរ?

[១៥:៤៣:១៧]

**ឆ៖** បានតែខ្ញុំមានប្រសាសន៍ថា "សុទ្ធតែគ្នាគេ" ពីព្រោះមនុស្សដែលនៅភូមិជាមួយគ្នា អាចធ្វើទៅដឹងទឹកចិត្តគ្នា អាចហ៊ាននិយាយលេងខ្លះ និយាយមែនខ្លះ ហើយដល់ពេលពួកនិរតីមកគឺពួកអស់ហ្នឹង គឺគេទម្លាក់អស់សិទ្ធិ អត់មានសិទ្ធិអី។ ម្ល៉ោះហើយ នៅខ្លះពីរបីនាក់អីនៅ ក៏សុទ្ធតួនាទីក្រោមៗគេបង្អស់ ហើយចេះតែមានការព្រួយបារម្ភ វាបាក់ស្បាតពីអង្គាល៧៧ រហូតមក។ អាហ្នឹងឃើញ ចេះតែ ការព្រួយបារម្ភ មកដល់ចេះតែនិយាយណែនាំគ្នាទៅ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា វាមានការបែងចែកយ៉ាងដូចម្តេចខ្លះ រវាងអ្នកដឹកនាំមកថ្មី ហើយនិងអ្នកមូលដ្ឋានចាស់នៅពេលនោះ?

**ឆ៖** ខ្ញុំមិនយល់ដែរ។ កាលពីសម័យនោះ កាលពីដើម អ្នកនៅកន្លែងណាធ្វើការកន្លែងហ្នឹង អប់រំប្រជាជនកន្លែងហ្នឹង ដឹកនាំប្រជាជនកន្លែងហ្នឹងធ្វើការ ដល់ពេលឆ្នាំ៧៧ហ្នឹង ដល់ពួកនិរតីមក គឺគោលការណ៍របស់គេ គឺថាអ្នកយើងចាស់ៗហ្នឹង គេទម្លាក់ចោលអស់ គេដកសិទ្ធិដកអីហើយ។ ម្ល៉ោះហើយមិនហ៊ាន។ អ៊ីចឹងបានថា ពួកហ្នឹងមកថ្មីហ្នឹងបានដូចជា រាងសាហាវៗបន្តិច ម្ល៉ោះហើយខ្លាច។

[១៥:៤៥:៣៣]

**ស៖** បាទ សូមអរគុណ។ លោកបានអាចបញ្ជាក់បានទេថា មូលហេតុអីបានជានាំឲ្យមានការខ្លាចគ្នា រវាងក្រុមកម្មាភិបាលមកថ្មី ហើយនិងក្រុមរបស់លោកនោះ?

**ឆ៖** ខ្ញុំមិនច្បាស់ មិនយល់ ពីព្រោះឃើញមកតែអ៊ីចឹង កាចហើយ មិនដឹងជាគោលការណ៍ហ្នឹងយ៉ាងម៉េចក៏ខ្ញុំអត់ដឹង។ គ្រាន់តែខ្លាចៗ ធ្វើការបានមួយថ្ងៃ គឺរស់មួយថ្ងៃ គឺថាលែងទុកចិត្តគ្នាអស់ហើយ អង្គាល់ហ្នឹង។

**ស៖** បាទ សូមអគុណ។ ទាក់ទងទៅនឹងការរៀបការរបស់លោក ហើយនិងការរៀបការរបស់យុវជនដទៃទៀតនៅក្នុងកងចល័ត ខ្ញុំចង់ ដំបូងខ្ញុំចង់សួរថា តើលោកមានធ្លាប់រៀបចំឲ្យមានការរៀបការរវាងក្រុមកងចល័ត ពីកងចល័តមួយទៅកងចល័តមួយទៀត ឬក៏ក្នុងក្រុមរបស់លោកដែរទេ?

**ឆ៖** សម័យនុ៎ងធ្លាប់មាន ដូចថាការយុវជនខ្លះស្រឡាញ់នារី ដូចថា យុវជន "ក" ស្រឡាញ់នារី "ខ" មកសុំទៅ ខ្ញុំថាឲ្យប្រធានភូមិគេធ្វើប្រវត្តិរូបឲ្យទៅមេឃុំទៅ ពីព្រោះខ្ញុំអត់មានសិទ្ធិធ្វើប្រវត្តិរូបឲ្យគេទេ។ គ្រាន់តែសម្រេចតែប៉ុណ្ណឹងឯង។

**ស៖** លោកនិយាយថា សម្រេចប៉ុណ្ណឹង សម្រេចរឿងអី?

**ឆ៖** វាការងារហ្នឹងសម្រេច គ្រាន់តែមានយោបល់ គ្រាន់តែផ្តល់ជាយោបល់ប៉ុណ្ណឹង មិនហ៊ានសម្រេចថា អ៊ូ! ធានាអះអាង ថាខ្ញុំត្រូវតែឲ្យរៀបការ។ អាហ្នឹងទាល់តែប្រធានភូមិគេធ្វើប្រវត្តិរូបពីភូមិមក បានយើង គេសុំយើងយកពីកម្លាំង ដកពីកម្លាំងធ្វើប្រឡាយហ្នឹងទៅ បានរៀបការបាន។ មិនមែនយើងមានសិទ្ធិថា អ៊ូ! ឲ្យត្រូវតែរៀបការឯណា។ បានតែខ្ញុំដូចនិយាយបញ្ជាក់ហើយបញ្ជាក់ទៀតថា យើងមានសិទ្ធិគ្រាន់តែឲ្យ ប្រាប់ ផ្តល់ជាព័ត៌មាន ឲ្យទៅទាក់ទងមេភូមិគេទៅ។

[១៥:៤៨:១៨]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការរៀបការនេះដែរ លោកបានបញ្ជាក់ថា មេភូមិជាអ្នកសម្រេចទៅលើសំណើសុំរបស់យុវជន។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់មកវិញថា តើមានការរៀបអាពាហ៍-ពិពាហ៍ណា ដែលកើតឡើងចេញពីមេឃុំ ឬក៏មេភូមិបញ្ជាមកលោកថា ឲ្យទៅ -- ឲ្យចាត់ចែងយុវជនណាទៅរៀបការដែរទេ?

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយតប!

**លោក អ៊ុំ ជី៖**

**ឆ៖** ខ្ញុំដែលមេភូមិ មេឃុំគេពិនិត្យប្រវត្តិរូបរួចអស់ សម្រេចថ្ងៃការ ខ្ញុំធ្លាប់បានចូលរួមជាមួយគេដែរ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សំណួរៗរបស់ខ្ញុំ គឺទាក់ទងទៅនឹងការរៀបការ ដែលស្នើឡើងដោយមេភូមិ ឬក៏មេឃុំ មិនមែនជាការស្នើឡើងដោយបុគ្គលដែលត្រូវរៀបការទេ។ ចម្លើយរបស់លោកមុននេះ លោកថា

កាលណាបើមានភាគីណាគេចង់រៀបការ គេស្នើទៅ លោកជូនដំណឹងទៅមេភូមិ មេឃុំ។ អ៊ីចឹងខ្ញុំចង់សួរបញ្ច្រាសត្រឡប់មកវិញ ថាតើមានករណីដែលមេភូមិ ឬមេឃុំប្រាប់មកលោក ឬក៏បញ្ជាមកលោកឱ្យបញ្ជូនយុវជនណាទៅរៀបការ ដោយមិនមានការយល់ព្រមពីបុគ្គលខ្លួនឯងហ្នឹងទេ?

**ឆ៖** សុំឱ្យបញ្ជាក់ម្តងទៀត ខ្ញុំដូចជាស្តាប់មិនបាន មិនយល់។

[១៥:៥០:៣០]

**ស៖** បាទ ខ្ញុំអាចបញ្ជាក់សាជាថ្មី។ ខ្ញុំចង់ដឹងថា តើមេភូមិ ឬក៏មេឃុំបញ្ជាមកលោក ឬក៏បង្គាប់មកលោក ដើម្បីឱ្យបញ្ជូនយុវជន ឬកងចល័តណាម្នាក់ទៅរៀបការ ដោយមិនមានការយល់ព្រមពីយុវជននោះដែរឬទេ? លោកស្តាប់បានទេ?

**ឆ៖** នៅកន្លែងខ្ញុំ ដូចមិនមាន។ យុវជនដែលមានជាមនោសញ្ចេតនារួចហើយ បានគេមកសុំយើង។ មិនដែលចាប់បង្ខំអ្នកណាថាត្រូវទៅយកនារីនេះ យក ដូចមិនដែល ថាមិនដែលតែម្តង មិនដែលមានកន្លែងខ្ញុំនោះ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងចំណុចមួយទៀត លោកមានប្រសាសន៍រួចហើយអំពីការចាប់មនុស្សប្រាំគ្រួសារ ដោយមេភូមិយកទៅសម្លាប់។ ខ្ញុំចង់ថាសួរថា តើលោកស្គាល់ឈ្មោះមេភូមិដែលបញ្ជានោះដែរទេ?

**ឆ៖** ដំណាក់កាលនៅកាលហ្នឹង ដែលរើសប្រជាជនទៅហ្នឹងគឺ ហេង និង លាក់ គាត់នៅជាប្រធានសហករណ៍ ហើយគាត់រើសទៅ ហើយខ្ញុំក៏មិនឃើញច្បាស់នឹងភ្នែកដែរ ពីព្រោះខ្ញុំនៅចម្ការ។ ដល់ពេលខ្ញុំមកវិញ បាត់ទៅ ខ្ញុំសួររកគេ គេថាអង្គការបោសសម្អាតហើយ។ ហើយឈ្មោះដូចខ្ញុំរាប់រៀបនៅក្នុងឯកសារចាស់ នៅជិតផ្ទះខ្ញុំគឺមាន តាឆេង-យាយអ្ញូ និង តាគិន-យាយម៉ាន់ ហើយគាត់នៅជិតផ្ទះខ្ញុំ ធ្លាប់និយាយទំនាក់ទំនងលេងសើច ដែលពេលមកពីចម្ការម្តងៗ។ ដល់ពេលនេះមកស្ងាត់ ខ្ញុំសួររកហើយគេថាបោសសម្អាតអស់ហើយ។ ហើយខ្ញុំមានសិទ្ធិអីទៅដេញដោល គ្មានទេ គឺចាប់បណ្តោយ។

[១៥:៥៣:០៦]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ឱ្យច្បាស់បានទេថា លោកដឹងពីការបាត់ហ្នឹងដោយរបៀបណា? ក្រៅពីថាលោកមកលេងផ្ទះ មានព័ត៌មានអ្វីបន្ថែមទៀតទេ ទាក់ទងទៅនឹងការបាត់មនុស្សប្រាំគ្រួសារនេះ?

**ឆ៖** ខ្ញុំមិនមានសំណួរអីឆ្លើយទៀតទេ។ គ្រាន់តែគេដឹងថា សួរគេថា អង្គការឱ្យទៅនៅភូមិថ្មី

មិនដឹងជាភូមិណា។ យើងប៉ានបញ្ជាក់ដេញដោល គឺសម័យហ្នឹងមិនប៉ានទេ។

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញ លោក តាមសក្ខីកម្មរបស់លោកអំមិញ លោកថាអង្គការបញ្ជូនគាត់ហ្នឹងទៅនៅភូមិថ្មី ក៏ប៉ុន្តែលោកសន្និដ្ឋានថា មេភូមិយកគាត់ទៅសម្លាប់។ តើអ៊ីចឹងទេ?

**ឆ៖** ការ--

**លោក សេង លាង៖**

លោកប្រធាន តាមដែលខ្ញុំដឹង ចម្លើយរបស់សាក្សី គាត់មិនបានសន្និដ្ឋានទេ។ គាត់ស្ដាប់ឮអ្នកជិតខាងប្រាប់គាត់អំពីព័ត៌មាននេះ។ នេះអ្វីដែលខ្ញុំស្ដាប់បាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោកសាក្សី សូមលោកអញ្ជើញឆ្លើយ!

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

[១៥:៥៤:៥៥]

**លោក អ៊ុំ ជី៖**

**ឆ៖** ខ្ញុំ ដូចយោបល់សហព្រះរាជអាជ្ញាមានប្រសាសន៍អំមិញអ៊ីចឹង គឺថាតែបាត់ទៅនៅភូមិថ្មីតែបាត់ មានតែយកទៅសម្លាប់ហ្នឹង មានដែលភូមិថ្មីឯណា គេធ្វើឯណា អាហ្នឹងសម្លាប់ មុខតែសម្លាប់ហើយបានជាបាត់។ អានេះការសន្និដ្ឋាន មិនឃើញគេសម្លាប់ទេ ប៉ុន្តែវាបាត់។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មុននឹងផ្អាកសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះសូមរំឭកសាជាថ្មីដល់ភាគី និងសាធារណជនបានជ្រាបថា នៅសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងមិនធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ទំនប់ត្រពាំងថ្មទេ។ ដោយទុកពេលវេលាសម្រាប់ភាគីពាក់ព័ន្ធសំណុំរឿង០០២ មានលទ្ធភាពពិនិត្យឯកសារនានា ដែលទើបត្រូវបានដាក់បង្ហាញជាថ្មីនាពេលថ្មីៗនេះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ ហើយម្យ៉ាងវិញទៀត ដោយមានធុរៈផ្ទាល់ខ្លួនចាំបាច់ យើងខ្ញុំដែលជាប្រធានអង្គជំនុំជម្រះនឹងអវត្តមាននៅក្នុងសវនាការដែលនឹងគ្រោងធ្វើនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សប្តាហ៍ទី២ ពីថ្ងៃទី១០ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ នៅក្នុងអំឡុងពេលអវត្តមានខ្ញុំជាប្រធានអង្គជំនុំជម្រះ លោក យ៉ា សុខន ដែលជាចៅក្រមជាតិមានអាយុចំណាស់ជាងគេ នឹងដឹកនាំសវនាការដោយស្វ័យប្រវត្តិ ដោយអនុលោមតាមវិធាន៧៩(៥) នៃវិធានផ្ទៃក្នុង ហើយចៅក្រមបម្រុងនឹងចូលជំនួសកន្លែងទំនេរ។ អាស្រ័យហេតុនេះសូមភាគី និងសាធារណជនជ្រាបជាព័ត៌មាន។

[១៥:៥៦:៤៥]

សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១០ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ ទី១០ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះនឹងធ្វើសវនា-ការស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុ -- សាក្សីពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការដ្ឋានទំនប់ត្រពាំងថ្ម ដោយចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-845 ហើយនិងសវនាការបន្តបន្ទាប់ទៅតាមលំដាប់លំដោយនៃបញ្ជីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីរួចហើយ ដោយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងពីពេលកន្លងមក សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក អ៊ុំ ជី ការស្តាប់សក្ខីកម្មរបស់លោកបានចប់ហើយ ហើយអរគុណដែលថា លោកបានចំណាយពេលវេលាដ៏មានតម្លៃ ហើយមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី នៅក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោក អ៊ុំ ជី ជួបតែសំណាងល្អ មានសេចក្តីសុខ សេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក អ៊ុំ ជី វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃចន្ទ ទី១០ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*